# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ឆ្នាំទី ៣០ លេខ ២ ខែកុម្ភៈ

ព.ស. ២៥០០ គ.ស. ១៩៥៨

– ភ្នំពេញ –

1958 _ 2

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

*ផ្នែកសាសនា*      *បញ្ជីរឿង*      *ទំព័រ*


- ប្រវត្តិពុទ្ធសាសនា នៅប្រទេសខ្មែរ ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . . . . . ៩៧
- សព្ទសមាសកថា របស់ព្រះឧបាលិវង្ស ស្វរ-ហាយ ក្រុមជំនុំព្រះត្រៃបិដក . . . . ១០១
- សេចក្ដីពិចារណានៃពុទ្ធសាសនិកជនម្នាក់ (តអក) លោកភ៉យ-ប៊ុក រៀបរៀង . . ១១៣

*ផ្នែកអក្សរសាស្ត្រ*

- រឿងទេវន្ទះរបស់អម្រឹតក្សត្រីម៉ុក (តមក) លោកញ៉ុក-ថែម ពិនិត្យ . . . . . . . ១១៧
- រឿងសាមកុក (តមក) . . . . . . . ឧកញ៉ានូ-កន ប្រែ . . . . . . . ១២៩
- រឿងអ្នកគង្វាលចៀមចិត្តស្មោះត្រង់និងព្រះរាជធីតា (តមក) លោកផេង-ជ្រីវ រៀបរៀង ១៤១
- រឿងចៅបាយក្ដាំង (តមក) លោកទៀង-តៃ-ឈុន ប្រែរៀបរៀង . . . . . . ១៤៧
- រឿងនាងនាយចង្ក្រាន លោកលាង-ហាប-អាន រៀបរៀង . . . . . . . . ១៥១
- រឿងព្រេងនិងរឿងបូរាណនៃប្រទេសជប៉ុន លោក ភ៉យ-ប៊ុក ប្រែរៀបរៀង . . . . ១៦៣

*ផ្នែកកំណត់ហេតុប្រវត្តិការណ៍*

- ពិធីអនុស្សាវរីយ៍ មហាសន្និបាតលើកទី ១៤ នៃមន្ត្រីសង្ឃ លោក ឯន-ប៉ង់ រៀបរៀង ១៦៧
- ដំណើរទស្សនាការសហរដ្ឋអាមេរិកនៃព្រះពោធិវង្ស (តមក) លោកជា-ទន់ រៀបរៀង ១៧១
- ពិធីទទួលព្រះត្រៃបិដកអក្សរទីបេតលោក ភ៉យ-ប៊ុក រៀបរៀង . . . . . . . . ១៧៧
- ពិធីទទួលព្រះត្រៃបិដកអក្សរចិន ស្រី អ៊ូ រៀបរៀង . . . . . . . . . . ១៨៣
- វចនានុក្រមសំស្ក្រឹត ខ្មែរ (តមក) ព្រះមហាបាង-ខាត់ រៀបរៀង . . . . . . ១៩២


មួយឆ្នាំមាន ១២ សៀវភៅ ដំរៃប្រាក់ ២៣០៛០០

# KAMBUJASURIYA

Revue religieuse et littéraire
éditée par l'Institut Bouddhique

## TABLE DES MATIERES

*PARTIE RELIGIEUSE* :

-Histoire du Bouddhisme au Cambodge par Vén. *PANG-KHAT* . . . . . . . . . . . . . . . . . . 97
-Sabbhisamasakatha (suite) par Vén. *SO-HAY* . . . . . .101
-Réflexion d'un Bouddhiste (suite) par *M. RAY-BUC* . . 113

*PARTIE LITTERAIRE* :

-Histoire de Devanda de *M. MOK* (suite) revue et corrigée par *M. NHOK-THEM* . . . . . . . 117
-Histoire de Samkok (suite) traduit par *M. NOU-KAN* . . 129
-Le Berger fidèle de la princesse (suite) par *M. PHENG-CHRIV* . . . . . . . . . . . . . . 141
-Légende de «Sieur Croûte de riz» (suite) traduit par *M. TIANG-TAY-CHHUN* . . . . . . . . . . 147
-Histoire du Cendrillon traduit par *M. LEANG-HAP-AN* . 151
-Conte et légende du Japon traduit par *M. RAY-BUC* . 163

*NOTES ET CHRONIQUES* :

-Quatorzième réunion annuelle des dignitaires religieux pour l'année 1958 par *M. EN-PANG* . . . . . . 167
-Voyage du Vén. Huot-Tat aux U.S.A (suite) par *M. CHEA-TON* . . . . . . . . . . . . . . . 171
-Cérémonie de réception des Tripitaka en langue tibétaine par *M. RAY-BUC* . . . . . . . . . . 177
-Cérémonie de réception des Tripitaka en langue chinoise par *M. SREY-OU* . . . . . . . . . . . 183
-Dictionnaire Sanskrit-Khmèr (suite) par Vén. *PANG-KHAT* . . . . . . . . . . . 192

---

Prix d'abonnement annuel (comprenant 12 numéros) : 230 r 00

# ផ្នែកសាសនា

## ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ

ព្រះមហា ប៉ាង - ខាត់ រៀបរៀង

ប្រទេសខ្មែរបានទទួលអរិយធម៌ឥណ្ឌៀទុកជាមត៌ក តាំងពីបុរាណ-កាល, សាសនាព្រាហ្មណ៍ក្តី ពុទ្ធសាសនាក្តី ដែលបានមកប្រតិស្ឋាននៅលើដែនដីខ្មែរហើយ ក៏ក្លាយទៅជាអរិយធម៌សម្រាប់ប្រទេស ប្រជាជនខ្មែរបានរក្សាអរិយធម៌នោះទុកជាប្រពៃណីដោយប្រពៃ តពូជពង្សរៀងរបរហូតមកដល់បច្ចុប្បន្នកាល ។ ដើមឡើយ, បុព្វជនខ្មែរ ក៏ដូចជាបុព្វជននៃមនុស្សទាំងឡាយ លើពិភពលោកសម័យមុនប្រវត្តិសាស្ត្រដែរ តែងតែគោរពលោកធាតុគឺ ទឹក ដី ភ្លើង ខ្យល់ អារក្ស ទេពារក្ស ព្រះធរណី ព្រះពាយ យកឈើព្រៃក្តីក្រឹថ្មជាទីពឹងទីរឭក សម្រាប់បង្ក្រាបភ័យគក់ស្លុតដូចយើងបានឃើញគោរពល្ងៀងអារក្ស ជាទំនៀមយើង ក្នុងកាលសព្វថ្ងៃនេះ

(១) សមនឹងពុទ្ធភាសិតថា :

១- ធម្មបទ ១

" មនុស្សទាំងឡាយច្រើន ដែលត្រូវភ័យគម្រាមហើយ
តែងយកភ្នំ ព្រៃ អារាម ឈើ ចេតិយ ជាទីពឹងទីពុក នុះ
មិនមែនជាសរណៈក្សេមទេ នុះមិនមែនជាសរណៈឧត្តមទេ ។

សម័យតមក ប្រជាជនខ្មែរស្រាល់ជ្រើសយកសាសនាតែមួយ ដែលខ្លួនយល់ឃើញថាជាសរណៈឧត្តម អាចបង្ក្រាបភ័យតក់ស្លុតបាន អាចសម្រេចសេចក្ដីប្រាថ្នា និងសេចក្ដីសង្ឃឹមបាន ព្រមទាំងអាចបញ្ជាក់នូវសេចក្ដីទុកចិត្តរបស់ខ្លួន ទៅអនាគតបានផង សមដូចពុទ្ធភាសិតថា:(១)

"អ្នកណាបានដល់នូវព្រះពុទ្ធព្រះធម៌ព្រះសង្ឃ
ទុកជាទីពឹងទីពុក បានឃើញច្បាស់នូវអរិយសច្ច
ទាំង ៤ ដោយប្រាជ្ញាប្រពៃ គឺទុក្ខសច្ច ១
សមុទយសច្ច ១ និរោធសច្ច ១ មគ្គសច្ចមាន
អង្គ ៨ ជាដំណើរទៅកាន់ក្ដីរម្ងាប់ទុក្ខ ១
នុះឯងជាសរណៈក្សេម នុះឯងជាសរណៈឧត្តម
អ្នកនោះ ទើបរួចចាកទុក្ខទាំងពួងបាន ព្រោះ
ការស្រ័យនូវសរណៈឧត្តមនេះ ,, ។

ក្នុងសាសនាបានទូន្មានអប់រំប្រជាជនខ្មែរ ហើយបង្រៀនឲ្យចេះប្រើដំរិះគតិ យកឈ្នះនូវដំណើរគតិយមនៃបុគ្គលជន ត្រាតែរសព្រះធម៌ជ្រួត

១ ធម្មបទ ។

ជ្រាប ក្នុងសាច់ឈាមនិងជីវិតចិត្តថ្លើមរៀងរាល់ថ្ងៃ ។ តាំងពីបានចូលមក
ប្រតិស្ឋាននៅលើដែនដីខ្មែរហើយ ព្រះពុទ្ធសាសនាក៏បានតាំងនៅស៊ប់
ឥតសាបសូន្យទៅក្នុងវេលាណាមួយឡើយ គ្រាន់តែមិនបានចេញឈ្មោះ
ជាផ្លូវការ ឬមិនបានទទួលក្តីប្រោសប្រាណពីរាជសំណាក់ ក្នុងកាលខ្លះ
ប៉ុណ្ណោះ ហើយផ្សាយឥទ្ធិពលទៅលើសិល្បៈ និងអក្សរសាស្ត្រខ្មែរទៀត
ផង ។ ក្នុងសម័យអាប់ទុន ព្រះពុទ្ធសាសនាអាចជ្រកជ្រៀតនៅជាមួយ
សាសនាព្រាហ្មណ៍បាន ហើយឋិតថេរចិរកាល នៅរហូតមក ដូច
ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរបង្ហាញឱ្យឃើញស្រាប់ ។

ប្រភពផ្សាយពុទ្ធសាសនាចូលមកប្រទេសខ្មែរ. ក្រោយ
ពុទ្ធបរិនិព្វានទៅ ប្រមាណជា ២១៨ ឆ្នាំ មានព្រះរាជាមួយអង្គព្រះនាម
ព្រះបាទធម្មាសោកមហារាជ បានឡើងសោយរាជ្យក្នុងព្រះរាជធានីបាត-
លិបុត្តនៃមគធរដ្ឋ ។ ព្រះរាជាអង្គនេះ ប្រកបដោយឫទ្ធានុភាពច្រើន ផ្សាយ
តេជានុភាពទូទៅពេញប្រទេសឥណ្ឌា ។ ទ្រង់បានចូលកាន់ពុទ្ធសាសនា
ហើយបានជាព្រះរាជូបត្ថម្ភក្នុងការធ្វើតតិយសង្គាយនា ព.ស. ២៣៤ ។
លុះធ្វើតតិយសង្គាយនាហើយ ទ្រង់បានបញ្ជូនសមណទូតទៅកាន់បច្ច-
ន្តប្បទេសនានា ផុតពីដែនដីមជ្ឈិមប្រទេសមុនដំបូងអស់ ក្នុងប្រវត្តិ
ពុទ្ធសាសនា ។ ការបញ្ជូនសមណទូតទៅប្រកាសពុទ្ធសាសនា នៅ

ប្រទេសនានាគ្រានេះ ឈ្មោះថា ទ្រង់បានបើករនាំងសកលលោក ហើយបំភ្លឺឲ្យប្រជានិករបានស្គាល់ពុទ្ធសាសនា តាំងពីកាលនោះមក ៗ ក្នុងបច្ចុប្បន្នកាលនេះ ពិភព·លោកទាំងមូល បានទទួលស្គាល់ពុទ្ធសាសនា ហើយ នៅទ្វីបអឺរ៉ុបក្ដី ទ្វីបអាមេរិកាក្ដី ទ្វីបអាហ្វ្រិកាក្ដី ស្ទើរតែមិនមានទីចន្លោះ មានជនានុជនចូលកាន់សាសនាពុទ្ធរ័តន៍ កាន់តែកើនច្រើនឡើង ហើយ ឥឡូវនេះ មានទីឋានណាមួយ ដែលមិនស្គាល់ពុទ្ធសាសនា? ឃើញថា បានលទ្ធផលសមតាមព្រះរាជបំណងព្រះអង្គមែន ៗ

យើងបានដឹងតាមប្រវត្តកោះសិរីលង្កាថា ក្រោយកាលធ្វើតតិយ-សង្គាយនា ព្រះមោគ្គលីបុត្តតិស្សត្ថេរ បានបញ្ជូនព្រះសោណត្ថេរនិងព្រះឧត្តរត្ថេរមកកាន់សុវណ្ណភូមិ ក្រោមព្រះរាជូបត្ថម្ភនៃព្រះបាទធម្មាសោក (១) មហារាជ ដូចសេចក្ដីក្នុងគម្ពីរបឋមសមន្តបាសាទិកា ចែងទុកថា:

"ធ្វើតតិយសង្គាយនារួចហើយ ព្រះមោគ្គលីបុត្តតិស្សត្ថេរត្រិះរិះថា ព្រះពុទ្ធសាសនានឹងតាំងនៅដោយប្រពៃ ក្នុងទីឋានណាហ្ន៎? ព្រះមហាថេរត្រិះរិះហើយឃើញថា ព្រះពុទ្ធសាសនានឹងតាំងនៅដោយប្រពៃ ក្នុងបច្ចន្តប្បទេសទាំងឡាយ ស្រេចហើយព្រះមហាថេរក៏បានបញ្ជូនភិក្ខុទាំងឡាយជាសមណទូតកាន់ទីនោះ ៗ"

---

១- ត្រង់ពាហិរនិទានវណ្ណនា, មហាវង្ស ។

(មានត)

សត្ថិសមាសកថា

របស់ព្រះឧបាលិវង្ស ស្បូវ · ហាយ វត្តឧណ្ណាលោម ក្រុមជំនុំព្រះត្រៃបិដក

( តមក )

៣) តណ្ហាសន្ថវៈ សេចក្ដីស្និទ្ធស្នាលចំពោះតណ្ហា ។

## អធិប្បាយ

១) ពាក្យថា "សេចក្ដីស្និទ្ធស្នាលចំពោះធម៌" បានដល់ការយកចិត្តទុកដាក់ ក្នុងធម៌ទាំងឡាយ ដែលព្រះអរិយៈមានព្រះពុទ្ធជាដើមសំដែងទុកមកហើយ ។ ពាក្យថា "ធម៌ទាំងឡាយ"នេះលេបសេចក្ដីបានច្រើនណាស់ ក្នុងទីនេះមិនបានប្រែសព្ទរបស់ពាក្យថា"ធម៌" ឲ្យជាប់មកបានឡើយ ប៉ុន្តែពាក្យថា"ធម៌"ក្នុងទីនេះ លោកសំដៅយកពុទ្ធវចនៈទាំងអស់គឺព្រះត្រៃបិដក ដែលព្រះអង្គបញ្ញត្តសំដែង បង្អួលបង្ហាញហេតុផល ជាគោល ជាគំរូស ឲ្យសត្តនិករយល់ឃើញដោយខ្លួនឯង ហើយស្មោគចិត្តប្រព្រឹត្តតាមសមគួរដល់ភេទរបស់ខ្លួន ។ ឯពាក្យថា "ព្រះត្រៃបិដក" នេះ ជាឈ្មោះទាំងធម៌ទាំងវិន័យ ជួនកាលលោកហៅថា " បាវចនៈ " ប្រែថា " ពាក្យជាប្រធាននៃព្រះសម្មាសម្ពុទ្ធ"ឬប្រែថា "ព្រះពុទ្ធសាសនា" ដូច្នេះក៏បាន ដោយហេតុថា លោកកាប់យកគោលធម៌មួយ វិន័យមួយ ទាំងពីរមាត់នេះ រួមមកហៅថា "សាសនា" ។ ពាក្យថា "ធម៌" បាត់ជាបិដកមាន ២ គឺសុត្ត-

ន្តបិដក ១ អភិធម្មបិដក ១ ។ សុត្តន្តបិដកនោះ ប្រដាប់ដោយធម្មក្ខន្ធ ២១០០០, អភិធម្មបិដក ប្រដាប់ដោយធម្មក្ខន្ធ ៤២០០០ ។

សុត្តន្តបិដក មាននិកាយ៥គឺ ទីឃនិកាយ សំដែងដោយសូត្រ មានសេចក្តីវែងៗ, មជ្ឈិមនិកាយ សំដែងដោយសូត្រ យ៉ាងកណ្តាលៗ, សំយុត្តនិកាយ សំដែងដោយសូត្រ ដែលប្រកបផ្សំនឹងហេតុ ឬបុគ្គលៗ អង្គុត្តរនិកាយ សំដែងធម៌ជាពួកជាកងៗ, ខុទ្ទកនិកាយ សំដែងដោយសូត្រតូចៗ ។

អភិធម្មបិដក មាន៧គម្ពីរ គឺធម្មសង្គណីៗ វិភង្គៗ ធាតុកថាៗ បុគ្គលបញ្ញត្តិៗ កថាវត្ថុៗ យមកៈៗ មហាបដ្ឋានៗ ។

វិន័យបិដកនោះ ចាត់ជាខន្ធមាន២១០០០ខន្ធ ។ បើចែកតាមពួកយ៉ាងធំ មាន២យ៉ាងគឺ អនាគារិយវិន័យ វិន័យសម្រាប់បព្វជិតៗ អាគារិយវិន័យ វិន័យសម្រាប់គ្រហស្ថៗ ។

វិន័យបិដកមាន ៥ គម្ពីរគឺ មហាវិភង្គៗ បាចិត្តិយៗ មហាវគ្គៗ ចុល្លវគ្គៗ បរិវារៈៗ ។ ពាក្យថា "វិន័យ" នេះ បានដល់ច្បាប់ ដែលជាប់ទាក់ទងដោយពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត ដែលតែងតាំងទុកដោយពុទ្ធ-អាជ្ញាចាត់ជាសិក្ខាបទ ឬជាមាត្រាមួយៗ នឹងអភិសមាចារៈ ដើម្បីទូន្មានកាយវាចារបស់ពុទ្ធបរិស័ទ ឲ្យមានសណ្តាប់ធ្នាប់រៀបរយល្អឡើង ។

ពាក្យថា "បិដក" មានសព្ទដែលត្រូវប្រែដូចតទៅនេះ ៖

ប្រែថា

១- គ្រឿងបញ្ចេញនូវអត្ថ,

២ គ្រឿងបញ្ចេញនូវធម៌,

៣- ភាជនៈ នៃបរិយត្តិ គឺការសិក្សា ឬមេរៀន,

៤- ផ្គោះសំឡេង គឺជម្ពាំងសម្រាប់បោះបញ្ចេញនូវសំឡេង,

៥- តម្រា គឺក្បួន ឬច្បាប់ដែលកត់ត្រាទុក,

៦. ល្អី ឬ កញ្ជើ,

៧- ការរួបរួមប្រមូលទុក ( នូវឯកសារ ) ។

ព្រះត្រៃបិដកនេះ ជាឈ្មោះគម្ពីរនៃព្រះពុទ្ធសាសនា កាលបើបុគ្គលណាមួយ ទោះបព្វជិត ឬគ្រហស្ថ បានសិក្សាអប់រំល្អហើយ អាចនាំឱ្យផ្ទុះបំភ្លឺ ឃើញសារប្រយោជន៍ទាំងផ្លូវលោកផ្លូវធម៌ ។ ព្រះត្រៃបិដកនេះមានទ្រឹស្តី (ពាក្យពន្យល់ឱ្យឃើញហេតុផល) ជាច្រើនយ៉ាង, មានអត្ថបទល្អៗ ជាច្រើនណាស់, មានវប្បធម៌ ក្នុងផ្នែកអក្សរសាស្ត្រ ក៏បរិបូណ៌ណាស់, ធម៌ជាន់ខ្ពស់ គឺសមាបត្តិ, ឈាន, មគ្គផលនិព្វាន ដែលជាទីដៅរបស់ព្រះពុទ្ធសាសនា ក៏មាននៅក្នុងព្រះត្រៃបិដក ដោយបរិបូណ៌ ។ ព្រះត្រៃបិដកទុកជាឯកសារ ដ៏ប្រសើរបំផុត ឈ្មោះថា ជាឃ្លាំងរបស់វប្បធម៌ក្នុងផ្នែកអក្សរសាស្ត្រ ទាំងជាប់ទាក់ទងដោយផ្លូវវិទ្យាសាស្ត្រផង ។

ការសិក្សារបស់មនុស្សនៅក្នុងលោក ដើម្បីចេះដឹងតែខាងវិជ្ជាផ្លូវ

លោក ឈ្មោះថា មានភ្នែកផ្លូវលោក, ការសិក្សាគម្ពីរព្រះត្រៃបិដកនៃព្រះពុទ្ធសាសនា ដើម្បីចេះដឹងក្នុងផ្លូវធម៌ ឈ្មោះថា មានភ្នែកខាងផ្លូវធម៌ ។ ការសិក្សាទាំងវិជ្ជាលោកទាំងវិជ្ជាធម៌ ឲ្យមានបញ្ញាចក្ខុមើលឃើញច្បាស់ទាំងផ្លូវលោកផ្លូវធម៌ ទើបឈ្មោះថា មានភ្នែកទាំងពីរ ។ បព្វជិតឬគ្រហស្ថ អ្នកមានការចេះដឹងច្រើន ដោយសារការសិក្សាមើលច្បាប់ទម្លាប់ច្រើន ទើបហៅថា ជាបុគ្គលពហុស្សុត ជាអ្នកមានភ្នែកភ្លឺទាំងពីរ គឺភ្នែកលោក ភ្នែកធម៌ ។

ព្រះសារីបុត្រជាអគ្គសាវ័កខាងស្តាំរបស់ព្រះសម្មាសម្ពុទ្ធ ជាឯតទគ្គៈ (មានកិត្តិសព្ទគ័កល្បីល្បាញ នាះ) ព្រោះហេតុតែលោកសិក្សារៀនសូត្រច្រើនចំពោះខ្លួនផង កសាងគម្ពីរដីកាជាធម្មទាន ដើម្បីឲ្យគេរៀនសូត្រតទៅផង ទើបព្រះសារីបុត្រ មានប្រាជ្ញាឈ្លាសវៃស្រួចស្រាលល្បីល្បាញបន្ទាប់បន្សំនឹងព្រះសម្មាសម្ពុទ្ធ ដោយអានិសង្សនៃធម្មទាន ដែលលោកបានសំរៀកសាងមក ព្រោះថា ធម្មទាន ជាទានប្រសើរណាស់ជាងអាមិសទានទាំងអស់ សមដូចពុទ្ធភាសិតថា

សព្វទានំ ធម្មទានំ ជិនាតិ សព្វរសំ ធម្មរសោ ជិនាតិ
សព្វរតិំ ធម្មរតិ ជិនាតិ សព្វទុក្ខំ តណ្ហក្ខយោ ជិនាតិ ។

ធម្មទាន រមែងឈ្នះអាមិសទានទាំងអស់ ធម្មរស រមែងឈ្នះរសទាំងអស់ សេចក្តីត្រេកអរក្នុងធម៌ រមែងឈ្នះតម្រេកទាំងអស់ ការអស់

គណ្ហា រមែងឈ្នះសេចក្ដីទុក្ខទាំងអស់ ។ ពុទ្ធភាសិតនេះ បំភ្លឺសេចក្ដីថា " បណ្ដាទានទាំងអស់ មានតែធម្មទាន ទើបជាទានប្រសើរខ្ពង់ខ្ពស់អាចឲ្យសម្រេចផលានិសង្ស ក្នុងលោកនេះផង ក្នុងលោកខាងមុខផង " ។ ពាក្យថា "ធម្មទាន" សំដៅយកទាំងការរៀនសូត្រដោយខ្លួនឯងទាំងការសំដែងឲ្យអ្នកដទៃស្ដាប់ ទាំងការបង្រៀន ទាំងការកសាងគម្ពីរដីកាដោយការដាក់ទុកសម្រាប់សាធារណជន ដើម្បីសិក្សារៀនសូត្រតទៅ ។

សកម្មភាពនៃពុទ្ធសាសនបណ្ឌិត្យក្រុងភ្នំពេញ បានប្រែព្រះត្រៃបិដកពីបាលីមកជាភាសាខ្មែរ ចប់ស្រេចហើយ, បានបោះពុម្ពដល់ភាគទី ៥២ហើយ ។ លោកអ្នកដែលត្រូវការក្នុងវិប្បធម៌ក្ដី ក្នុងផ្លូវសីលធម៌រម៉ែយធម៌ក្ដី ក្នុងផ្លូវប្រតិបត្តិធម៌ក្ដី គួរអានមើល គួរពិនិត្យ គួរដាក់ទុកជាសម្បត្តិប្រចាំជីវិត ដើម្បីនឹងសិក្សាគាំទ្រអាយុព្រះពុទ្ធសាសនាទៅអនាគត ។ ព្រះត្រៃបិដកជាគម្ពីរនៃព្រះពុទ្ធសាសនានេះ សម្បូណ៌ដោយរឿងនិទាន, ដោយអត្ថបទដ៏ល្អច្រើនណាស់, ដោយវប្បធម៌ផ្នែកខាងអក្សរសាស្ត្រដោយគល្បាណវត្តជាច្រើនណាស់. ព្រះត្រៃបិដក ទុកជាមូលដ្ឋាននៃព្រះពុទ្ធសាសនាដោយពិត ។

សេចក្ដីស្ទួនស្ទាល, សេចក្ដីជ្រះថ្លាពេញចិត្ត ចំពោះធម៌នេះ ទុកជាករណីយកិច្ចដ៏ឧត្ដម របស់មនុស្សសប្បុរស គឺមនុស្សល្អដែលអាចធ្វើបានជាមួយនឹងពួកសប្បុរស ហើយជាបុញ្ញកម្មមួយដ៏ប្រសើរបំផុត របស់យើង

អ្នករស់នៅក្នុងលោក ដែលអ្នកមានគុណធម៌ពិតទាំងឡាយ គួរបំពេញឲ្យកើតមាន សម្រាប់ជីវភាព ដែលបំណាច់កើតមកជាមនុស្ស ទាន់ព្រះពុទ្ធសាសនា ។

២) ពាក្យថា "សេចក្ដីស្និទ្ធស្នាលចំពោះបុគ្គល" សំដៅយកមនុស្សជាបុរសក្ដី ជាស្ត្រីក្ដី ជាគ្រហស្ថក្ដី ជាបព្វជិតក្ដី ដែលមានសីលធម៌ ឬពុំទាន់មានសីលធម៌នៅឡើយ ប៉ុន្តែជាមនុស្សគួរសេពគប់ ក៏ត្រូវតែធ្វើនូវសេចក្ដីស្និទ្ធស្នាលរាប់អាន ទទួលស្គាល់ ដោយគោរព ដើម្បីចងសាមគ្គីភាពក្នុងរវាងគ្នានឹងគ្នា ឲ្យកើតផ្កាយទូលាយតទៅ ។

## សង្គហៈ ៣ យ៉ាងទៀត

១) ពាក្យថា "សេចក្ដីស្និទ្ធស្នាលចំពោះលោក" បានដល់សេចក្ដីស្រឡាញ់ពេញចិត្ត ប្រកបដោយសេចក្ដីសន្ដោស ចំពោះលោកដែលកើតឡើងហើយប្រកបដោយធម៌ មិនត្រូវរវះរាមហួសប្រមាណ ហួសហេតុក្នុងការស្វែងរកលាភនោះឡើយ ព្រោះការស្វែងរក ការចង់បានដែលប្រាសចាកធម៌សន្ដោស ច្រើនតែនាំឲ្យមានការប្រព្រឹត្តទុច្ចរិត មានការលោភដណ្ដើមជាដើម ។

២) ពាក្យថា "សេចក្ដីស្និទ្ធស្នាលចំពោះមិត្ត" បានដល់ការស្គាល់ស្និទ្ធយល់ចិត្តថ្លើមគ្នា, ការសង្គ្រោះមិត្រសំឡាញ់ ដោយប្រយោជន៍ណាមួយ ក្នុងកាលដែលមិត្រសំឡាញ់ត្រូវការ ឬមានគ្រោះថ្នាក់ ដើម្បីទំនុក

បំរុងមិត្រផ្សាភ្ជាប់មិត្តភាពរវាងខ្លួននឹងមិត្រសំឡាញ់ មិនឲ្យប្រេះឆារបែកសាមគ្គីរវាងមិត្ត ។

៣) ពាក្យថា "ស្និទ្ធស្នាលចំពោះតណ្ហា" បានដល់ការប្រព្រឹត្តិរបស់មនុស្សបុថុជ្ជន ដែលច្រើនតែលុះក្នុងអំណាចនៃតណ្ហា ដោយពិត ប៉ុន្តែធម្មតា មនុស្សជាសប្បុរស ទោះបីធ្វើការណាមួយដោយកាយវាចា តែងស្គាល់ប្រមាណក្នុងករណីយកិច្ចជាដរាប ពុំបានលុះលង់គំនិត ពុលស្រវឹងទៅក្នុងកិច្ចការនោះ ៗ ឲ្យហួសប្រមាណទេ តែងភ្ញាក់ដឹងខ្លួនរឿយៗ ដោយអំណាចការចេះដឹង ។ ការស្និទ្ធស្នាលចំពោះអារម្មណ៍ទាំងអស់ ដែលប្រកបដោយរាគតណ្ហា លោកហៅថា ជាបហាតព្វកិច្ច គឺកិច្ចដែលត្រូវលះបង់ មិនត្រូវបណ្តោយឲ្យរាគតណ្ហាគ្របសង្កត់ ញាំញីចិត្តរបស់ខ្លួនបានឡើយ ។

បុគ្គលដែលបានធ្វើសេចក្តីស្និទ្ធស្នាល ដោយការពេញចិត្តជ្រះថ្លាចំពោះធម៌ ចំពោះបុគ្គលដូចរៀបរាប់មកនេះ ឈ្មោះថាជាឧត្តមបុរសក្នុងលោក ។ បុគ្គលជាអ្នកប្រាជ្ញ ដែលត្រូវអ្នកឯទៀតចូលទៅសេពគប់ តែងតែព្រមានដាស់តឿនចង្អុលប្រាប់ប្រយោជន៍ ក្នុងផ្លូវនាំឲ្យបានជួបប្រទះនូវសុភមង្គលដល់អ្នកឯទៀតជាដរាប មិនដែលបង្ហាញផ្លូវដើម្បីឲ្យវិនាសបាត់ប្រយោជន៍ឡើយ សមដូចពុទ្ធភាសិត ក្នុងធម្មបទខុទ្ទកនិកាយ ថា

និធីនំវ បវត្តារំ យំ បស្សេ វជ្ជទស្សិនំ
និគ្គយ្ហវាទឹ មេធាវឹ តាទិសំ បណ្ឌិតំ ភជេ ។

បុគ្គលដែលឃើញបណ្ឌិតណា ជាអ្នកមានប្រាជ្ញា ចង្អុលបង្ហាញទោស ពោលពាក្យសង្កត់សង្កិន (ដោយទុច្ចាយល្អ) ដូចមនុស្សប្រាប់កំណប់ទ្រព្យ គួរសេពគប់បណ្ឌិតនោះចុះ ។ ពុទ្ធភាសិតនេះ បង្ហាញពីការគប់ឲ្យឃើញថា "បណ្ឌិតតែងដឹកនាំគេ ចង្អុលប្រាប់ផ្លូវទៅរកគុណ មិនដែលដឹកនាំគេទៅរកទោសទេ ទោះបីមានមាត់ពាក្យគម្រាមកំហែង តាមវិធីប្រៀនប្រដៅខ្លះក៏ដោយ ត្រូវតែចូលទៅជិតសេពគប់ ដើម្បីចម្លងរបៀបផ្សេង ៗ ផង ដើម្បីញ៉ាំងសម្ពន្ធភាពមិនឲ្យប្រេះឆាផង " ។

មនុស្សទាំងអស់ក្នុងលោក តែងជាប់ទាក់ទងដោយការសេពគប់គប់រកគ្នាជាយពិត ប៉ុន្តែការសេពគប់នោះ នាំមកនូវសេចក្តីចំរើនក៏មាននូវសេចក្តីវិនាសក៏មាន ព្រោះហេតុនោះ បានជាព្រះអរហន្ត សម្មាសម្ពុទ្ធត្រាស់ថា " បុគ្គលត្រូវពិចារណាស្ទាបស្ទង់ឲ្យឃើញជាមុន សឹមសេពគប់ជាខាងក្រោយ ព្រោះការសេពគប់នេះ ទុកជាបញ្ហាមួយក្នុងជីវភាពរបស់មនុស្ស" ។ បើបុគ្គលសេពគប់ ចំពោះមនុស្សសប្បុរសជាអ្នកចេះដឹង រមែងបានស្តាប់នូវធម៌គាថាណាមួយ ក្នុងសំណាក់លោកអ្នកចេះដឹងពុំខាន បើសេពគប់ចំពោះមនុស្សអសប្បុរស ជាអ្នកមិនចេះដឹងជាមនុស្សប្រព្រឹត្តទុច្ចរិត ក៏រមែងបានស្តាប់នូវពាក្យ តិរច្ឆានកថាដែលមិនមែនជាធម៌វិន័យ ។ សេចក្តីសង្ស័យកើតឡើងក្នុងធម៌ទាំងឡាយណាមួយ កាលបើបុគ្គលមានបំណងដើម្បីដោះស្រាយ ត្រូវចូលទៅ

រកមនុស្សសប្បុរសអ្នកចេះដឹង ទើបអាចដោះស្រាយសេចក្តីសង្ស័យបាន មិនមែនដោះស្រាយ ក្នុងសំណាក់នៃមនុស្សអសប្បុរសបានឡើយ ។ លោកអ្នកសប្បុរស គឺអ្នកចេះដឹង ជាអ្នកទទួលភារៈក្នុងការដោះស្រាយបញ្ហាដែលបុគ្គលត្រូវការជាអ្នកដឹកនាំ នូវសេចក្តីយល់កាន់ប្រឡំ របស់មនុស្សឲ្យយល់ឃើញត្រូវ ឲ្យមានសតិសម្បជញ្ញៈ គ្រប់គ្រាន់ តាមសមគួរដល់សមត្ថភាព របស់ខ្លួន ឲ្យស្គាល់ចំណែកនៃសេចក្តីប្រតិបត្តិខាងដើម កណ្តាលនិងខាងចុង តាមជំនាន់វ័យរបស់មនុស្ស ។ ជម្ពា លោកអ្នកសប្បុរស អ្នកមានកាយវាចាចិត្តស្ងប់រម្ងាប់ តែងដឹកនាំជនទាំងឡាយ ឲ្យបែរមុខឈមទៅរកសេចក្តីស្ងប់រម្ងាប់ចាកបាបអកុសល ទាំងពួង ឲ្យមានកាយវាចាចិត្តបរិសុទ្ធផូរផង់ ដើម្បីដោះខ្លួនឲ្យរួចចាកទុក្ខភ័យទាំងលោកនេះនិងលោកខាងមុខ ដូចអត្ថបទទី ៣ តទៅនេះ

៣ សតំ សទ្ធម្មញ្ញាយ សព្វទុក្ខា បមុច្ចតិ បុគ្គលដឹងច្បាស់នូវព្រះសទ្ធម្មរបស់ពួកសប្បុរស រមែងរួចចាកទុក្ខទាំងពួង ។

អត្ថបទនៃពុទ្ធភាសិតទីបំផុតនេះ សំដែងចំពោះអានិសង្ស គឺលទ្ធផលដែលកើតមកអំពីការចេះដឹង, ការយល់ត្រូវ, ការប្រតិបត្តិត្រូវ, ឯការចេះដឹងយល់ត្រូវក៏កើតមកអំពីការសេពគប់លោកអ្នកសប្បុរសដោយពិត ៗ បុគ្គលអ្នករួចចាកទុក្ខគ្រប់យ៉ាង មានជាតិទុក្ខជាដើម ដែលជាពិសេសបំផុតនោះ ក៏ព្រោះហេតុនៃការចេះដឹងនូវព្រះសទ្ធម្ម ដែលជាពាក្យ

ប្រៀនប្រដៅរបស់លោកអ្នកប្រាជ្ញទាំងឡាយ មានព្រះសម្ពុទ្ធជាដើម ។

ព្រះសទ្ធម្ម បើនិយាយដោយខ្លីមាន ៣ យ៉ាង

១) បរិយត្តិសទ្ធម្ម ព្រះសទ្ធម្ម គឺជាមេរៀនសូត្រ

២) បដិបត្តិសទ្ធម្ម ព្រះសទ្ធម្ម គឺជាផ្លូវប្រតិបត្តិ

៣) បដិវេធសទ្ធម្ម ព្រះសទ្ធម្មគឺជាគន្លងដើម្បីត្រាស់ដឹង ។

ពុទ្ធវចនៈ គឺព្រះត្រៃបិដក ដែលលោកអ្នកប្រាជ្ញ បានសង្គាយនា រៀបចំទុកមក មានអង្គ ៩ មានសុត្តៈ គេយ្យៈ ជាដើម ដែលជាមេរៀនក្នុងថ្នាក់ជាដំបូង ហៅថា "បរិយត្តិសទ្ធម្ម" ។

សេចក្តីជ្រះថ្លាពេញចិត្ត សេចក្តីយល់ច្បាស់ ក្នុងកុសលធម៌ទាំងឡាយដែលគួរចំរើនផង ក្នុងអកុសលធម៌ទាំងឡាយដែលគួរលះផង របស់បព្វជិត ឬ គ្រហស្ថ ដែលអាចចូលចិត្ត យល់សេចក្តីច្បាស់លាស់ដោយខ្លួនឯង ហើយបានទទួលគុណវិសេស តាំងអំពីឈានសមាបត្តិ រហូតដល់មគ្គផលនិព្វាន ដែលជាទីដៅដ៏ខ្ពស់បំផុត នៃព្រះពុទ្ធសាសនា ទាំងនេះហៅថា "បដិវេធសទ្ធម្ម" មនុស្សក្នុងសកលលោក បើប្រសិនជានាំគ្នាអនុវត្តឲ្យម៉ត់ចត់នូវព្រះសទ្ធម្មទាំងនេះ ប្រាកដជាបានទទួលផលនៃសន្តិសុខ ឃើញជាក់ច្បាស់ពុំខាន ព្រោះព្រះសទ្ធម្ម គង់ប្រព្រឹត្តទៅដើម្បីស្ងប់កិលេស, កាលបើកិលេសស្ងប់ សេចក្តីទុក្ខភ័យទាំងពួង ក៏វិនាសសាបសូន្យទៅជាលំដាប់ ។

ព្រះសទ្ធម្មពាយ៉ាងនេះជាគតិបណ្ឌិតដែលអាចរុងរឿងឋិតនៅតែក្នុងវង្ស នៃលោកអ្នកសប្បុរស មិនដែលឋិតនៅ មាននៅក្នុងវង្សពួកអសប្បុរសទេ កាលបើបុគ្គលត្រូវការចម្លងផ្គត់យកព្រះសទ្ធម្មទាំងនេះ ត្រូវចូលទៅសេព-គប់លោកអ្នកសប្បុរស ដូចអធិប្បាយមកហើយតាមន័យខាងដើម ។ មួយទៀត ការសិក្សា ការហាត់រៀនទន្ទេញ ការពិនិត្យមើល ឱ្យចេះចាំយល់សេចក្តី ក្នុងផ្លូវធម៌ទាំងឡាយ លោកហៅថា ជាបរិយត្តិ ។ ការវៀរចាក ទុច្ចរិត ៣ ប្រការ ការប្រព្រឹត្តកាន់តាមសុចរិត ៣ប្រការ, ការរម្ងាប់នូវកិលេសទាំងឡាយដ៏គ្រោតគ្រាត លោកហៅថា បដិបត្តិ ។ ការយល់ធ្លុះធ្លាយ ការបានគុណវិសេសមានឈានជាដើម; ការរួចចាកកិលេសថ្នាក់កណ្តាល ឬល្អិត លោកហៅថា បដិវេធៈ ។

ការសិក្សាធម៌ ប្រតិបត្តិធម៌ និងការយល់ច្បាស់ក្នុងធម៌ កាលបើបុគ្គលបានចំរើន បានពិចារណារឿយ ៗ ក៏រមែងឃើញជាក់ ដោយប្រាជ្ញាខ្លួនឯងនូវសេចក្តីសង្ស័យ ក៏រមែងអស់ទៅចាកខន្ធសន្តាន សមដូចពុទ្ធ-ភាសិតក្នុងពុទ្ធវចន ក្នុងកាលដែលព្រះអង្គទើបនឹងបានត្រាស់ថ្មី ៗ ថា

យទា ហវេ បាតុភវន្តិ ធម្មា
អាតាបិនោ ឈាយតោ ព្រាហ្មណស្ស
អថស្ស កង្ខា វបយន្តិ សព្វា
យតោ បជានាតិ សហេតុធម្មំ ។

ប្រែថា ធម៌ទាំងឡាយ រមែងកើតប្រាកដដល់ព្រាហ្មណ៍ អ្នកមានព្យាយាមជាគ្រឿងដុតនូវកិលេស អ្នកពិនិត្យរំពឹងក្នុងកាលណា សេចក្ដីសង្ស័យទាំងពួងរបស់ព្រាហ្មណ៍នោះ រមែងសាបសូន្យទៅ ព្រោះស្គាល់ច្បាស់នូវធម៌ព្រមទាំងបច្ច័យ ក្នុងកាលណោះ ។ ពាក្យថា "ធម៌ទាំងឡាយ" ក្នុងគាថានេះ បានដល់មគ្គផល ។ ពាក្យថា "ព្រាហ្មណ៍" លោកសំដៅយក អ្នកប្រព្រឹត្តធម៌យ៉ាងគឹងរឹង ដើម្បីបន្សាត់បង់នូវបាបមិនមែនសំដៅយកព្រាហ្មណ៍ដោយជាតិនោះទេ ។ ពាក្យថា "ធម៌ព្រមទាំងហេតុបច្ច័យ" នោះ លោកពោលចំពោះខន្ធ ៥ ព្រមទាំងហេតុគឺកិលេសដែលជាបច្ច័យគាត់តែងឲ្យកើតបញ្ចក្ខន្ធមានអវិជ្ជា តណ្ហាជាដើម ។

ធម្មទេសនា ចំពោះការបួងសួង សេពគប់ ដោយពួកសប្បុរសក្នុងវេលានេះក៏ល្មមសមគួរ តាមកាលបរិច្ឆេទ ។ ជាទីបំផុតនេះ សូមថ្វាយព្រះរាជកុសលនៃធម្មទេសនា ចំពោះព្រះករុណាជាម្ចាស់ជីវិតទាំងពីរព្រះអង្គ. សូមថ្វាយព្រះរាជកុសល ចំពោះសម្ដេចព្រះឧបយុវរាជ សូមឲ្យព្រះអង្គប្រកបដោយព្រះជន្មសុខគ្រប់ប្រការ! សូមជូនកុសលចំពោះលោកអ្នកពុទ្ធបរិស័ទទាំងអស់ សូមឲ្យប្រកបដោយពរទាំង ៤ ប្រការគប់ ៗ គ្នាកុំបីឃៀងឃាតឡើយ !

# សេចក្ដីពិចារណានៃពុទ្ធសាសនិកជនម្នាក់

## លោក វ៉ាយ-ប៊ុក រៀបរៀង

(តមក)

សួរ. ហេតុដូចម្ដេច ក៏គេមិនឱ្យស្ត្រីបួសក្នុងព្រះពុទ្ធសាសនា? ៗ

ឆ្លើយ. បានជាគេមិនឱ្យស្ត្រីបួស ក្នុងព្រះពុទ្ធសាសនា ព្រោះថា ធម្មតាភិក្ខុនី ដែលបួសត្រូវមានទបជ្ជាយ៍, កម្មវាចាចារ្យ ត្រូវគ្រូជាភិក្ខុនី មានវស្សាចាស់; ក្នុងសម័យកឡូវនេះ មិនមានភិក្ខុនីសោះឡើយ ៗ បើតាមសំដែងក្នុងមិលិន្ទបញ្ហា ថា ព្រះពុទ្ធសាសនាគ្រប់ ១០០០ ឆ្នាំ គិតតាំងពីព្រះសម្មាសម្ពុទ្ធ ទ្រង់ចូលព្រះនិព្វាន, នឹងបាត់ភិក្ខុនី នៅតែពួកសីលវតី គឺ ទបាសិកា អ្នកកាន់អដ្ឋង្គសីល, ពួកសិក្ខមានា គឺស្ត្រីដែលមុននឹងបួស ត្រូវកាន់សិក្ខាបទប្រាំមួយ តាំងពីបាណាតិបាត ដល់វិកាល អស់រយៈពេលពីរឆ្នាំ ៗ

សួរ. ខ្ញុំមិនទាន់បានដឹងពីសីលវតី ឬ សិក្ខមានានោះទេ គាវដែលខ្ញុំបានដឹងថា ហេតុដូចម្ដេច បានជាបាត់ភិក្ខុនី? ៗ

ឆ្លើយ. មុននឹងពណ៌នាអំពីរឿងមានភិក្ខុនី ខ្ញុំសូមជំរាបថា កាលព្រះបរមគ្រូទ្រង់គង់ធរមាននៅឡើយ, ព្រះនាងមហាបជាបតី-

គោតមី ជាម្ដាយមីង ជាម្ដាយចិញ្ចឹមព្រះអង្គ បានចូលទៅក្រាបបង្គំទូលសូមឧបសម្បទា ជាភិក្ខុនី ព្រះអង្គទ្រង់មិនយល់ព្រមសោះឡើយ ។ លើកទីពីរ ព្រះអានន្ទត្ថេរបានទៅក្រាបបង្គំទូល សូមព្រះអង្គឲ្យទ្រង់ពុទ្ធានុញ្ញាតឲ្យព្រះនាងមហាបជាបតីគោតមីបួសជា ភិក្ខុនី, ព្រះអង្គទ្រង់មិនព្រមជាដាច់ខាត ។ ដល់លើកទីបី ព្រះអានន្ទត្ថេរ ក៏ដើរឧបាយដើម្បីញ៉ាំងព្រះហឫទ័យព្រះអង្គឲ្យអនុញ្ញាត ឲ្យព្រះនាងមហាបជាបតីគោតមី បួសជាភិក្ខុនីបាន ។ ព្រះអានន្ទត្ថេរជំមានអាយុ បានក្រាបបង្គំទូលសួរព្រះអង្គថា ចំពោះស្ត្រី ដែលបានលះបង់យកវាសហើយ ទៅប្រព្រឹត្តប្រតិ-បត្តិតាមធម៌ ធ្វើសមាធិកម្មដ្ឋាន តាមបរមពុទ្ធោវាទ តើការប្រព្រឹត្តនោះនឹងបានមគ្គផល ឬ ទេព្រះអង្គ? ។

ព្រះសម្ពុទ្ធទ្រង់តបទៅវិញថា ម្នាលអានន្ទ ផលនោះប្រាកដជានឹងបាន ។

ព្រះអានន្ទត្ថេរ ក៏ក្រាបបង្គំទូល តទៅទៀតថា បើដូច្នេះ បើព្រះនាងមហាបជាបតីគោតមី មានចិត្តស្មោះស្ម័គ្រនឹងព្រះអង្គ ដោយព្រះនាង, កាលនៅជាម្ដាយមីង ក្រោយដែលព្រះនាងស្រីមហាមាយាទេវី សោយព្រះទិវាល័យ បានបីបាច់ថែរក្សាព្រះអង្គ ដូចជាកូនចេញពីសាច់, គួរណាស់តែព្រះអង្គទ្រង់អនុញ្ញាត ឲ្យព្រះនាងបួសជាភិក្ខុនីបាន, គួរណាស់

តែព្រះអង្គទ្រង់អនុញ្ញាតឲ្យស្ត្រីលះបង់គ្រួសារ ទៅប្រព្រឹត្តប្រតិបត្តិ តាមព្រះបរមពុទ្ធោវាទ ដែលព្រះអង្គទ្រង់បានសំដែងហើយ ដោយប្រពៃ រឿងនេះ មានសំដែងក្នុងខន្ធកទី ១០ ចុល្លវគ្គនៃវិន័យបិដក ។

ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងតបទៅព្រះអានន្ទត្ថេរវិញថា “ តថាគតមិនយល់ទាស់ទេ អានន្ទ បើព្រះនាងមហាបជាបតីគោតមី បង់បួសជាភិក្ខុនី ក្នុងសាសនាតថាគត ត្រូវព្រះនាងប្រព្រឹត្តប្រតិបត្តិនូវគរុកម្ម ៨ យ៉ាងសិនគឺ

១- ភិក្ខុនី បើទុកជា ឧបសម្បទាដល់ទៅ ១០០ វស្សា ក៏ត្រូវគោរពភិក្ខុ ដែលទើបនឹងបានឧបសម្បទា ១ថ្ងៃ,

២- ភិក្ខុនី ត្រូវនៅចាំវស្សានៅវត្តដែលមានភិក្ខុ,

៣- ភិក្ខុនី ត្រូវតែប្រព្រឹត្តប្រតិបត្តិនូវវត្តពីរយ៉ាងគឺ, ត្រូវសួរឧបោសថ ត្រូវទទួលឱវាទពីភិក្ខុសង្ឃ ក្នុងកន្លះខែម្តង,

៤- ភិក្ខុនី បើចេញវស្សាហើយ ត្រូវបវារណាព្រះសង្ឃទាំងពីរផ្នែក,

៥ ភិក្ខុនី បើប្រព្រឹត្តល្មើសនឹងគរុធម៌ហើយ ត្រូវប្រព្រឹត្តខមាទោស នឹងព្រះសង្ឃទាំងពីរផ្នែក គឺព្រះសម្មតិសង្ឃ នឹងព្រះអរិយសង្ឃ,

៦- ភិក្ខុនី ត្រូវឲ្យឧបសម្បទានាងសិក្ខមានា ដែលរក្សាសីល ៦ គឺ តាំងពីបាណាតិបាតរហូតដល់វិកាល,

៧- ភិក្ខុនី មិនត្រូវសម្រេចរឿងរ៉ាវរបស់ភិក្ខុ,

៨ ភិក្ខុនី មិនត្រូវបង្ហាត់បង្រៀនភិក្ខុ ៗ អាចបង្ហាត់បង្រៀនភិក្ខុនីបាន ៗ

ម្នាលអានន្ទ, បើព្រះនាងបជាបតីគោតមី បានប្រព្រឹត្តប្រតិបត្តិតាមគរុធម៌ទាំង៨យ៉ាងសព្វគ្រប់ហើយ, តថាគត នឹងអនុញ្ញាតឲ្យបួសជាភិក្ខុនីបាន ។

រឿងនេះគឺខ្ញុំដកស្រង់យកពីអដ្ឋកនិបាត អង្គុត្តរនិកាយ ។

ក្រៅអំពីនេះ ភិក្ខុនីត្រូវប្រព្រឹត្តប្រតិបត្តិតាមសិក្ខាបទ ៣០៩ (សិក្ខាបទរបស់ភិក្ខុមានតែ ២២៧, សិក្ខាបទរបស់ភិក្ខុនីលើស ៧២) ។

សួរ. ហេតុដូចម្តេច ក៏សិក្ខាបទភិក្ខុនីមានដល់ទៅ ៣០៩ សិក្ខាបទ. លើសសិក្ខាបទភិក្ខុដល់ទៅ ៧២? ។

ឆ្លើយ. ព្រះបរមគ្រូទ្រង់បញ្ញត្តសិក្ខាបទភិក្ខុនី លើសសិក្ខាបទភិក្ខុដល់ទៅ៧២ សិក្ខាបទ ដោយហេតុថា ចរិយា ភិក្ខុនីនោះលំបាកនឹងថែរក្សាពន់ពេក ប្រៀបដូចជា លើកទំនប់ទប់ទឹក កុំឲ្យហៀរហូរ ទៅកាន់ទីដទៃដូច្នោះ ៗ ម្យ៉ាងវិញទៀត, ស្ត្រីលំបាកនឹងសំគាល់ចរិយាឲ្យច្បាស់លាស់, មានកលមាយាជាច្រើនប្រការ, មានឧបាយគ្រប់បែបគ្រប់យ៉ាង ៗ សិក្ខាបទចំពោះភិក្ខុនី ក៏គង់ ឧបសម្បទាភិក្ខុនីក៏គង់ ការដែលបំបួសភិក្ខុនី គឺត្រូវបួសចំពោះមុខព្រះភិក្ខុនីសង្ឃម្តង រួចទើបព្រះភិក្ខុសង្ឃ សម្រេចជាអវសាន ៗ

(មានត)

# ផ្នែកអក្សរសាស្ត្រ

## រឿងទេវធ្ន

ពាក្យកាព្យ

### លោក អម្មតក្សត្រីម៉ុក រៀបរៀង

ក្នុងរាជ្យព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម

### លោក ញ៉ុក ថែម ពិនិត្យ

( តមក )

សារពេជ្ញពន្យពោធិ៍ មានញាណរុងរឿង ទៀនទូលទៅថា ។ បពិត្រព្រះគុណ ប្រសើរមហាធ្ងន់ ឥតឯទបមា ខ្ញុំនឹងថ្វាថ្លែង សំដែងធម្មាប្រសើរថ្លៃថ្លា សណ្តាប់ព្រះមេ ។ ធម្មតាជាសត្វ អន្ទោលក្នុងវដ្ត ភពសង្សារ អនិច្ចាអនិច្ចំ ទុក្ខំទុក្ខ ទៀវពិតតែងតែ ជិតជាយអត្តា ។ នេះហៅកម្មភាព កម្មតាយងនភាព ឲ្យអន្តមាតា អសារអសោរ អាស្រូវអាត្មា សូមព្រះបិន្ទា រំរំពឹងញាន ។

នាងស្តាប់រាជបុត្រ ថ្វាថ្លៃវិសុទ្ធ ទូលទៀនសព្វបាន ចិត្តចាប់ជួបចូល

ទទួលទូន្មាន ព្រះទ័យក្រៀមក្សាន្ត ឥតអន់ចិន្តា ៗ តាំងបួនព្រះអង្គ សោមនស្សត្រេកត្រង់ បដិសណ្ឋាក ទៅមកទៅវិញ ពេកពេញចិន្តា ទៀតទើបព្រះមហា- បុរសថ្កើងថ្កល់ ៗ ឲ្យរៀបប្រាសាទ មាសមួយស្អាងស្អាត ព្រះប្រោសប្រទាន ឲ្យអង្គអភ័យ ព្រះថ្ងៃក្សត្រក្សាន្ត គង់ក្រៀមរួមឋាន ទឹងនាងចន្ទា ៗ ប្រទានព្រះស្នំ ពលលៀងចាស់ទុំ អាមាត្យសេនា ទើបព្រះបមបក្រ ហៅយក្ខស្វាខ្វា ចូលមកវន្ទា ព្រះបាទបមទៅ ៗ

ត្រាស់ទ្រង់ផ្តាំថា ចូរអ្នកពល់គ្នា ត្រឡប់វិលទៅ កាន់ទីកាន់ឋាន ពិមានលំនៅ សឹងសុខឥតសៅ ទីរនេសទុក្ខា ៗ ស្វាខ្វាអញមត់ ប្រាំមួយខែគត់ ឲ្យផ្លាស់ប្តូរគ្នា នានាំយកឃុំ នូវអំពៅជា ស្ពួយសារសព្វគ្រា កុំឲ្យខកខាន ៗ កុម្ភណ្ឌមត់តែ មួយខែ ១ ឲ្យនាំផលសាន ផ្លែផ្កាឈូកនូវ ក្រនុឈូកមាន ក្រចាប់មកប្តាន អង្គអញពុំធ្លុស ៗ នាអ្នកទីងខាន នៅអាយពុំបាន ដ្បិតជាស្រុកទេស មិនសមអាស្រ័យ សព្វថ្ងៃរនេស សព្វសត្វលេបលស លាយឡំផងគ្នា ៗ មួយសោតគ្មានអ្នកណាទីងរួមរ័ក្ស ស្រះឃុំនៅប្បារ ទីងខូចទីងខាយ អន្តរាយទៅជាព្រះព្រៃព្រឹក្សា សោះសូន្យស្ងប់ស្ងាត់ ៗ

កុម្ភណ្ឌស្វាខ្វា ក្រញ៉ក្រោបលុតលា ទៅឋានវិញថ្កាត់ តែងនាំ

ដង្វាយ មកថ្វាយមហាក្សត្រ តាមព្រះបញ្ញត្ត បន្តាប់ផ្កាផ្លែ ។ (យើង នឹងឈប់ស្មេះ និទានត្រឹមនេះ តែងទុកជារឿង បីបន្ទាប់បួន ពាក្យបួន បន្ទៃ ក្អកប្រាជ្ញប្រាប់ប្រែ (១) ទុកតសាសនា) ។

(ចប់រឿងបីតែប៉ុណ្ណោះ) ។

នឹងនិទានត តំណើតំណ ទំនងរឿងកប ហៅជារឿងបួន ជាប់ដូនដកប ដោយនូវសុភាព កាព្យកិច្ចលោកិយ ។ កាលព្រះពង្សពោ-ធិទត្តមោ លើសលើលោកិយ លាព្រះមាតា ក្សត្រាធិបតី ទៅរកមហេសី ប្រសើរស្មាលស្នេហ៍ ។ សម្តេចពង្សពុទ្ធ ធិពជអង្គ-ទ-ត្តមោតែងតែ គ្រៀមក្សាន្តសោយសុខ នីទុក្ខឡើយរឿង ក៏ក្សេពជ-រដ្ឋ ប្រមាណខែបី ។ ទើបអស់ព្រាហ្មណ៍ព្រឹទ្ធ ព្រាហ្មណ៍បុរោហិត មាត្យមុខមន្ត្រី ជួបជុំគ្នា ឲ្យសារសេចក្តី ទៅយកបុត្រី ក្សត្រយឯកអង្គ ។ ព្រាហ្មណ៍រើសលក្ខណា បានមួយគូជា មហេសីរវង្ស ទូលពុទ្ធង្កូរ ថាបូលព្រះអង្គ ទទួលរាជ្យទ្រង់ ស្លាប់ស្នងបិតា ។ យើងរើសក្សត្រី បានមួយជាស្រី ប្រកបលក្ខណា លើសនាងទាំងឡាយ នឹងថ្វាយជាតិជា ឯកអគ្គជាយា ព្រះបាទនរបតី ។

ពោធិចមទៅ យាងយាត្រាទៅ ទតរូបក្សត្រី ទាំងអស់អង្គប្រាណ

---

១ ដល់ចប់រឿងបី មិនរាប់ចុងដួនតទៅក្នុងរឿងបួនទេ ។

ពុំមានរបតី ត្រាស់កាន់មន្ត្រី ថាអស់ធីតា ៗ សឹងល្អស័ក្តិសម មែន-តែពិតពុំ បុះព្រួផងគ្នា ខ្ញុំពុំគន់គិត ចាប់ចិត្តស្នេហា ខ្ញុំនឹងសុំលា ទៅរកខ្ទនខ្ញុំ ៗ ឯអស់ក្សត្រី ប្ញូរអស់សេនី សេនាជាធំ ឲ្យវិលវឹងទៅ លំនៅជួបជុំ ញាតិសាច់នឹងផ្សំឲ្យមានប្តីសី ៗ

មន្ត្រីបានស្តាប់ ទទួលបង្គាប់ បង្គំនរបតី ចាត់តាមបណ្តាំ ឲ្យនាំក្សត្រី វិលទៅបុរី ទីទៃពល់គ្នា ៗ ស្រេចក្សត្រឧត្តម ចរចូលបង្គំ ព្រះវរមាតា ទូលថាអញខ្ញុំ សូមសុំក្រាបលា ទៅរកពនិតា នគរដទៃ ៗ ក្រែងមានស្ត្រីណា ប្រកបលក្ខណ៍ជា ស្ត្រីរត្នថាថៃ្ង កើតនៅនាក្នុង កំឡុងភពត្រៃ ជាតិជានិស្ស័យ គួរគូផងគ្នា ៗ ខ្ញុំនឹងនាំយក នូវនាងនោះមក អភិសេកឡើងជា ឯកអគ្គទេពី មួយនីវង្សា ដៀតខ្ញុំលាគលា ខ្ញុំសូមផ្ញើនៅ ៗ

នាងស្តាប់បុត្រា បន្ទូលខាំងយាត់ កូនអើយកុំយៅ ចាកចេញចោលម្តាយ ទៅឆ្ងាយឡើយពៅ អាសូរម្តាយទៅ ដ្បិតម្តាយចាស់ហើយ ៗ មួយសោតស្រុកយើង នគរថ្កុំថ្កើង ព្រលឹងមាសអើយ បើចោះចូរចៅ រកនៅអាយហើយ កុំអ្នកទៅឡើយ អាសូរម្តាយក៏ ៗ

បពិត្រស្រុកអាយ ពោះដិតពោះឆ្ងាយ មានមែនតែថា ពុំត្រូវចិត្តខ្ញុំ ខ្ញុំសូមក្រាបលា ទៅរកស្រីជា គួរគូប្រដិពទ្ធ ៗ សូមទ្រង់បើកខ្ញុំ

ឲ្យបានទៅកុំ  បីបន្ទូលឃាត់  នាងនាថស្តែងស្តាប់  សារសព្ទបុត្រក្ន
ពុំអាចទាំងឃាត់ ព្រមតាមចិន្តា ។

ពន្លកសារពេជ្រ លាកលាស្រោប់ស្រេច ស្តែងស្តេចលីលា វិលវឹង
រាជឋាន ពិមានថ្លៃថ្លា ឲ្យអស់សេនា រៀបរាជអស្សពង្ស ។ ស្រេច
ព្រះទេវន្ទ ព្រះករគាន់ខាន់ ពិសេសទ្រើសទ្រង់ គ្រប់គ្រឿងប្រដាប់
បម្រាប់អស់អគ្គ គ្រចះគ្រចង់ យាត្រាចេញចរ ។ ហើយក្សត្រថ្កល់
ថ្កឹង ស្តេចស្ទុះផែលឡើង លើអគ្គអស្សតរ រូបដូចមហាព្រហ្ម
ស័ក្តិសមសន្ធរ ផ្ទះផ្ទាក់លែងអមរ មណ្ឌលសួគ៌ា ។ ហោះឯអាកាស
ក្ដៃផ្ដែកចុះផ្លាស មើលម្តងដូចជា ព្រះឥន្ទ្រព្រះអគ្គ ស្តេចគង់អស្សពាហ៍
មើលម្តងគណនា សុវណ្ណហង្សហោរ ។

ពស្ត្រទាសស្តេចស្តែង យង់យល់ស្ងប់ស្ងែង ក្សត្រក្សាន្តប្រសើរ
ហេតុព្រះពង្សពុទ្ធ ជាម្កុដលើសលើ ក្សត្រផងឥតបើ ទឹងប្រៀបទបមា ។
អស់ព្រាហ្មណ៍គរី ព្រាហ្មណ៍ព្រិទ្ធមន្ត្រី ទាំងពីរអនុជា នូវអស់ព្រះស្នំ
ចាស់ទុំស្រីផ្កា ទាំងនាងវិមលា បំរើនពរបុត្រ ។ សូមព្រះអង្គឥន្ទ្រ
សហាស្សចក្ខុន្ទ្រ ព្រហ្មព្រឹទ្ធវិសុទ្ធ វិសេសថ្លៃថ្លា ទេវតាទេវបុត្រ យក្ខ
យង់ក្រុងគ្រុឌ នាគានាគី ។ មួយម៉ឺនចក្រវាឡ ទាំងទេពបាដាល
ដលសាគរណី សូមជួយបំបាត់ ជម្ងាត់ព្យាធិ បំរើនវុឌ្ឍិ-សេសសម-

ពណ្ណរាយ ៗ ឲ្យប្រកបរិទ្ធិ ប្រសើរប្រសិទ្ធិ លែងលោកសម្តាយ ប្រាស
លែងទុក្ខា ភយាចាំងឡាយ សត្រូវពាយឆាយ វិនាសដោយបុណ្យ ៗ

គោធិពន្ធក ហៀរហោះរេក ក្សត្រីវត្ថុគន់ ប្រកបលក្ខណ៍គ្រប់
សុះសព្វតំបន់ ពុំមានជួរជន បទបាតកុងក្រៅ ៗ លំហើយលំហែ
ហោះហួសទ្វារ នៃពដហានទៅ ហុកសិបយោជន៍គត់ មហាក្សត្រចោម
ទៅ ដល់ទីលំនៅ ឥសីសិល្បសាស្ត្រ ៗ ព្រះនាមថ្វាថៃ ឈ្មោះអស-
ន្ធ្វើយ្យ ឥសីស្មឹងស្មាធិ បំរើនបតុពេទ សាស្ត្រពុទ្ធបាទ សម្តេចមុនីនាថ
វិសេសប្រសើរ ៗ ទ្រើសទ្រង់ជដា ពាសពាក់ស្បែកខ្លា ទន់ល្អិតធ្វើ
បរិយាលែះផ្កាំ ស្លៀកសំបកឈើ អំពលអំពើ ពិធីគុណការ ៗ
អស់អញលំគេញ គាវនាបំពេញ ព្រឹទ្ធព្រត្តពិស្ដារ បំរើនវេជ ព្រះធមិ
សម្មា មានពុកបក្កា ដុះជាសក់សវែង ៗ ព្រះការណិយុរយារ គន្គ
ឥតទន្តា មើលទៅគួរស្ញែង ក្សត្រក្សន្តទសពល យង់យល់ជាក់ស្តែង
ព្រះឱ្យបថ្វាថ្ងៃ ឪងពាដីថា ៗ បងអើយដ្បិតបាន អាស្រមវិហាន
ឥសិសីលា ចូរបងចុះទៅ យើងនៅខមស្សការ ប្រតិស្ឋានជា កុសល
ផលបុណ្យ ៗ យើងនៅសួរសាន រកស្រីកល្យា-ណីនៅតំបន់ ដ្បិត
លោកមែនមាន ព្រះញាណទិព្វគន់ ឯងអាចគួរគន់ សុះសព្វសួគ៌ព្រហ្ម
សេះទន្ទាបទៅ ស្ដេចទុកសេះនៅ នាក្រៅអាស្រម ស្រេចទើបគោធិ-

សត្វវិសេសសម បរបូលបន្គំ ឥសីសិល្បសេយ្យ ។

ឥសិយង់យល់ ពោធិថ្កើងថ្កល់ លើសលោកកពត្រៃ ស្គាល់ជាក់ ជាតិជា ក្សត្រាមហាថ្ងៃ នៃក្សត្រទ្រង់ស័ក្តិ ប្រុសប្រាជ្ញញាណៈញ្ញយ្យ ពង្ស ពោធិសត្វ ។ គយគ្រប់នរលក្ខណ៍ ត្រិះត្រេកអរក្អាត់ ដូចអ្នកមួយប្រាណ មែនមានតម្កាត់ ហើយហៀបនៅបាត់ ជីវិតមរណា ។ យល់ព្រះដូច យល់ ទិព្វពេទ្យមកដល់ យកទុសថា មកប្រោសមកប្រស់ រួចរស់ ជន្មា ឥសីគិតថា បាបអញប៉ុន្នាន ។ ពីដើមអញធ្វើ នូវកម្មកំពើ ពិត ពុំកល្យាណ ពន្ទុកក្រៃក្រាស់ គេជះអញបាន ប្រសព្វក្សត្រក្សាន្ត ពុទ្ធ· ង្កូវថ្ងៃ ។ អស់បាបទាំងនោះ ទើងបានល្ហោះ រគ្គោះក្សណក្ស័យ អង្គអញ សោតទើង បានពឹងដេស្ចជ័យ នាំជាក់ដល់ញ បរមនិព្វាន ។ ទើបសួរ ទៅថា មហាពជយាត្រា តែទីងអស្សយាន លះលែងស្នេងស្នេះ លំ នៅពជឋាន មកតើមោះមាន ប្រាថ្នាកស្តុអ្វី ។

ពោធិស្តេចស្តែង តំណើរថ្មៅថ្មែង អស់អាថ៌សេចក្តី ដើមក្សត្រ ពន្ទុក ទៅរកមហេសី ចង់ជួបក្សត្រី គូគាប់បូរាណ ។ បរបូលបង្គំ ប្រយោជន៍នៅសូម ពឹងព្រះពុទ្ធញាណ រំរេកបូរី ស្រុកស្រីកល្យា· ណីៈនោះទើងបាន បរិបូណ៌បំណង ។

ឥសីស្តេចស្តាប់ ព្រះសូរសារស័ព្ទ ឆ្លាសឆ្លើយថ្លែងស្នង កុំព្រួយអាត្មា

ឆានាពីប៉ាន់ ណែះណែនេះម្ដង ឲ្យបរិបូណ៌បាន ។ តែបួរអ្នកផ្ដុំ អាស្រ័យអាស្រម សម្រាកសម្រាន្ត សម្រេចសម្រស់ ភោជន៍កស្ដ ព្រឹក្សាន ប្រសើរសើងមាន រសជាតិពិសា ។ បួរអ្នកទៅស្រង់ ជម្រះ អស់អង្គ ទឹកនៃអាត្មា មាននៅក្នុងតុម្ព (១) នានាំយាត្រា គិរិគម្ភីរ (២) ពីជ្រោះប្រកក្ដិ ។

ពោធិបង្ហាប់ហ្វាស់ ឆ្លើយថាអរណាស់ អរនឹងអង្គអ-ម្ចាស់ប្រោស ស្មុគ្រស្មោះ គឺមោះអញខ្ញុំ ប្រគេនវិញសុំ នូវមគ្គផលា ។ ក្សត្រនូវឥសី សំណោះមេត្រី សំណាលសន្ទនា សួរសព្វទុក្ខសោក នូវភោគភយា សួរសព្វនានា ទីទេសក្រុងត្រៃ ។ ព្រះមុនីនាថនោះ បានជានាមឈ្មោះ ហៅអសន្ធេយ្យ ព្រោះព្រះជន្មា ទីយាវែងក្រៃ តែមកនៅព្រៃ សាងសីល ភាវនា ។ អសន្ធេយ្យគិត នៅទៀតទោះឥត បើកបញ្ចុបមា ពោធិទត្តម ស្ដេចផ្ទុំនៅនា ឥសីសីលា ប្រមាណបីថ្ងៃ ។

ឥសីសិល្បសាស្ត្រ ការនាស្និទ្ធស្នាធ៌ ធៈកក្សត្រី វិសេសសួស្ដីសល់ កបកល្យាណ៍ ទើបព្រះឥសី ប្រាប់ពោធិថា ។ អាត្មាយន់យល់ បូរាណ មណ្ឌល បូរីនាមា កោសេយ្យនគរ នាមករក្សត្រា បវរសេដ្ឋា យសវតី ។ រីព្រះពនិតា ទ្រង់នាមបទុមា ពីរពង្សអង្គឥ សួរសួស្ដីស័ក្តិសម បរមជាតិ

១ សៀមប្រែថា (ពាង) ។ ២ ជ្រោះភ្នំមានជម្រៅនៅភ្នំ ។

ឥតមានអរិ[១] ណាទីផពះពា ៗ សេពះសាយកាផ្សបិត ដោយធម៌វសពិធ

មនោសេដ្ឋោ ឯងអាចបន្ទោរ អោសោមោហា ខន្តីសច្ចា ដូចព្រះ

អរហន្ត ៗ ពីរពង្សសោកសុទ្ធ កបកើតកាជបុត្រ ឯកអគ្គសោភ័ណ ទ្រ

ទ្រង់រូបា ឆាយានីរម និលទិព្វបេ្រ ទេវ័យជ្រះថ្លា ៗ ទ្រង់នាមករ សុវណ្ណ-

កេសរ ប្រកបលក្ខណា អង្គឥតថៃងថីង វុត្តិងព្រាការ នាងនាថថៃថ្ថា ផា

ឆ្មើមប្ញី ៗ នាងមានប្រាជ្ញា ដោះសាប្រស្នា អាថិអត្ថអ៊ីៗ ឆ្ញៀវឈ្លាស

ឆ្លាសឆ្ងះ ប្រាជ្ញប្រុះប្រុតី ពលពាន់ពេកពី សេសសុះសព្វសារ ៗ នាង

នោះថ្វាថ្វៃង លៃងស្រីគពព្រៃ ទីងយកស្រីណា ស្មោះស្មើត្រៀបត្រឹម

មកផ្ទឹមទបមា ឲ្យល្អដូចជា ក្សត្រីពុំបាន ៗ នាងនាថប្រុះប្រា-កដកន្ស្រ-

សារ-ពេជ្រញោធញ្ញាណ វិសេសពុញ្ញា ជាគួបូពណ បរមជាតិបាន សាងទីង

ព្រះអង្គ ៗ រីពជសីមា ឥស្សូរសុខា ក្សត្រថ្វៃវង្ស អធិកពិស្ដារ ធិការ

កិម ផ្គបគាប់ទគ្គុង ទគ្គមទគ្គលា ៗ នៅខាងខេត្តខែម ខែត្រខណ្ឌព្រះ

ហេម-ពាន្តខាងទក្ខព បន្ទាយដ៏វ៉ិល ប្រាំពីរជាន់មហា-ទីឃោរដោយព្យារ

សីងមានមណ្ឌប ៗ គូគោកច្ចាក់ច្ឆល់ ឥតដលមានដល ពិចិត្រគ្រៀ

គ្រប់ ផ្កាព័ន្ធផ្កាពៃង ខាត់ខ្វែងប្រសព្វ ប្រសើរសឹងអ-ក្ររម្យគួរខ្លាច ៗ

ស្រូតុបរិ ក័ណ្ឌសីធន្តរ ពន្ធសុមេរុពេជ ប្រាសាទរចនា ប្រាំប្រការស្ងាប

---

១ បាលី: ប្រែថា សឹកសត្រូវមកពីពាក្យថា អរិ

ចំណែងចិញ្ចាច រត្នៈខណ្ឌ ៗ មាសមែលៀងលែម កាត់កែវកាល់ កែម កញ្ចក់កញ្ចាន់ កញ្ចុំគ្រោងគ្រោយ ត្រកួយតាប់តាន់ គន់ទិព្វសុវណ្ណ វិពេចន៍រង្សីបទុមពគរត្ន ហៅមហាមារកត ទាទិព្វស្រស់ស្រី ពិទាយពិទូរ្យ បុស្សរាជាត្រី ពេជ្រពិតពីសី ពិសេសឆ្ពះឆ្ពាស់ ៗ សូរកានមហានិល ឥន្ទនូទឹករិល ពពាលប្រាលប្រាស នូវពជនពរត្ន លោហិតឆ្គជាស មំសំ អកិកាស ដំរៀបរេខា ៗ ត្រីសូរស្រោងស្រឹង ត្រែដេតត្រដឹង ឆើត ឆាយឆាយា គាងឃ្វាយដកគាំ បទុមមាលា ខែនកែវរចនា ពិមានមាស ផូង ៗ ក្រិលៀពនពន្ធ ខ្វាត់ខ្វែងឆ្វាយឆ្វាត់ មាសមែបំទបង់ នេត្រនៃ រូបស ទងស្រស់រហង់ លូតលេចពីក្នុង ក្បែបក្បាយក្តិកក្តក់ ៗ ពញូមឡេ ឡៅ រុងរឿងធ្ពុះឆ្ពៅ លេងស្មើស្រក មាសមែកែវកល់ កមល់ខែនទុក ប្រាង្គប្រាសាទសុខ មន្ទីរឆ្ពៅឆ្ពាក់ ៗ គ្រែគ្រប់ទ្រទ្រង់ ទ្រនាប់ទ្រនង់ នូវរូបពងយក្ស បង្ហួមបក្ខា ហើយហារជៀងជាក់ ខាស់ខែងរិទ្ធីស័ក្តិ រូបស វិញ្ញាណ ៗ ក្តិកសីទៀយហ៊ាក់ សង់ខាងកំជក់ ក្រោមព្រះពិមាន ពួក ខ្ពស់ព្រៃព្រាំ ជៀមចំមាសមាន ស័ក្តិសម្បូហាន ទិព្វទេសសេយ្យនាប ទ្រៃត្រ សន្ធិសម តន្ត្រីតូរ្យជំ បំរើកដាំ សម្រាប់ប្រៀងប្រូច គ្រលួចសព្ទសា សូរ សោតសមគ្នា ក្តលេចល្ហែងល្ហើយ ៗ អនេកមន្ទក្ស ត្រសៀតត្រសាក់ ព្រះពាយរំភើយ ស្រះត្រកត្រេប កាព្យគិច្ចឆ្ពាស់ឆ្ពើយ ស្តេចតែងលំ

ហើយ លំហែហឫទ័យ ៗ ស្ដែងស្ដេចប្រដាប់ឧទ្យានសម្រាប់ ព្រះរាជ-បុត្រថ្ងៃ បើនាងកល្យាណ ពុំក្សាន្តព្រះទ័យ តែងនាំសាវង័យ ទៅលេង-សព្វគ្រា ៗ មានស្រះកៀមក្សាន្ត ដូចនន្ទឧទ្យាន សម្ដេចឥន្ទ្រា មានតាស់ពីរនាក់ ពីកក្ដិក្សោ ដូះសម្បែងអា-ស្រ័យក្នុងឧទ្យាន ៗ បើព្រះអង្គទៅ ចូលសំណាក់នៅ នឹងតាស់ពីរប្រាណ ពិតពុំលន់លង់ ព្រះអង្គនឹងបាន នៃនាងកល្យាណ ដូចក្ដីប្រាថ្នា ៗ

ព្រះពោធិសត្វ ឮនាមប្អូនភ្ន ដល់ព្រកាំម៉ា ព្រឺព្រួចដួចយង់ យល់អង្គធីតា ក្ដួចកើតស្នេហា ហេតុគួបពាណ ៗ ទើបមហាក្សត្រា ក្រាបទូលមហា ឥសីរញ្ញាណ សូមព្រះករុណា មេត្តាប្រោសប្រាណ ជន្យានាងបាន ប៉ុន្មានវស្សា ៗ

ឥសីផ្ទាស់ឆ្លើយ ថាមហារាជអើយ នាងនោះដន្ទា ចួបចូលសោឡស ស្រៀបស្រស់អស់ការ អាពាហ៍ពិពាហ៍ មង្គលថ្កើងថ្កាន ៗ

ពោធិសួរថា បពិត្រអ្នកតា មគ៌ាដែនដាន ទៅដល់កោះសេយ្យវិជ័យកដ្ឋាន ចម្ងាយប៉ុន្មាន យោជន៍យាត្រាដល់ ៗ

ឥសីឆ្លើយថា បពិត្រព្រះមហា រាជមណ្ឌល ពីនេះទៅឆ្ពះកោះសេយ្យស្រុកសល់ សាមសិបយោជន៍ដល់ ជាជិតល្មមទេ ៗ

ពោធិ៍ឆ្លើយថា បពិត្រអ្នកតា ខ្ញុំនឹងទៅតែ រំពេចឲ្យដល់ មណ្ឌលរដ្ឋ អាគុណឥតឯ គេអ៊ុំផ្ទឹមគ្នា ៗ

ឥសីឆ្លើយខាន់ អ្នកកុំអាលទាន់ ពេលាពុំបាន ដ្បិតមានយក្ខស្រី អប្រិយ៍សាមាន្យ នៅកណ្ដាលឋាន មគ្គាដែលទៅ ៗ ហួសពីនោះ ទីង បានដល់ដងស្ទឹង មួយមានទឹកជ្រៅ ក្រពើត្រីផង យង់ឃ្នងយោរយៅ សឹងសំណាក់នៅ នាស្ទឹងនោះណា ៗ ត្រីមួយជាប្បង លើសលើត្រីផង ហៅមហាលោមា មនុស្សម្នាណាចុះ ស្ទឹងនោះគាលណា ក្បៀណក្បៀ ជន្ទា ពុំដែលរួចរស់ ៗ បានជាអាហារ។ ត្រីនោះកោក្តា ក្នុងស្ទឹង ទាំងអស់ បើដល់គុំបី ក្សត្រៃថ្ងៃទ្រង់យស ចុះស្រង់សម្រស់ សម្រាក កាយា ៗ ថាបើព្រះអង្គ បង់បរចុះស្រង់ ប្ដូរៀនចិន្តា-មណីព្រះមន្ត ទិព្វ គន់អាត្មា ថ្វាយមហាក្សត្រា ស្មើពលទាហាន ៗ នរអ្នកណា មោះ មកពាំងា បៀតបៀនក្សត្រក្សាន្ត ស្ងូត្រស្រែកព្រះមន្ត ទិព្វគន់ថ្កើងថ្កាន ប្រែប្រែបប្រោសប្រាណ ជាមិត្រស្នេហា ៗ ហួសពីស្ទឹងទៅ នោះ ឥតអ៊ីទៅ ខាន់ខាំងមគ្គា កេ្រមក្សាន្តសប្បាយ លោះលាយព្រឹក្សា លង់ លុះប្ដូរ ប្ដូណាគោសេយ្យ ៗ

ពោធិសោភ័ណ ស្ដេចស្ដូមរៀនមន្ត ហេតុប្រាជ្ញញាណញ្ញេយ្យ ព្រះ ញាណគ័ត្ថណ ដរ៉ែនវាំងវៃ ព្រះឥសីសេយ្យ ប្រាប់តែម្ដងបាន ៗ ស្ដេច ផ្ដុំត្រអាល ឯករាត្រីកាល លុះព្រឹកក្សត្រក្សាន្ត ចរចូលភ័ក្ត្រ ឥសីវិញ្ញាណ ប្រយោជន៍លាថ្កាន គោសេយ្យនគរ ៗ (មានត)

# រឿងសាមកុក

## កណ្ឌទី ២៩

លោកញ៉ាវិបុលរាជសេនា ង៉ូ-កឹង ប្រែរៀបរៀង

( តមក )

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាស បើបានអាន
> នឹងចេះឧបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

មួយកន្លែងទៀតនោះ ឲ្យលើកទៅតាំពន្ធាយអាហារ ដែលលើកចេញមកពីក្នុងស្រុក ហើយបួនកំប្រមូលពលអាហារបំរុងទុក តាមពាក្យដែលនិយាយ ។

អ៊ួនស៊ុនលើកទាហានជាកងទ័ព ទៅដល់ទន្លេប៉ែកតុក មើលទៅមិនឃើញទូកស្បៀងបួនសោះ អ៊ួនស៊ុនក៏លើកទ័ពទៅតាំង នៅដំបន់យ៉ុនប៉េនវិញ ផ្លូវដិតស្រុកគីជីវប្រហែល ២០០ សិន ( ៨ គ ) ហើយបង្គាប់ទាហានឲ្យទៅជញ្ជូនយកចំបើង នឹងស្មៅមកគរទុកជាច្រើន ប្រាប់ថានឹងដុតភ្លើងឲ្យឆេះឡើង ដើម្បីឲ្យសឹមដោយឃើញជាសំគាល់ នឹងបានលើក

ទាហានជួយខ្ទប់កងទ័ពបួនចេញមក ទើបឱ្យលីហ៊ូ តែងខ្ទមបន្ទុំជាទាហានបួនហើយបង្គាប់ថា ឱ្យចូលទៅប្រាប់សីមាដោយថា យើងលើកកងទ័ពមកដល់ទីនេះហើយ បើឃើញពន្លឺភ្លើងដែលយើងដុតឡើងកាលណា ឱ្យលើកទាហានវាយខ្ទប់ចេញមកទទួលយើង ចូលទៅក្នុងស្រុក ៗ លីហ៊ូក៏បន្ទុំធ្វើជាទាហានបួនចូលទៅ ក្នុងស្រុកបាន ហើយប្រាប់សីមាដោយតាមពាក្យដែលអួនសុនបង្គាប់នោះ សីមាដោយបានស្តាប់ដូច្នោះ ក៏ចាត់ចែងទាហានត្រៀមទុកព្រម ៗ លីហ៊ូដឹងថា ស្បៀងអង្ករស្បៀងអាហារក្នុងស្រុកនោះស្ទួចស្តើងហើយ ក៏និយាយនឹងសីមាដោយថា ដែលអួនសុននឹងលើកទ័ពចូលមកតាំងនៅក្នុងស្រុកគឺជាវនេះ ខ្ញុំបានឃើញថា នឹងខ្វះខាតដោយស្បៀងអាហារ ខ្ញុំបាននឹងសុំអោយគេឱ្យអ្នកស្រុកតែចេញទៅ ចុះចូលនៅនឹងបួន មុខជាបួនគាត់ស្មាតើផុសប្រវៃបាសទៅ លោកត្រូវលើកទាហានតាមចេញទៅពោមវាយកងទ័ពបួន ៗ ក៏គង់នឹងបែកទៅដោយងាយមិនខាន សីមាដោយយល់ឃើញត្រូវផង ក៏ឱ្យទាហានយកទង់សមកសរសេរជាអក្សរថា " ឥឡូវអួនសុនមិនបាននៅក្នុងស្រុកទេ អ្នកស្រុកទាំងអស់ព្រមចិត្តគ្នានឹងសុំទៅចំណុះចុះចូលខាងមហាចក្រវិញ " ហើយយកទង់នោះទៅដោតលើសើនបន្ទាយ ៗ បួនឃើញអក្សរក្នុងទង់ដូច្នោះ ក៏និយាយក្នុងទីប្រឹក្សាទាំងពួងថា " ទង់សសរសេរអក្សរដោតលើសើននោះ ព្រោះ

សឹមផោយឃើញថា ស្បៀងអាហារក្នុងស្រុកស្តួចស្តើងណាស់ហើយ ទើបរិះគិតធ្វើឧបាយដូច្នេះ ឲ្យអ្នកស្រុកចេញមកបំណុះបុះបួលយើង ឲ្យយើងទុកចិត្ត ឯខ្លួនសឹមផោយនោះនឹងលើកទាហានចេញមកទ័ព្វវាយកងទ័ពយើង" ប៉ុន្តែក៏ឲ្យទៀវលៀវនឹងស៊ូហ្វាងលើកទាហានម្នាក់ ៣ ពាន់ ទៅពួនបង្កប់នៅជើងភ្នំក្បែរកំពែងស្រុក បើឃើញសឹមផោយលើកចេញមកក៏ឲ្យនាំគ្នាព្រួតវាយខ្ទប់ចាប់យកខ្លួនសឹមផោយឲ្យបាន ហើយប៉ុន្តែក៏ពាក់គ្រោះដះសេះបាំងស្បួច នាំទាហានទៅជិតជើងកំពែងស្រុក ប្រាថ្នាចាំច្បាំងនឹងសឹមផោយ ឯទាហានស្រុកនោះក៏បិទជិត ទទួលក្រឡេកមើលទៅឃើញអ្នកស្រុកដែលចាស់ជរាកាន់ឈើច្រត់ នឹងធូបទៀនផ្កាភ្ញីចេញមកជាច្រើនហើយឃើញសឹមផោយលើកទាហានតាមមកទៀត ប៉ុន្តែក៏ឲ្យបោកទង់ក្រហម ៣ ដង ៗ

ឯទៀវលៀវនឹងស៊ូហ្វាងឃើញដូច្នោះ ក៏លើកទាហានដែលបង្កប់នោះចេញមកវាយខ្ទប់ចាំងសង្កាន់ ការសម្លាប់ទាហានសឹមផោយនឹងពួកអ្នកស្រុកស្លាប់ជាច្រើនមិនដឹងរាប់ សឹមផោយយល់ឃើញថានឹងតស៊ូពុំបានក៏នាំទាហានថយចូលស្រុកវិញ ៗ ប៉ុន្តែឃើញទាហានស្រុកបើកបិទក៏បរសេះចូលទៅជិតជើងកំពែងស្រុក ប្រាថ្នានឹងដេញទាហានទាំងនោះឲ្យច្បាំងទំលាយចូលទៅក្នុងស្រុកឲ្យបាន នោះទាហានដែលនៅលើសើនក៏តៃដគ្នាជាពន្លឺកហើយបាញ់ធ្នូសំដៅ ព្រួញធ្លាក់ទៅត្រូវមួកបធ្ទុះហូតទៅ ៗ

# កណ្ឌទី ៣០

**កាំងពីទាហានចូឆូវាយបន្ទាយអួនសុងបែករត់ទៅ**

**ចូឆូយកបានស្រុកគីជីវ សម្លាប់សឹមផោយ**

**នឹងកោហ៊ុំ ហើយលើកតាមអួនថាំទៅស្រុកឡាំភី**

**រហូតដល់ចូឆូប្រឹក្សានឹងលើកទៅវាយឡៅប៉ៀវ ។**

---

បណ្ដាទាហានទាំងពួងក៏ភ័យស្លុតចិត្តគិតថា ចូឆូត្រូវព្រួញ ក៏នាំគ្នាចូលទៅបោមរោមហើយនាំចូឆូចូលទៅក្នុងបន្ទាយ ចូឆូក៏ចាត់ចែងទាហានលើកទៅវាយបន្ទាយអួនសុង ៗ ដឹងហើយក៏លើកទាហានចេញមកច្បាំងនឹងកងទ័ពចូឆូជាពន្លឹក ។ អួនសុងខូចខាតទាហានច្រើនណាស់ឃើញថានឹងទ្រាំតទៅមិនបាន ក៏នាំទាហានដែលសល់នៅទាំងប៉ុន្មាននោះ លើករត់ទៅកាំងបន្ទាយនៅក្នុងសានលិច ហើយឲ្យបំរើសេះស្រួតទៅហៅម៉ា-អៀននឹងទៀវយើមក ។

ខណៈនោះ មានបំរើសេះម្នាក់មកប្រាប់ចូឆូថា អួនសុងលើកកងទ័ពចេញពីស្រុកពេងង្ងួនគួនទៅហើយ ៗ ចូឆូប្រើលីកង លីសៀង ទៅបញ្ចុះបញ្ចូលម៉ាអៀននឹងទៀវយើបានមក ហើយឲ្យធ្វើជានាយទាហាន ៗ កាលថ្ងៃដែលសុំមកដោយចេញមកនោះ លុះដល់ពេលយប់ស្ងាត់ ចូឆូក៏ឲ្យ

លីកង, លីសៀង, ម៉ាអៀន, ទៀវយើ, លើកទាហានទៅប្លន់បន្ទាយអ្នងស៊ុងៗមិនទាន់ដឹងខ្លួន ក៏ខូចខាតទាហានជាច្រើន ទើបថយទៅតាំងនៅក្នុទិសខាងលិច ចម្ងាយពីស្រុកប្រហែល ៤០០ ស៊ិន(១៦គ )អ្នងស៊ុងឃើញទាហានរបស់ខ្លួនស្លាប់ស្ទើង បែកខ្ញែកគ្នាដូច្នោះ ក៏ឲ្យសឹមអេងទៅជំពបប៊ូធូថាយើងនឹងសូមមកចំណុះចុះចូល ធ្វើការរាជការ ជាមួយនឹងមហា· ខបពជផង ៗ សឹមអេងក៏ចូលទៅគេប៊ូធូ ហើយអធិប្បាយសេចក្ដី តាមពាក្យដែលអ្នងស៊ុងបង្គាប់ ៗ

ប៊ូធូបានស្ដាប់ដូច្នោះហើយក៏គិតថា " អ្នងស៊ុងដែលនឹងមកចំណុះចុះចូលយើងនេះ ព្រោះអស់ជំរម្រះប្រាជ្ញា បើយើងនឹងរក្សាទុកក៏មិនបាន តែត្រូវទទួលតាមពាក្យចុះ តទៅមុខសឹមគិតសម្លាប់បញ្ចេញឲ្យបាន " ប៊ូធូគិតហើយក៏ឆ្លើយទៅសឹមអេងថា ដែលអ្នងស៊ុងចូលមកចំណុះយើង ព្រមធ្វើរាជការផង ក៏តាមចិត្តចុះ ៗ សឹមអេងក៏លាប៊ូធូត្រឡប់ទៅប្រាប់អ្នងស៊ុងវិញថា ប៊ូធូព្រមទទួលហើយ ៗ

លុះពេលព្រលប់ ប៊ូធូក៏ប្រើទៀវលៀវនឹងស៊ីហ៊ុងឲ្យលើកទាហានទៅវាយបន្ទាយអ្នងស៊ុង ទៀវលៀវនឹងស៊ីហ៊ុងលើកទាហានទៅជិតបន្ទាយប្រហែលជាយាម ៣ ប៉ាយ ក៏លើកចូលទៅវាយទំលាយបន្ទាយអ្នងស៊ុង ខណៈនោះ អ្នងស៊ុងមិនដឹងខ្លួន ក៏ខូចខាតទាហានជាច្រើន ពោលគ្រា

សម្រាប់នាំរទឹងរបស់ទ្រព្យទាំងអស់ នាំទាហានដែលសល់នៅទាំងប៉ុន្មាន នោះ រត់ចូលក្នុងទៅ ទៀវលៀវនឹងស៊ុយហ៊ុង ក៏រើសយកគ្រានឹងរបស់ទ្រព្យ ទៅឲ្យប៊ូឆូ ហើយពណ៌នារឿងរ៉ាវ ឲ្យប៊ូឆូស្តាប់គ្រប់ប្រការ ។

ប៊ូឆូលុះដឹងច្បាស់ដូច្នោះ ក៏មានអំណរសាទរណាស់ ទើបលើកកងទ័ព ទៅព័ទ្ធស្រុកគីជីវ ។ ទៅហ៊ីវនិយាយនឹងប៊ូឆូថា ហេតុម្តេចបានជាលោក មកធ្វើសង្គ្រាម បង្អែបង្អង់នៅដូច្នេះ មិនគួរសោះ សូមឲ្យលោកលើកទា-ហានជីកព្រែកបង្ហូរទឹក ឲ្យចូលមកក្នុងកំពែងស្រុក ទឹកក៏គង់ហូរមក តាមព្រែកចូលទៅលិចស្រុក មនុស្សទាំងឡាយក៏នឹងលង់លិចស្លាប់ពុំខាន លោកក៏នឹងបានស្រុកគីជីវ ដោយងាយ ។ ប៊ូឆូយល់ឃើញថាត្រូវ ក៏កេណ្ឌទាហានឲ្យធ្វើទំនប់ទប់ទន្លេជៀងហោទុក ហើយឲ្យជីកព្រែកមួយ ពីមាត់ទន្លេជៀងហោ កាត់តម្រង់ទៅស្រុកគីជីវ ចម្ងាយផ្លូវប្រហែលជា ៤០០ សិន (១៦គ.) ។

ឯសីមាជាយនៅលើសើនបន្ទាយ ឃើញប៊ូឆូត្រឡប់មកធ្វើការជីកព្រែក ដូច្នោះ ក៏សើចហើយនិយាយនឹងទាហានទាំងពួងថា គំនិតប៊ូឆូគិតធ្វើការ ដូច្នេះ យើងមិនខ្លាចសោះឡើយ យើងខ្លាចតែជីកព្រែកនោះឲ្យជ្រៅ ទើបបង្ហូរទឹកចូលមកឲ្យលិចស្រុកយើងបាន ។ សីមាជាយឃើញថាប៊ូឆូនឹង ធ្វើការនោះមិនកើតឡើយ ទើបមិនបានគិតការពារប្រការដូចម្តេចសោះ ។

ឯចូដ្ឋមិនបានឃើញពួកអ្នកស្រុកគិតធ្វើការពារអ្វីសោះ ក៏ឃើញបានចំណាប់ផ្ទួចគំនិតគិត លុះវេលាយប់ក៏ប្រមូលពលទាហានឲ្យទៅចូលគ្នាជីកព្រែកទំហំ ៤ ព្យាម ជំរៅ ៤ ព្យាម (៨ ម.) ឲ្យហើយស្រេចតែក្នុងពេលយប់នោះ ទាហានទាំងអស់ក៏ជួយគ្នាប្រមុះធ្វើការជីកព្រែក ទំហំនឹងជំរៅ ៤ ព្យាម (៨ ម.) ហើយស្រេច រួចក៏បើកទំនប់ក្នុងពេលយប់នោះ ទឹកក៏បាក់ហូរចុះទៅក្នុងគូពេញព្រៀប ហើយហូរចូលទៅតាមព្រែកជីកក្នុងស្រុកនោះ ជាច្រើនអន្លង់គ្រប់ដំបន់ ទើបលិចពេញស្រុកជម្រៅទឹកប្រ-ហែល ៧-៨ ហត្ថ បណ្ដាជននឹងពួកទាហានទាំងពួង ក៏ទញខ្លះខាតដោយស្បៀងអាហារ ស្លាប់ដោយលង់ទឹកខ្លះៗ ក៏គេឡើងទៅលើសេនបន្ទាយ ។

ឯស៊ុនគីកំរើសយកបានត្រាសម្រាប់ងារនឹងមួក និងគ្រឿងប្រដាប់តែងខ្លួនរបស់អ្នកស៊ុន ដែលបានទុកចោលក្នុងបន្ទាយនោះ ស៊ុនគីកំរើសយកពាក់ទៅលើចុងឈើ លើកឡើងគ្រវីស្រែកប្រាប់បណ្ដាជនទាំងពួងថា ឥឡូវនេះ មហាទបពជសម្លាប់អ្នកស៊ុនចេញហើយ អ្នកណាល់គ្នានឹងទៅស្បៀមធ្វើអី ឲ្យដល់ខ្លួនសេចក្ដីស្លាប់ ចូរនាំគ្នាត្រឡប់មកបំណុះចុះចូលនៅខឹងមហាទបពុជចុះ ទើបនឹងរស់រួចជីវិតតទៅ ។ សមដោយបានព្រស៊ុនគីស្រែក ប្រកាសដូច្នោះ ក៏ទាំងណាស់បង្គាប់ឲ្យចាប់យកករ យោបុត្រនឹង

បក្ខពួកបងប្អូនស៊ុនគីប្រហែល ៨០ នាក់ ទៅសម្លាប់ចោលទាំងអស់ ហើយយកខ្មោចនោះបោះចេញទៅ ឲ្យស៊ុនគីឃើញ ស៊ុនគីឃើញដូច្នោះ ក៏រន្ធត់ស្លុតចិត្ត ស្រែកទ្រហោយំទួញ អាល័យការិយាបុត្រនឹងបងប្អូនញាតិសន្តានពន់ប្រមាណ ។

ខណៈនោះ សឹមអេងត្រូវជាក្មួយសឹមផោយនោះ ជាគៀនសំឡាញ់នឹងស៊ុនគី កាលបើសឹមអេងឃើញសឹមផោយឲ្យសម្លាប់ការិយាបុត្រញាតិសាច់សាលោហិតស៊ុនគីអស់ហើយ ក៏នឹកខឹងក្តៅក្រហាយខ្លាំងណាស់ ព្រោះសឹមអេងស្រឡាញ់ស៊ុនគីជាច្រើន ទើបសរសេរសំបុត្រជាសេចក្តីថា ខ្ញុំបាទសឹមអេងជាក្មួយសឹមផោយ ជាគៀនសំឡាញ់នឹងស៊ុនគី មានសេចក្តីក្តៅក្រហាយ នឹងសឹមផោយខ្លាំងណាស់ ព្រោះសឹមផោយជាមាខ្ញុំបាទ សម្លាប់ការិយាបុត្រនិងញាតិសាច់សាលោហិតស៊ុនគីអស់ ពេលយប់នេះសូមឲ្យមហាទបរាជ លើកទ័ពចូលមកចុះ ខ្ញុំបាទនឹងបើកទ្វារស្រុកចាំទទួល ហើយយកសំបុត្រនោះចងនឹងព្រួញបាញ់ចេញទៅ ។

ឯស៊ុនគីកាលបើរើសបានសំបុត្រ ក៏យកមកមើលឃើញសេចក្តីច្បាស់ហើយ ក៏មានអំណរណាស់ ទើបនាំយកសំបុត្រនោះទៅឲ្យប៊ួចធូវដឹងសេចក្តីច្បាស់ហើយក៏ឲ្យយកទៅប្រកាសប្រាប់ដល់ទាហានទាំងពួងថា យើងនឹងលើកទ័ពចូលស្រុកក្នុងពេលយាម ៣ ក្នុងយប់នេះ កុំឲ្យនរណាធ្វើទុក

បុកម្មេញពួកសែអួន នឹងពួកដែលសូមចំណុះចុះចូលជាផាច់ខាត បើនរ-ណាមួយ ល្មើសមិនស្តាប់នឹងឲ្យសម្លាប់ជីវិតបង់ ។

លុះពេលជិតភ្លឺ សឹមអេងក៏បើកទ្វារស្រុកខុកតាមសញ្ញា ស៊ីនគីឃើញ ហើយក៏លើកទាហានចូលទៅក្នុងស្រុកគីជីវ សឹមជោយនៅក្បែរគយ ល្បាតសើនបន្ទាយ ខាងទិសឯកើត ឃើញទាហានគងទ័ពចូចូចូលមកក្នុង ស្រុកពីទិសខាងត្បូង ក៏លើកទាហានប្រហែល ៣០ នាក់មកប្រុងនឹងតដៃ នឹងទាហានចូចូ ទទួលប្រទះនឹងស៊ីហ្វាង សឹមជោយក៏បរសេះចូលច្បាំង នឹងស៊ីហ្វាងប្រជាប់គ្នា ស៊ីហ្វាងព្រួតចាប់ខ្លួនសឹមជោយបាន ក៏ចងនាំទៅឲ្យ ចូចូ ស៊ីនគីដឹងដូច្នោះហើយ ក៏បរសេះស្រូតតាមទៅ ដោយអំណាចចិត្ត ដែលខឹងក្តៅពន់ប្រមាណ ក៏យកសែសេះវាយសឹមជោយ ហើយខាំធ្មេញ ជេរថាអាសត្រូវ អាឯងស្លាប់ក្នុងថ្ងៃនេះហើយ ។

សឹមជោយឮដូច្នោះ ក៏ខឹងណាស់ទើបឆ្លើយតបថា អាឯងប្រែចិត្តទៅ ចូលនឹងអាចូចូជាសត្រូវ អញមានចិត្តខឹងចង់ស៊ីសាច់អាឯងទៀត ស៊ីហ្វាង ចំស្រូតនាំខ្លួនសឹមជោយ ទៅឲ្យចូចូក្នុងបន្ទាយ ទើបចូចូសួរសឹមជោយថា នរណាបើកទ្វារស្រុកទទួលទាហានយើង សឹមជោយឮហើយក៏ខឹងណាស់ ទើបនិយាយថា កុំតែអាសត្រូវពីក្នុងឲ្យដៃទៅ សត្រូវក្រៅ កុំអីមិនខូច ស្រុកសោះ ។

ចុចក៏សួរសីមាផោយថា កាលពីថ្ងៃខ្លួនបានធ្វើកលៗបាយឲ្យអ្នកស្រុកចេញមកចុះចូលយើងនោះ យើងជិះសេះបោលទៅជិតជើងកំពែង ទាហាននៅលើសើងយកធ្នូបាញ់បម្រះចុះមកពីណាក៏ច្រើនម៉្លេះ សីមាផោយឆ្លើយថា ខ្លួនជាសត្រូវនាយចៅហ្វាយយើង មានសេចក្តីខឹងគុំគួន នេះត្រូវលើពេលដែលធ្វិចពេក បើប្រសិនជាមានច្រើនទៀតនឹងឲ្យទាហានបាញ់បន្ថែមឲ្យខ្លួនដល់នូវសេចក្តីស្លាប់តែម្តង ។ ចុចតបទៅវិញថា ដែលខ្លួនមានសេចក្តីសត្យកតញ្ញូ នឹងនាយចៅហ្វាយរបស់ខ្លួននោះ យើងពេញចិត្តណាស់ តែវេលានេះ អ្នកសៀវចៅហ្វាយរបស់ខ្លួនស្លាប់បាត់ទៅហើយ ខ្លួនព្រមមកនៅធ្វើការរាជការជាមួយនឹងយើងបួ យើងនឹងចិញ្ចឹមទំនុកបំរុងគទៅ? ។ ស៊ុនភីបានឮចុចថាដូច្នោះ ក៏ឆ្លើយដំរាបទៅវិញថា បុត្រភរិយានិងបក្ខពួករបស់ខ្ញុំបាទជាង ៨០ នាក់ សីមាផោយវាសម្លាប់អស់ហើយ ហើយ សូមឲ្យលោកសម្លាប់វាឲ្យស្លាប់តាមគ្នាទៅ ទើបខ្ញុំបាទនឹងបាត់ខឹង ។ សីមាផោយឆ្លើយតបថា, ឯងកុំមកញុះញង់ថែមថ្មីទៀត អញមិនមែនសោកស្តាយជីវិតទេ ព្រោះខ្លួនអញកើតមកជាមនុស្សកតញ្ញូ គិតតាំងចិត្តថា ធ្វើជាបាវអ្នកណាហើយ ក៏ត្រូវតែទៀងត្រង់នឹងអ្នកនោះ យ៉ាងដូចអញបានមកនៅជាបាវសែអ្នួន ក៏ត្រូវតែស្រឡាញ់ស្មោះត្រង់ដោយសុចរិត ទោះបីខ្លួនអញស្លាប់ទៅទៀត ក៏សូមឲ្យទៅជួបជាបាវសែអ្នួនទៀត

មិនបានគិតទុច្ចរិតដូចខ្លួនឯងក៏ទេ ឯងប្រញាប់ញាប់ចូលឲ្យសម្លាប់អញចេញ ចុះ ៗ ចចកឮដូច្នោះក៏ខឹងណាស់ ទើបបង្គាប់ទាហានឲ្យយកខ្លួនសឹមផោយទៅសម្លាប់ ទាហានទាំងពួងក៏នាំខ្លួនសឹមផោយចេញទៅ ខណៈកាលនឹងលើកដាវទៀងកាប់នោះ សឹមផោយក៏និយាយអង្វរពេជ្ឈឃាតថា ចៅហ្វាយយើងនៅទិសឯជើង សូមឲ្យបង្អង់កុំអាលសម្លាប់សិន យើងសូមបែរមុខទៅកាន់ទិសត្រង់ចៅហ្វាយយើងនៅប្រសិមកាប់ចុះ សឹមផោយក៏ប្រែខ្លួនបែរមុខទៅទិសឧត្តរ ផ្ទៀងចិត្តគិតដល់ចៅហ្វាយនាយ ហើយពេជ្ឈឃាតក៏លើកដាវទៀងកាប់ស្លាប់នៅទីនោះ ៗ

ចចកយល់ឃើញដូច្នោះ ក៏ក្លែងលើកសរសើរសឹមផោយ ប្រាថ្នានឹងឲ្យសេនាទាហានរបស់ខ្លួន មានចិត្តស្និទ្ធភក្តីមេត្រី ស្រឡាញ់ដល់ខ្លួនជាចៅហ្វាយនាយ ហើយថាសឹមផោយនេះជាមនុស្សមានសេចក្តីសត្យកតញ្ញូនឹងនាយចៅហ្វាយណាស់ នរណានឹងធ្វើរាជការគេទៅត្រូវឲ្យយកជាតួយ៉ាងសឹមផោយទុកខ្លួនចុះ ហើយក៏ឲ្យតែងការសពនាំយកទៅកប់តាមទំនៀម ទទួលទាហានចាប់បានខ្លួនតន់លិមនាំមកទៀត ចចកសួរតន់លិមថា ដែលអ្នកសៀវឲ្យខ្លួនតែងសេចក្តីសំបុត្រប៉ះទង់ប្រកាសគ្រប់អាណាខេត្តទាំងអស់ថា យើងធ្វើការទុច្ចរិតអាក្រក់ក្នុងផែនដីនោះក៏ត្រូវមែនហើយ ព្រោះអ្នកសៀវនឹងយើងជាសត្រូវនឹងគ្នា ហេតុក៏បានជាខ្លួនចេះជេរឈាងនិយាយ

កកាយទៅដល់ជីតាបិតាយើងថា គិតប្រទុស្តរ៉ាយក្បត់ផែនដីដោយហេតុអ្វី? តន់លឹមតបថា ដែលខ្ញុំបាទតែងសំបុត្រនោះ ទុបមាដូចអ្នកយកគ្រួផ្គងព្រួញនឹងបាញ់ ត្រូវទាញខ្សែប្រទ្បាះឲ្យតឹងតម្រង់ព្រួញឲ្យត្រង់ ហើយលែងទៅឲ្យត្រូវមនុស្សនឹងសត្វដល់នូវសេចក្តីស្លាប់តែម្តង ។ ទីប្រឹក្សានឹងសេនាទាហានទាំងពួងព្នងដូច្នោះក៏ខឹងណាស់ ទើបនិយាយនឹងចូឆូថា ដែលតន់លឹមនិយាយក៏យរៀងដូច្នេះជាទីប្រមាថមើលងាយខ្លាំងណាស់ សូមឲ្យលោកយកខ្លួនទៅសម្លាប់ចេញ ។ ចូឆូតបថា ដែលតន់លឹមនិយាយនោះ ជាសេចក្តីពិត អ្នកពល់គ្នានឹងប្រកាន់ខឹងឲ្យយើងសម្លាប់ចេញនោះមិនគួរទេ ។ យើងត្រូវចិញ្ចឹមទុកសម្រាប់នឹងឲ្យតែងសំបុត្រនឹងចុតហ្មាយតទៅ ។

ឯហោគីជាបុត្រចូឆូនោះ អាយុបាន ១៨ ឆ្នាំ មានសតិបញ្ញាឆ្លៀវឆ្លាតណាស់ ។ ចូឆូស្រឡាញ់ពេញចិត្តជាច្រើន ទោះបីនឹងលើកកងទ័ពទៅច្បាំងដល់ដែនណា ហោគីក៏ទៅតាមបិតាជាដរាប ។ កាលដែលចូឆូវាយយកបានស្រុកគីជីវនោះ ហោគីជាបុត្ររបស់ចូឆូក៏កាន់គ្រឿងចូលទៅជាមួយនឹងទាហានដល់ទ្វារផ្ទះអួនសៀវ ទាហានហាមឃាត់ហោគីថា មហា-ឧបរាជបានហាមប្រាមទុកថា កុំឲ្យនរណាធ្វើអន្តរាយដល់បុត្រភរិយាញាតិ

(មានត)

# អ្នកគង្វាលចៀមចិត្តស្លូតត្រង់និងព្រះរាជធីតា

លោក ជើង-ជ្រឿវ នៅក្រសួងឃោសនាការជាតិ

ប្រែចាកសៀវភៅ កុងត៍អេឡេសង់ដ៍ ដឺ រេមានី

( តមក )

( Contes et Légendes de Roumanie, )

អ្នកគង្វាលឡើងជិះ ហើយកូនសេះស្ទុះក្ដែកលឿនដូចខ្យល់ ដូចគំនិតដែលនឹក រួចក៏បានដល់ប្រាសាទស្ដេចយក្សក្លាម ។ យក្សចេញទៅលេងព្រៃ ដើម្បីបរបាញ់ទៀត ។

អ្នកគង្វាលចិត្តស្លូតត្រង់ យកនាងកូនយាយព្រះសៅរ៍ឲ្យជិះពីខាងក្រោយ ហើយបរចេញទៅយ៉ាងរហ័ស ។

គ្រានោះ សេះរបស់យក្ស តាំងស្រែកកញ្ជ្រៀវពេញរំពងមាត់ ។

- យើ ! យើ ! សេះយក្ស សេះសិង្ហ ! ឯងមិនទាន់បានផឹក មិនទាន់បានស៊ីទេឬ ? ។

— ខ្ញុំបានផឹក បានស៊ីហើយ ចៅហ្វាយ ។ ប៉ុន្តែចៅហ្វាយស្រីលួចរត់ទៅ ជាមួយនឹងអ្នកគង្វាលទៅទៀតហើយ ។

បើដូច្នោះ តើអញឈប់ស៊ី ឈប់ផឹកសិនផង បានឬទេ ? ។

- មិនបានទេ សូម្បីតែទៀនជិះលើខ្នងខ្ញុំយឺតយូរ ក៏មិនបានផង ។

កាលណោះ ស្តេចយក្សលោតហក់លើខ្នងសេះយ៉ាងរួសរាន់ឥតបង្អង់ ហើយបរចេញលឿនដូចខ្យល់ព្យុះដេញតាមអ្នកគេ ដែលត្រាច់លឿនដូចផ្លេកបន្ទោរ ។ ជនទាំងពីរទៅដាច់បានឆ្ងាយហើយ ។ មិនយូរប៉ុន្មានខ្យល់ដង្ហើមរបស់សេះយក្សក្តៅ ដូចអណ្តាតភ្លើងផ្សាយមកប៉ះខ្នងអ្នកគង្វាល ។ ម៉្លោះហើយគេវាយកូនសេះ ដើម្បីឱ្យខំផាយឡើង ។ ប៉ុន្តែកូនសេះប្រាប់ថា

- ចៅហ្វាយ កុំវាយខ្ញុំ ។ ខ្ញុំនឹងនិយាយប្រាប់បងរបស់ខ្ញុំឱ្យគាត់ទុកឱកាស ដើម្បីឱ្យយើងរត់រួច ។

រួចកូនសេះស្រែកប្រាប់ទៅសេះយក្សថា:

- បពិត្រអ្នកបងសំឡាញ់ សូមអ្នកបងគ្រវែងខ្លួនម្តងទៅ ។

ខណៈនោះ សេះយក្សកាលបើបានឮប្អូនស្រែកប្រាប់ដូច្នោះ ក៏គ្រវែងខ្លួនលោស យក្សធ្លាក់មកយ៉ាងខ្លាំងដល់ដី ខាងខ្លួនល្អិតដូចជាធូលី ។

អ្នកមេត់ទាំងពីរនាំគ្នាឈប់ ។ ឥឡូវនេះ គេបានសេះពីរជាជំនិះផង គេបានផុតពីសេចក្តីវិនាសផង ។

ប៉ុន្តែ ចំណែកអ្នកគង្វាលចេះតែនឹកទៅរកព្រះរាជធីតាជានិច្ច ។ ចុះឥឡូវ តើធ្វើដូចម្តេចនឹងទៅថ្វាយបង្គំព្រះចៅកើត បើគ្មានផ្លែទៀបមាសទាំងបី ហើយថែមទាំងមាននាងក្រមុំនេះទៅជាមួយផង? ។

សេះយក្សប្រាកដជាដឹងចិត្តអ្នកគង្វាល បានដាក់ស្រែកកញ្ជ្រៀវហើយ និយាយថា:

- បពិត្រលោកនាយ សូមលោកកុំព្រួយឲ្យសោះ ខ្ញុំនឹងនាំលោកទៅកាន់សំណាក់យាយព្រះសៅរ៍ ។ កន្លែងនោះ ខ្ញុំដែលទៅម្ដងហើយ ! ប៉ុន្តែ សូមលោកជិះឲ្យប្រយ័ត្នក្រែងវិលមុខ ។

ប្រហែលមួយព្រេចភ្នែក សេះពាំងពីរនាំផងទាំងពីរហោះតាមអាកាសឡើងទៅដល់ខ្ទមរបស់យាយព្រះសៅរ៍ក្លាម ។ អ្នកគង្វាលប្រាប់ថា

- បពិត្រលោកយាយ ខ្ញុំបាទនាំនាងក្រមុំមកជូនលោកយាយវិញហើយ ។ ឥឡូវ សូមលោកយាយអត់ទោសដល់ខ្ញុំ ហើយគាណិតនាំខ្ញុំទៅចុងទៀបផង តើបានឬទេ ? ។

•យាយព្រះសៅរ៍ត្រេកអរពេក ក៏ប្រាប់ថា:

- ចូរទៅតាមមែកនេះចៅ ។ ចូរចេះតែឡើងទៅលើជានិច្ច ហើយចៅនឹងសម្រេចបានដល់លំនៅរបស់តាព្រះគក្កុ ដែលជាបងរបស់យាយ គាត់ចាស់ជាងយាយតែមួយថ្ងៃទេ ។ ប្រហែលគាត់នឹងអាចឲ្យដំណឹងដល់ចៅបាន ។ នែចៅគង្វាលចិត្តស្លូតត្រង់ បើកាលណាចៅត្រឡប់ទៅដីវិញ គាណិតមកយកកូនយាយទៅផង ពីព្រោះដើមទៀបនេះ នឹងមិនអាចរក្សានាងនេះ តយូរទៅទៀតបានឡើយ ។

ហើយអ្នកគង្វាលយើងក៏ចាប់សួរទៅទៀត ៗ លុះទីបំផុត ដោយបានឃើញតាម្នាក់ ពុកមាត់សសំពោងគេស្រែកសួរថា:

- បពិត្រលោកតាព្រះកេតុ សូមលោកតាប្រាប់ខ្ញុំបន្តិច តើត្រង់ណាចុងទៀប ព្រោះខ្ញុំខំប្រវាឡើងមកជាយូរណាស់ហើយ ៗ

តាព្រះកេតុពោលដោយសុន្ទរពាទថា:

នែចៅ ចូរទៅតាមនេះ បេះតែឡើងៗទៅក្នុងបីថ្ងៃទៀត ចៅនឹងបានដល់ចុងទៀបដែលជាលំនៅរបស់តាព្រះទេវានមិត្រ ៗ ដល់ទីនោះហើយ ត្រូវឲ្យគ្រាតផង ហើយប្រញាប់ប្រញាល់ផង ដូចពាក្យចំនៀមថា: " ក្តានផង ថែវផង ថ្កាលផង " ដើម្បីបេះផ្លូវទៀបកុំឲ្យគេឃើញ ព្រោះអ្វី ចៅមិនដឹងទេឬ ដែលគេហៅព្រះទេវានមិត្រ ? ចៅដឹងឬទេ គឺលោកតាហ្នឹងហើយ ដែលតែងគ្រាច់ទៅកាន់ផែនដី ដើម្បីកត់បញ្ជីជីវិតទាំងឡាយនៃមនុស្សនានា ៗ ហើយសម្រាប់នេះក៏ដោយ លោកឥតនៅទេ លោកគាល័យទៅទីឯណោះឆ្ងាយណាស់ ក្នុងផែនដីប្រាំបួន និងសមុទ្រប្រាំបួន ដើម្បីដកជីវិតយកពីព្រះចៅភជាធិរាជមួយព្រះអង្គ ដែលកំពុងតែគង់ក្រសាលនៅឯគុ ហើយមិនទ្រង់ជ្រាបថា ព្រះជន្មាយុអស់ហើយ ៗ ចូរទៅឲ្យឆាប់ ទាន់លោកមិននៅ ហើយគោងប្រយ័ត្នកាក្នាផង ៗ

( មានត )

# ចៅបាយក្តាំង

## លោក ទៀង តៃ-ឈុន

ក្រមការដើមខ្សែលេខ ១

ប្រែរៀបរៀង

( តមក )

---

ប្រាកដ ក៏ចេញបង្ហាញខ្លួន ។ នាងប្អូនទាំងពីរមានព្រះបន្ទូលទៅចៅបាយក្តាំងថា ព្រះបរមរាជបិតាយើងទ្រង់បញ្ជា ឲ្យនាំយកព្រះសិវិកា និងសំលៀកបំពាក់នេះ ព្រមទាំងទឹកអប់, ខ្លឹមចន្ទន៍និងក្រស្នា មកឲ្យបងឯង ។ បងសំអាតខ្លួនឲ្យស្អាត និងទឹកក្រអូបទាំងនេះ, ស្លៀកពាក់ហើយឡើងទៅលើគ្រែស្នែង, ព្រោះព្រះបរមរាជបិតាយើង ទ្រង់ចាំទទួលបង នៅក្នុងព្រះបរមរាជវាំង ។

លុះបានឃើញហ្វូងនាគជាច្រើន ដែលមកទទួលខ្លួន, ចៅបាយក្តាំងក៏ខ្លាចយ៉ាងក្រៃលែង ។ តែបើទោះជាយ៉ាងណាក៏ដោយ ចៅបាយក្តាំងលាងខ្លួននិងទឹកអប់ ស្លៀកពាក់ដ៏ល្អហើយ ទើបឡើងលើព្រះសិវិកា ។ ពួកនាគទាំងអស់ ដង្ហែទៅដល់ព្រះបរមរាជវាំង នៃព្រះបាទភុជង្គ ។

ព្រះរាជបុត្រទាំងពីរព្រះអង្គ បាននាំចៅបាយក្តាំងចូលទៅគាល់ព្រះ

ឋានមកដល់ហើយ ។ កាលបើទតឃើញអ្នកសប្បុរសនេះហើយ , ព្រះរាជាទ្រង់យាងចុះពីលើរាជបល្ល័ង្ក ទៅចាប់ដៃនាំទៅក្នុងបន្ទប់ ហើយមានព្រះបន្ទូលថា នែបុរស! ការដែលអ្នកយកអាសាកូនខ្ញុំទាំងពីរនាក់ មានជីវិតរស់ឡើងវិញមកនោះ, ខ្ញុំមិនអាចរករបស់អ្វី ឲ្យស្មើនឹងជីវិតនេះបាន ដើម្បីឲ្យជារង្វាន់អ្នកៗ ការសង្គ្រោះរបស់អ្នក ចំពោះកូនខ្ញុំធំណាស់ ហើយបើទុកជាខ្ញុំមានចិត្តចង់យ៉ាងណា ក៏ខ្ញុំមិនអាចសងគុណនោះវិញបានឡើយ ។

បន្ទាប់មក,ព្រះបាទកូដង្គទ្រង់បង្គាប់ ឲ្យរៀបចំអាហារយ៉ាងពេរពាសដើម្បីជប់លៀងទៅបាយក្តាំង ។ លុះទៅបាយក្តាំងបរិភោគបរិបូណ៌ហើយព្រះរាជបុត្រទាំងពីរនាំទៅបាយក្តាំង ទៅដេកលើគ្រែមួយយ៉ាងល្អផើត ។

លុះព្រឹកឡើង, ទៅបាយក្តាំងនិយាយទៅកាន់នាគប្អូនទាំងពីរថា នែប្អូនសំឡាញ់! បងមកតាមប្អូនបីថ្ងៃហើយ ។ ឥឡូវ បងឃើញថា ប្អូនបានសប្បាយនឹងរុងរឿងហើយ, បងសុំលាប្អូនត្រឡប់ទៅស្រុកវិញ ។ បងមកពោលដីដូនយូរណាស់ហើយ ។ គាត់ក្រលំបាកគោកយ៉ាកណាស់ ដែមទាំងនៅផ្ទះតម្នាក់ឯងផង ។

ព្រះអគ្គមហេសីទាំងពីរព្រះអង្គ ឮទៅបាយក្តាំងថ្លែងដូច្នោះហើយ ទ្រង់មិនហ៊ានទទឹងចំណង់ ហើយមានព្រះបន្ទូលថា នែបង! យើងគ្មានខ្វះអ្វីទាំងអស់ តែយើងនឹងឲ្យប្រាក់ទៅបងច្រើនទៅ ក្រែងបងយកទៅមិនរួច ។

ហេតុដូច្នេះ បានជាយើងឲ្យត្បូងនេះទៅបង ៗ ដោយគេនវត្ថុនេះ បើបងចង់បានអ៊ីនឹងបានរបស់នោះ ដូចបំណង ៗ ហើយបើកាលណាមានបច្ចាមិត្តមកគំរាមគំហែង, បងគ្រាន់តែបង្វិលត្បូងនេះជុំវិញខ្លួន, សត្រូវនោះវិនាសខ្ចាត់ខ្ចាយទាំងអស់ ៗ

លុះថ្ងៃព្រឹកស្អែក ព្រះអង្គម្ចាស់ទាំងពីរនាំចៅបាយក្តាំង ទៅក្រាបបង្គំលាព្រះបាទភូជង្គ ៗ បន្ទាប់មក, ព្រះរាជបុត្រទាំងពីរព្រះអង្គទ្រង់បន្ទូលឲ្យចៅបាយក្តាំងតោងក ហើយហោះទៅក្នុងឋានមនុស្សលោក ៗ

កាលបើបានដាក់ចៅបាយក្តាំងដល់ហើយ, ព្រះរាជបុត្រទាំងពីរមានព្រះបន្ទូលសួរទៅចៅបាយក្តាំងថា នែ បងរកផ្លូវទៅផ្ទះឃើញឬទេ?

ចៅបាយក្តាំងឆ្លើយវិញថា បងរកមិនឃើញទេ ៗ ប្អូននាំបងទៅកន្លែង ដែលបងចិញ្ចឹមប្អូន ទើបបងរកផ្លូវឃើញ ៗ

ព្រះរាជបុត្រទាំងពីរហោះនាំចៅបាយក្តាំង ទៅដាក់ដល់ព្រៃដែលចៅបាយក្តាំងធ្លាប់ចិញ្ចឹម កាលទើបនឹងចេញពីព្រះឧទរនោះ ៗ នៅពេលនោះ, ព្រះរាជបុត្រទាំងពីរទ្រង់ព្រះកន្សែង ទ្រង់អាឡោះអាល័យ មុននឹងបែកចេញពីចៅបាយក្តាំង ៗ លុះបែកគ្នាហើយ, ព្រះរាជបុត្រទាំងពីរក៏ហោះវិលទៅនគរវិញ, ចំណែកចៅបាយក្តាំង ក៏ដើរត្រង់ទៅផ្ទះខ្លួន ៗ

កាលបើឃើញចៅបាយក្តាំងត្រឡប់មកវិញហើយ ជីដូនសប្បាយ

រីករាយយ៉ាងក្រៃលែង ហើយសួរថា ចៅឯងទៅទីណាទើបនឹងមកវិញ ? ។

ចៅបាយក្តាំងឆ្លើយថា ឱយាយ ខ្ញុំទៅឆ្ងាយណាស់ ។

បន្ទាប់មកបានបីថ្ងៃ, ចៅបាយក្តាំងនិយាយទៅកាន់ជីដូនថា: យាយ ! សូមយាយទៅដណ្តឹងព្រះរាជបុត្រី ដែលនៅក្មេងជាងគេទាំងអស់ ។

ជីដូនឮហើយឆ្លើយថា យី អើហ្ន៎, ចៅសំឡាញ់ពេញចិត្ត, យើងជាអ្នកក្រទុគ៌ត, បើយើងទៅសួរដណ្តឹងព្រះរាជបុត្រី ទុកដូចជាយើងប្រមាថស្តេច ។

ចៅបាយក្តាំងនិយាយទៅទៀតថា យាយទៅ! យាយទៅ! យាយនិយាយតែតាមខ្ញុំចុះ ស្តេចមុខជាព្រមហើយ ។

ចៅបាយក្តាំងទទូចហើយទទូចទៀត លុះក្រាតែជីដូនទៅក្នុងព្រះបរមរាជវាំង ។ ព្រះរាជាទតឃើញយាយហើយ មានព្រះបន្ទូលសួរថា យាយ អញ្ជើញមកមានការអ្វី? ។

យាយឆ្លើយតបទៅស្តេចវិញថា សូមទ្រង់មេត្តាប្រោសព្រះរាជទានទោស ដ្បិតចៅទូលព្រះបង្គំជាខ្ញុំ បង្ខំឲ្យទូលព្រះបង្គំជាខ្ញុំមកដណ្តឹងព្រះរាជបុត្រី ដែលនៅក្មេងជាងគេ យកទៅធ្វើប្រពន្ធ ។

កាលបើដូច្នោះហើយ, ព្រះរាជាទ្រង់គិត ក្នុងព្រះចិត្តថា “ យាយ

នេះមិនសូវខ្លាចអញសោះទេតើ ទើបហ៊ានចូលមកដណ្តឹងកូនស្រីអញឲ្យចៅគាត់ ?" ។

បន្ទាប់មក ព្រះរាជាទ្រង់មានព្រះបន្ទូល ទៅកាន់យាយនោះថា នែយាយ, ខ្ញុំព្រមឲ្យកូនស្រីខ្ញុំទៅចៅយាយ តែយាយត្រូវសង់ស្ពានមាស-ប្រាក់មួយ និងប្រាសាទមាសមួយផង ហើយឲ្យរួចស្រេចក្នុងថ្ងៃស្អែក ។ បើមិនដូច្នោះទេ, ខ្ញុំចាប់យកជីដូននឹងចៅ ទៅស្ងោរក្នុងខ្ទះដែក ។

កាលបើឮព្រះរាជឱង្ការនោះ យាយក៏ក្រាបថ្វាយបង្គំលា ដោយមានសេចក្តីភ័យរន្ធត់យ៉ាងខ្លាំង ។ លុះត្រឡប់មកដល់ផ្ទះ, យាយនោះក៏ចូលដេកសន្លឹកសន្លៃ អត់បាយអត់ទឹក ។

ចៅបាយក្តាំងឃើញជីដូនដូច្នោះ ក៏សួរជីដូនថា យាយជាទីស្នេហា ! ហេតុដូចម្តេច បានជាយាយសម្រាន្តសន្លឹកសន្លៃ ដូចអស់កំឡាំងខ្លាំងណាស់ អត់បាយ, អត់ទឹកឬ ។ យាយម្តេច ក៏មិនប្រាប់ខ្ញុំ, តើស្តេចទ្រង់យល់ព្រមព្រះរាជទានព្រះរាជបុត្រីខ្ញុំឬទេ ? ។

ជីដូនឆ្លើយថា ចៅសំឡាញ់! យាយមិនព្រមទៅសោះ, ឯងចេះតែទទូចបង្ខំឲ្យយាយទៅ ។ ឥឡូវ ទៅរួចហើយ ។ ព្រះរាជាទ្រង់ព្រមព្រះរាជទានព្រះរាជបុត្រីឲ្យចៅឯងហើយ តែទ្រង់បញ្ជាឲ្យឯងសង់ស្ពានមាស-

ប្រាក់មួយ និងប្រាសាទមាសមួយផង ឲ្យរួចស្រេចក្នុងថ្ងៃស្អែក ។ បើចៅធ្វើតាមព្រះរាជឱង្ការនេះទាន់, ចៅទើបបានព្រះរាជបុត្រី, បើធ្វើមិនទាន់ទេ, ព្រះរាជាទ្រង់យកយើងទៅសម្លាប់ទាំងពីរនាក់ ។ ហេតុនេះហើយបានជាយាយភិតភ័យខ្លាំងណាស់ ។

លុះឮដីដូនរៀបរាប់ដូច្នោះ, ចៅបាយក្តាំងឆ្លើយទៅដីដូនថា: យាយជាទីស្នេហា, យាយកុំបារម្ភឲ្យសោះ! យាយក្រោកឡើងពិសារបាយទៅ, ព្រោះខ្ញុំចេះធ្វើសព្វគ្រប់ហើយ ។

កាលបើឮចៅធានានឹងអាចធ្វើបាន តាមព្រះរាជឱង្ការនៃព្រះរាជាហើយ, យាយក្រោកងូតទឹកស៊ីបាយ ។

នៅពេលយប់, កាលបើអ្នកស្រុកដេកស្ងាត់អស់ហើយ, ចៅបាយក្តាំងគិតថា "នាគប្អូនអញទាំងពីរ បានឲ្យត្បូងមួយមកអញ ហើយនិយាយថា បើបងចង់បានរបស់អ្វី, បងគ្រាន់តែលើកកែវមណីជោតិនេះ ហើយបន្ទោលជុំវិញខ្លួន បួងសួងតាមប្រាថ្នា វត្ថុដែលបងចង់បាននឹងកើតឡើងភ្លាម" គិតរួចហើយ, ចៅបាយក្តាំងអុជធូបបីសរសៃ ហើយដើរទៅក្នុងវាលស្ងាត់ ហើយបួងសួងថា ឱលោកម្ចាស់! ខ្ញុំចង់បានប្រាសាទមាសមួយ និងចង់បានស្ពានមាស ប្រាក់មួយផង ។

(មានត)

# នាងនាយចង្រ្កាន

លោក លាង ហាប់-អាន សាស្ត្រាចារ្យ

ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត

រៀបរៀង

កាលណោះ មានមហាសេដ្ឋីម្នាក់ឈ្មោះម៉ាយ បានរៀបការជាលើកទី-ពីរ ជាមួយនឹងស្ត្រីម្នាក់ដ៏ល្អឯក ធ្វើជាភរិយា ។ នាងនោះមានកូនស្រីពីរនាក់ មានមុខដូចៗគ្នាបេះបិទ ។ ចំណែកលោកសេដ្ឋីមានកូនស្រីដើមមួយនាក់ ដែលមានលក្ខណៈសុភាពរាបទាប ហើយស្រឡាញ់ម្តាយចុងដូចជាម្តាយខ្លួនបង្កើត ។ ប៉ុន្តែ នាងម្តាយចុងដែលជាអសប្បុរស ក៏តែងប្រណៅធ្វើបាបនាងកូនដើមជាអនេក ។ ហើយបានដាក់កំរិត ឲ្យបំពេញមុខការគ្រប់បំពូកនៅក្នុងផ្ទះ គឺឲ្យជូតក្តារ លាងចាន បោកអ៊ុតខោអាវ ជូតសំអាតបន្ទប់ខ្លួន និងកូនសំណប់ទាំងពីរ ហើយចាត់ឲ្យនាងដេកនៅ តែក្នុងជង្រុកលើចម្បើង ដ៏ស្មៀបមាស ។ នាងកញ្ញានេះមានទុក្ខក្រាំក្រា ក្នុងខ្លួនតែឯកឯង នាងពុំហានជំរាបលោកបិតាឡើយ ដោយមានសេចក្តីកោតក្រែងដល់ម្តាយចុង ។ ពេលធ្វើការ នាងកញ្ញាតែងនៅពួនធ្វើតែម្នាក់ឯងប្រផ្នុកក្នុងផ្ទះបាយ ។ ហេតុដូច្នោះហើយ ទើបនាងបុត្រីច្បងបានសន្មត់ហៅ

បំអកថា នាងកញ្ជះបង្ក្រាន ៗ ប៉ុន្តែ នាងបន្ទាប់ហៅថា នាង នាយ-បង្ក្រាន ៗ ពីព្រោះតែនាងមានសម្លៀកបំពាក់ពុំគប្បី គង់នាងនៅល្អឆើត ជាងបងជាបុត្រីម្តាយចុងទាំងពីរ ៗ

សម័យមួយ ព្រះរាជបុត្រព្រះចៅសោយរាជ្យ បានប្រកាសអញ្ជើញអស់ពពួកកញ្ញាទាំងឡាយ ជាបុត្រីមហាសេដ្ឋី និងនាម៉ឺនធំតូចទាំងឡាយ ចូលមកពិកំសាន្ត នៅក្នុងព្រះរាជដំណាក់ ៗ នាងកញ្ញាបុត្រីចុងរបស់មហាសេដ្ឋីក៏ត្រូវគេអញ្ជើញទៅដែរ ព្រោះនាងទាំងពីរនេះ មានឈ្មោះល្បីឯកក្នុងនគរ ៗ នាងទាំងពីរក៏បានប្រុងប្រៀបសម្លៀកបំពាក់ យ៉ាងល្អទុកជាមុនស្រេច ៗ លំដាប់នោះហើយ ដែលនាងនាយបង្ក្រានត្រូវទទួលការ អ៊ុតសំអាតសំលៀកបំពាក់ឲ្យបង ៗ មាតាបានប្រើឲ្យគេអញ្ជើញជាងមកកាត់ម្ជូរសក់ ឲ្យបុត្រីទាំងពីរនេះគង់ខ្លួនតាមសម័យ ៗ ពេលនោះ បងទាំងពីរ ក៏បានប្រាប់សេចក្តីអំពាវនាវ របស់ព្រះអង្គម្ចាស់ដល់នាងនាយបង្ក្រាន ហើយក៏បានអនុញ្ញាតឲ្យនាងកាត់សក់ក្ងីងរើងនោះចោលចេញ ជាមួយផង ៗ កំពុងកាត់ នាងបងទាំងពីរក៏និយាយបំអកទៅថា " យើមនាយបង្ក្រាន តែងខ្លួនទៅព្រះរាជដំណាក់មហោស្រពដែរ ! ហ៎ះ យ៉ាងណាទៅបើគេឃើញស្រីកញ្ជះបង្ក្រាន មកប្រឡូកក្នុងហ្វូងអ្នកមានមុខមាត់ធំៗយ៉ាងនេះ! " ៗ នាងនាយបង្ក្រានខឹងខ្មាសសំដីបងណាស់ ប៉ុន្តែ នាងពុំមានគប

ដោយកំហឹងនោះ នាងគ្រាន់តែអង្វរថា " សូមបងកុំបំអកឱ្យខ្ញុំ " តែប៉ុណ្ណោះ ៗ នាងទាំងពីរដោយសេចក្ដីអំនួតដ៏ក្រៃលែង ក៏ក្លេចក្លាំងអាហារម្ហូបចំណីអស់ពីរថ្ងៃ ៗ កាលពេលគេឃើញតែនាងទាំងពីរ អង្គុយធ្ងុះកញ្ជាក់មួយម្នាក់ គាក់គង់ខ្វន ។

ដល់កាលបរិច្ឆេទ នាងទាំងពីរក៏បានបណ្ដើរគ្នាយាងប្រឹម ហើយទៅទីប្រជុំនោះ ៗ ចំណែកនាងនាយបញ្ច្រាន ដែលមានសេចក្ដីអន្ទះអន្ទែងចង់ទៅជាខ្លាំង ក៏ខំដើរតាមមើលបងរហូតដល់ផុតកន្ទុយភ្នែក ៗ មានចំណង់ណាស់នាងក៏ទៅជាស្រែកយំ នឹកត្អូញចិត្តតែខ្លួនឯង ៗ មួយរំពេច ស្រាប់តែមានស្ត្រីម្នាក់រូបល្អស្អាត ចេញខ្លួនមកបង្ហាញនាង សួរអំពីដំណើរដែលនាងយំនោះ ៗ នាងកញ្ញាពុំបានប្រាប់សោះ ហើយនឹងរឹតតែយំស្រណោះស្រណោកផងយាងខ្លាំង ៗ ដោយអំណាចចិត្តទិព្វ របស់នាងទេពធីតាដែលជាម្ដាយចិញ្ចឹម របស់នាងនាយបញ្ច្រាន ធីតាយល់ហេតុពិតថា នាងកញ្ញាមានចំណង់ទៅលេងទីប្រជុំនឹងគេ ៗ ទើបនាងនិយាយលួងលោមថា " អើ កូនស្រីម្ដាយ នាងច្បាស់ជាចង់ទៅកំសាន្ត ជាមួយគេហើយ ! ឯងនេះកុំស្មានថា គ្មានសំណាងឲ្យសោះ កុំយំណាម្ដាយបើកឲ្យទៅ " ៗ តមកនាងទេពធីតាក៏នាំនាងនាយបញ្ច្រាចូលទៅ ក្នុងបន្ទប់ហើយ ស្រដីប្រើទៅថា " ចូរកូនស្រីចូលទៅក្នុងសួនច្បាររបេះផ្លែត្រប់មួយយកមកឲ្យម្ដាយ " ៗ

នាងនាយចង្រ្កានមានអំណរពេក ក៏ចុះទៅរកបេះផ្លែក្រូច បានមួយយ៉ាងទុំរលោង មកជូននាងទេពធីតាដោយគិតក្នុងចិត្តថា តើផ្លែក្រូច នោះនឹងធ្វើយ៉ាងណាទៅ ឱ្យខ្លួនបានទៅទីប្រជុំជនគេនោះ ៗ នាងទេពធីតាទទួលផ្លែក្រូចពីដៃបុត្រីចិញ្ចឹមហើយ ក៏មកយកសាច់ចោលចេញអស់ ទើបទាញបន្ទឹះទិព្វវាយបន្ទុលសេពអាគម ៗ មួយរំពេច សំបកក្រូចក៏ប្រែកើតទៅជាតួរទេះទូរមួយយ៉ាងថ្មីស្រឡាង ៗ

តមក នាងទេពធីតាក៏ចូលទៅបើកហិបតូចមួយ ឃើញមានកណ្ដុរ ៦ ៗ ធីតាប្រាប់ឱ្យបុត្រីបើកគម្របបង្ហើប ឱ្យចេញម្ដងមួយៗទើបយកបន្ទឹះទិព្វវាយលើខ្នងកណ្ដុរ ឱ្យប្រែក ទៅជាសេះយ៉ាងធំធាត់ទាំង ៦ សំរាប់អូសរទេះ ៗ

បានដូច្នោះហើយ នាងកញ្ញាក៏ស្រដីទៅធីតាជាមាតាចិញ្ចឹមថា " ចាំខ្ញុំទៅរកចាប់កណ្ដុរប្រេងមួយ មកជូនដើម្បីសេព ឱ្យបានជាអ្នកបរទេះ! " ៗ នាងទេព្ធីតាមានអំណរណាស់ក៏តបថា " អេប្រពៃណាស់កូនស្រី ឯងទៅរកចាប់យកឱ្យឆាប់មក " ៗ នាងនាយចង្រ្កានក៏ញាប់ទៅយកទ្រុងអន្ទាក់កណ្ដុរប្រេងមួយ ដែលមានកណ្ដុរបីនៅក្នុងនោះ មកឱ្យមាតាទេពរើសយកមួយមកសេព ឱ្យទៅជាអ្នកបររទេះម្នាក់យ៉ាងចំណាន ៗ ហើយនាងធី-តាបង្គាប់ទៅបុត្រីទៀតថា " ចូរកូនរកទៅក្នុងសួនច្បារ ឯងនឹងបានប្រទះឃើញបង្កួយប្រាំមួយនៅជើងរបង ចូរឯងចាប់យកមកឱ្យឆាប់ " នាង

កញ្ញាស្ទុះតែទៅគេ ឃើញហើយក៏ចាប់យកមកជូនមាតា ដែលបានសេពមួយរំពេច ឲ្យទៅជាអ្នកបំរើទាំង ៦ យ៉ាងរមៀម ។

ស្រេចហើយនាងទេពធីតា ប្រាប់ទៅបុត្រីថា “ ឥឡូវបានហើយ ចូរកូនទៅលេងនឹងគេចុះ ” ។ នាងបុត្រីស្រដីថា “អ្នកម៉ែឲ្យកូនទៅទាំងក្រខ្លួនយ៉ាងនេះ ” ។ ថាដូច្នោះភ្លាម នាងទេពធីតាក៏យកបន្ទឹះទិព្វពាល់ទៅលើខ្លួននាង ។ មួយរំពេច សម្លៀកបំពាក់ចាស់ក៏ប្រែភេទជាថ្មីហើយ អង្គនាងក៏ស្រោបស្រក់ទៅដោយគ្រឿងអលង្ការមានខ្សែ កដៃ មាសពេជ្រ ចិញ្ចៀនកុំចិញ្ចាច ។ ធីតាហុចស្បែកជើងកែវមួយគូ ឲ្យបុត្រីពាក់ ហើយផ្តាំផ្តាច់ថា “ ចូរកូនកុំនៅឲ្យហួសដល់អធ្រាត្រ បើកូនមិនត្រឡប់មកពីមុនឲ្យទាន់ពេលវិញទេ រទេះនោះមុខជាទៅជាសំបកក្រូច សេះទៅជាកណ្តុរ បំរើទៅជាបង្គួយ ហើយសម្លៀកបំពាក់ថ្មី ក៏ទៅជាចាស់ដូចដើមវិញ ” ។ នាងបុត្រីទទួលពាក្យនាងទេពធីតាថា នឹងវិលមកឲ្យទាន់ពេលវេលាដូចបណ្តាំ ។

ដល់ក្នុងព្រះរាជដំណាក់ អ្នកផងបានឲ្យដំណឹងដល់ព្រះអង្គម្ចាស់ថា មានព្រះនាងក្សត្រីម្នាក់ ជិះរទេះទូរចូលមកដល់ហើយ ។ ឮដូច្នោះព្រះអង្គម្ចាស់ក៏យាងចេញមកទទួល ។ ព្រះអង្គម្ចាស់ទ្រង់ហុចដៃទទួលនាងឲ្យចុះមកដី ហើយទ្រង់អញ្ជើញចូលទៅ ក្នុងមន្ទីរកំសាន្ត ។ មួយ-

រំពេច សូរសម្លេងភ្លេងក៏ស្ងាត់ស្ងៀម ។ គេឮតែសូរមាត់សរសើរគ្រប់ៗ គ្នា ចំពោះសេចក្ដីល្អឆើតរបស់នាងនាយចម្រៀងដាច់គេឯង ។ កុំថាឡើយ ដល់ទៅព្រះរាជា ដែលទ្រង់ជរាទៅហើយនោះ ក៏គង់តែ ទ្រង់គយគន់ទត រំពៃមកលើរូបនាង ហើយទ្រង់សរសើរ ចំពោះភក្ត្រព្រះអគ្គមហេសីថា ទ្រង់តាំងពីឡើងសោយរាជសម្បត្តិមក ពុំដែលបានប្រទះឃើញកញ្ញា ស្រស់ល្អឆើតយ៉ាងនេះសោះ ។ ស្រីៗទាំងអស់ខំផ្ទៀងផ្ទង់គយគន់សម្លៀក បំពាក់ប៉ូករបស់នាង ពុំដាក់ភ្នែកសោះ ខុះខំចំណាំគំរូ ដើម្បីនឹងដូលជាង ដែឯកឲ្យកាត់តាម នៅពេលដែលត្រឡប់ទៅផ្ទះវិញ ។

ព្រះអង្គម្ចាស់បានអញ្ជើញឲ្យនាងអង្គុយ នៅក្បែរជំទត្តម ហើយក៏ ទ្រង់អញ្ជើញឲ្យក្រោកឡើងរាំជាមួយព្រះអង្គ ។ ក្នុងកងអង្គនាង ព្រះអង្គ ម្ចាស់ពុំទាំងសោយចំណីផ្សេងៗ ដែលគេលើកយកមកថ្វាយសោះ ។ នាងកញ្ញាក៏បានក្រោកដើរទៅជិតបងស្រីទាំងពីរ ដែលពុំស្គាល់នាង ដល់បន្តិចសោះ ហើយគំនាប់ទទួលសេចក្ដីកក់ក្ដៅ យ៉ាងស្និទ្ធស្នាល ។ បន្តិចមក នាឡិកាចង្អុលម៉ោង ១១ សែសិបប្រាំនាទី នាងកញ្ញាគំនាប់លា គៀវទាំងអស់ ព្រមទាំងថ្វាយបង្គំលាព្រះរាជា រួចត្រឡប់មកផ្ទះវិញ តាម បណ្ដាំនាងមាតាទេព ។ ដល់ផ្ទះហើយនាងក៏ចូលទៅសំពះអរគុណមាតា ទេព ។ នាងបានរៀបរាប់ប្រាប់អំពីដំណើរ របស់នាងនឹងសេចក្ដីធ្លាប់

របស់អ្នកទាំងអស់ ៗ នាងជំពបមាតាទេពថា ព្រះអង្គម្ចាស់សូមអញ្ជើញនាងទៅកំសាន្ត នៅថ្ងៃស្អែកទៀត ៗ កំពុងតែនិយាយស្រាប់តែឮសូរមាត់បងស្រីមកគោះទ្វារហៅ ៗ នាងនាយចង្ក្រានស្ទុះចេញទៅទទួលបងដោយធ្វើជាស្វាបហើយយកដៃឈើក្អែក មានសញ្ញាដូចជាទើបនឹងគ្រាកពីដេក សើងមម៉ឹងដូច្នោះ ៗ មួយរំពេច បងស្រីម្នាក់ស្រដីអួតទៅនាងថា “នាយចង្ក្រានអើយ ! បើឯងទៅមន្ទីរជំណាក់ផង ប្រហែលជាឯងនឹកផ្ទែកអស្ចារ្យ ដូចបងជាពុំខានហើយ រុំអើយ មានព្រះនាងក្សត្រីកញ្ញាម្នាក់រូបល្អឆើតគេស្រីក្រមុំប្រៀបគ្មាន ហើយចេះគួរសមសុភាពរាបទាប ទាំងបានគួរសមចែកផ្លែក្រូចដល់យើងទាំងពីរស៊ុំផង យ៉ាងស្និទ្ធស្នាល គ្មានធ្មើងទេ នាងនាយចង្ក្រាន ក៏ធ្វើជាសួរឈ្មោះព្រះនាងក្សត្រីនោះ ” ៗ ប៉ុន្តែបងទាំងពីរតបមកវិញថា គេពុំដែលឃើញព្រះនាងនោះសោះ ជាអន្លើមកហើយ ព្រះអង្គម្ចាស់ទ្រង់សព្វព្រះហឫទ័យ ក្តុបទាំងក្រយាស្ងោយ ទន់ដៃជើងអស់ ៗ នាងនាយចង្ក្រានធ្វើជាសើចតបទៅវិញថា “ យី ល្អណាស់ហ្ន៎! ធ្វើម៉េចទៅឲ្យខ្ញុំបានឃើញផង ន៎! បើដូច្នោះ សូមបងមេត្តាឲ្យខ្ញុំខ្ចីអាវចាស់ពណ៌លឿងមួយមក ” ៗ នាងបងស្រដីពេបជ្រាយទៅថា ហ៎ះ! អាក៏គ្រាន់បើម្ទេះ មីកញ្ចះចង្ក្រាន ឯងស្មានថា អញគ្រើននឹងឲ្យឯងខ្ចីផ្ដេសផ្ដាសយ៉ាងនេះឬ ” ៗ

ស្អែកឡើងនាងកញ្ញា ទាំងពីរបានតែងខ្លួនទៅមន្ទីរប្រជុំក្សាន្តទៀត ។ ចំណែកនាងនាយបង្ក្រានក៏បានស្លៀកពាក់យ៉ាងល្អ លើសលុបជាងថ្ងៃមុន ឡើងជិះរទេះសេះដែលបរចេញទៅ ។ ព្រះអង្គម្ចាស់ពេញទៅដោយសេចក្តីត្រេកត្រអាល ក៏បានមកអង្គុយជិតប្រកៀក ពិភាក្សានឹងនាងនាយបង្ក្រានក្សត្រី យ៉ាងស្និទ្ធស្នាល សប្បាយហួសប្រមាណ នាងកញ្ញាភ្លេចពាក្យបណ្តាំមាតាទេព ។ លុះនាលិកាវាយម៉ោង ១២ គត់ នាងស្មាន តែម៉ោង ១១ ប៉ុណ្ណោះ ។ ប៉ុន្តែ មួយរំពេចមក ស្រាប់តែនាងក្រោកឈរឡើង សំពះគំនាប់លាភ្លៀវ ព្រមទាំងព្រះមហាក្សត្រ នូវព្រះអគ្គមហេសី ស្ទុះរត់ចេញមកក្រៅជាប្រញាប់ ។ ឆ្ងល់ពន់ពេក ព្រះអង្គម្ចាស់ក៏ដេញតាមនាងមកក្រៅ ប៉ុន្តែ ទ្រង់តាមពុំទាន់នាង ។ រហ័សដូចព្រួញ នាងកញ្ញាភ្លាត់ស្បែកជើងមួយចំហៀងធ្លាក់នៅលើផ្លូវ ។ ព្រះអង្គម្ចាស់ទ្រង់ស្ទុះទៅរើសយកមកទុកយ៉ាងប្រពៃ ។

នាងនាយបង្ក្រានដើរ ត្រឡប់មកផ្ទះវិញ នៅសល់តែស្បែកជើងមួយចំហៀងជាលំអរ ។ សម្លៀកបំពាក់នាង ប្រែក្លាយទៅជាចាស់ក្រខ្វក់ដូចដើម ចំណែករទេះសេះនឹងបំរើក៏ក្លាយភេទ ទៅជាសត្វកណ្តុរបង្គួយរត់បាត់អស់ ។ ព្រះអង្គម្ចាស់បានបញ្ជាក់សួរអ្នកយាមទ្វារថា មានឃើញរទេះព្រះនាងក្សត្រីបរចេញទៅតាមទ្វារទេ ។ នាយឆ្មាំទ្វារទូលតបថា បាន

ឃើញតែស្រីកំសត់ ស្លៀកសំពត់អាវចាស់ម្នាក់ រត់ចេញទៅ តែប៉ុណ្ណោះ ដែលមានភាពជាកូនអ្នកស្រែស្មោះ ។

លុះនាងបងទាំងពីរត្រឡប់មកដល់ផ្ទះវិញ នាងនាយបង្គ្រានក៏សួរបញ្ជាក់ អំពីសេចក្តីសរសើរដល់ព្រះនាងក្សត្រី ពីថ្ងៃមុននោះ ។ នាងទាំងពីរបានរ៉ាយរៀងប្រាប់ថា ព្រះនាងកញ្ញានោះ ប្រដាប់រឹតតែល្អជាងថ្ងៃមុនទៅទៀត ប៉ុន្តែ ដល់នាឡិកាវាយម៉ោង ១២ គត់ ស្រាប់តែព្រះនាង ស្ទុះរត់ចេញគៀសខ្លួនបាត់ទៅ ។ ហើយដោយរហ័សពេក ព្រះនាងក៏របូតស្បែកជើងម្ខាងធ្លាក់នៅលើឥដ្ឋ ។ ព្រះអង្គម្ចាស់ ក៏បានរើសស្បែកជើងកែវនោះទុក ហើយទ្រង់សព្វព្រះហឫទ័យ ទៅដល់ព្រះនាងជាខ្លាំង សឹងផ្ទំពុំលក់ ។

រំលងប៉ុន្មានថ្ងៃក្រោយមក ដោយសេចក្តីអន្ទះអន្ទែងទប់ពុំបាន ព្រះអង្គម្ចាស់ ក៏បានអំពាវនាវគ្រប់ដំបន់ ដល់កញ្ញាទាំងឡាយ ដែលមានទំហំជើងត្រូវនឹងស្បែកជើងនោះ នឹងបានបានខ្លួនជាទីអគ្គមហេសី ។ ក្រុមព្រះញាតិវង្សទាំងអស់ បាននាំបុត្រីមកលជើង នឹងស្បែកជើងនោះ ប៉ុន្តែ ពុំមានត្រូវដល់ម្នាក់សោះ ។ បន្ទាប់មក ដល់វេនពួកបុត្រីកូនមន្ត្រីរហូតដល់មន្ត្រីជាន់ទាប ប៉ុន្តែ ពុំមានល្មមជើងសោះ ។ គេក៏បាននាំបុត្រីលោកមហាសេដ្ឋីទាំងបីយកទៅឲ្យលទៀត ។ លុះឃើញបងប្រឹងសាកពុំចុះហើយ

នាងនាយបង្ក្រានបន្ទឹកពា ដោយស្គាល់ជាក់ជាស្បែកជើងរបស់ខ្លួនឡើង ថា "មើលឲ្យខ្ញុំលមើលតើប្រពៃទេ" ។ ឮដូច្នោះ នាងបងទាំងពីរក៏នាំគ្នា សើចចំអកឲ្យនាងប្អូន ។ អ្នកប៉ាវគង់ក៏សូមអញ្ជើញ ឲ្យនាងនាយបង្ក្រាន ចូលមកលស្បែកជើងនោះ ។ នាងកញ្ញាក៏បានចូលទៅអង្គុយនៅកន្លែង ដំសមគួរមួយ ហើយនាយតម្រួត ក៏ទាញស្បែកជើងយកមកឲ្យនាង ពាក់ល ។ នាងកញ្ញាទទួលសុពណ៌បាទមកពាក់ត្រូវក្ដុំ គ្មានចន្លោះ ។ អ្នក ទាំងអស់ព្រមទាំងបងស្រីទាំងពីរ ក៏នាំគ្នាកាំងធ្ងល់សំឡឹងមើលមុខនាង នាយបង្ក្រានក្ដឹសៗ ។ ដើម្បីសហេតុឲ្យរឹងរឹតតែប្រាកដឡើង នាងក៏ដក ទាញយកស្បែកជើងដូចគ្នា មួយចំហៀងទៀតពីហោប៉ៅមកពាក់បង្ហាញ អ្នកទាំងអស់ឲ្យឃើញជាក់ថា ជារបស់នាងពិត ។ ហើយការតែស្រួច រាសនានានទៅទៀត ។

មួយរំពេច នាងទេពធីតាជាមាតាចិញ្ចឹម ក៏បានមកដល់ទីនោះ ។ នាង យកចង្កឹះទិព្វពាល់ទៅលើសម្លៀកបំពាក់ប្រាណនាង ។ មិនបានទាំងមួយ ដំណាស់ដៃផង ស្រាប់តែសំពត់អាវចាស់ ក្រខ្វក់ប្រែកទៅជាហូលខិន ចរល្បាប់ដ៏ក្រៃលើបរលាង ប្រដាប់ទូវខ្សែមាសពេជ្រ ស្រោបស្រក់ទាំង កាយនាង ធ្វើឲ្យនាងបងទាំងពីរស្គាល់ជាក់ថា នាងនាយបង្ក្រាននេះហើយ ដែលត្រូវខ្លួនជាព្រះនាងក្សត្រី កាលដែលខ្លួនបានឃើញកោតគោរព

សរសើរទៅក្នុងព្រះរាជមន្ទីរមហោស្រពនោះ ។ ទើបនាងទាំងពីរតក់ស្លុត ឥតឧបមា នឹកខ្លាចសប្តូរពេក ស្ទុះចូលទៅ ក្រាបទូលដើងនិយាយអង្វរ សូមទោសកុំឲ្យនាងប្រហារឲ្យសោះ កាលដែលខ្លួនបានធ្វើបាបមើលងាយ ពេបជ្រាយ ទាំងប៉ុន្មានអំពីមុននោះ ៗ នាងនាយចង្ក្រានក៏ចាប់លើកបងទាំងពីរឲ្យក្រោកឈរឡើងហើយនិយាយពាក្យគាក់បញ្ឆាក់ថា ខ្ញុំគ្មានគំហឹងគុំគួននឹងអ្វីឡើយ គឺពិតជានៅស្រឡាញ់បងដូចបងបង្កើតពោះមួយ ៗ ជីវិត ។

ក្បួនរាជរថក៏បានរៀបផ្ញើនាងនាយចង្ក្រានជិះលើ ចូលទៅក្នុង ព្រះរាជវាំងថ្វាយចំពោះព្រះភក្ត្រព្រះអង្គម្ចាស់ ព្រមទាំងព្រះរាជបិតាមាតាខ្ញុំព្រះញាតិវង្សទ្រង់នាម៉ឺនសព្វមុខមន្ត្រីធំតូច ដែលនៅចាំទទួលនៅទីនោះ ។

លុះដល់ពេលល្អ ព្រះរាជាក៏បានរៀបអភិសេកព្រះរាជបុត្រនឹងនាងកញ្ញានាយចង្ក្រានជាទីអគ្គមហេសីយ៉ាងមហោឡារិក ។ លំដាប់មក ព្រះអង្គក៏ទ្រង់ផ្ទេររាជ្យឲ្យព្រះរាជបុត្រគ្រងស្នង ហើយនាងនាយចង្ក្រានក៏ឡើងឋានន្តរជាព្រះម្ចាស់ក្សត្រីយ៉ាងប្រាកដ ។ ព្រះនាងក៏បាននាំបងស្រីទាំងពីរ ចូលទៅនៅក្នុងមហាប្រាសាទជាមួយ ហើយនៅថ្ងៃអភិសេកជាមួយនោះ ព្រះនាងក៏បានរៀបការបងទាំងពីរនាក់ ឲ្យទៅនាម៉ឺនគេម្នាក់ម្នាក់ ឯកយ៉ាងស្តុកអង់អាច ក្នុងព្រះរាជវាំងជាស្រេច ។

ចប់ ។

## និគមនៈ

ការមើលឆ្ងាយគេជាបាបមួយ ឲ្យផលទុក្ខក្រោយយ៉ាងអប្រិយ
ឲ្យអាប់មុខមាត់នាលោកិយ ទៅបរលោកក៏សឹងដូចគ្នា ។
ដូចនាងបង ៗ ចោមមើលឆ្ងាយ នាងនាយបន្ទ្រានឥតមេត្តា
បានក្ដីអាម៉ាស់មុខណាស់ណា កណ្ដាលហ្វូងមហាជនប្រជុំ ។
តែនាងជាស្រីនាយបន្ទ្រាន នាងបានម្ដាយដើមជួយទំបត្ថម្ភ
លៃលកឲ្យនាងបានជាធំ ឧត្ដមរុងរឿងរួចចាកទាប ។
គឺបានឡើងជាអគ្គមហេសី ខ្ពស់លើសបងស្រីតាំងទេវភាព
ដោយគុណម្ដាយដើមជួយឲ្យលាភ ប្រសើររៀងរាបលើសស្រីផង ។
លុះបានជាធំមិនឆ្មើងឆ្មៃ នាងជួយកែខៃស្រីជាបង
ឲ្យបានស្វាមីរួមគូគ្រង ល្អ ៗ កន្ទុងពេកណាស់អើយ !

ស្រី – អ៊ី

# រឿងព្រេងនិងរឿងបុរាណប្រទេសជប៉ុន

( តមក )

## លោក វ៉ាយ-ប៊ុក ប្រែរៀបរៀង

ចូរអ្នកឯងចេញទៅ! អ្នកឯងកុហកបោកបញ្ឆោតឲ្យខូចកិត្តិយសខ្ញុំ ។ ក្នុង ពេលនោះ រូបព្រះនាងមានផ្ទៃកបន្ទោរក្លាយប្រែកាត់ព្រៃវិញ ទេវតាភាំងស្រាំង ខ្មៅខ្នះ ក៏រត់ចេញពីព្រះសិរសា, ព្រះស្កន្ធ, ព្រះឧទរ, ព្រះហស្ត និងព្រះ បាទព្រះនាងអស់លើងគ្មានសល់ ។

ទេវតាអិជសាណាគី ក៏ថយចេញទៅ, ចិត្តតក់ស្លុតរន្ធត់តក់តប់មាៗ ឥឡូវនេះ, ទេវតា ក៏រត់ចេញពីឋាននរកនោះទៅ ។

តែដោយសេចក្ដីអំពាវនាវ, ព្រះនាងអិជសាណាមី, ក៏មាន ព្រាយរត់ដេញតាមទេវតាអិជសាណាគី ។

ទេវតាអិជសាណាគីរត់យ៉ាងលឿនចេញពីឋាននរក, លោកបាន យកកម្រងបុប្ផា ដែលរុំពន្ធព្រះសិរសា បោះទៅលើពួកព្រាយ ភាំងនោះ. កម្រងបុប្ផានោះប្រែកាលទៅជាផ្លែទំពាំងបាយជូរទាំងបន្ដោម: ពួកព្រាយ នោះក៏បង្អង់ឈប់ចាំ សាស្រ័យផ្លែទំពាំងបាយជូរនោះសិន ។

រួចពួកព្រាយក៏តាំងដេញតាមទេវតា អិជសាណាគីម្ដងទៀត ។ ក្នុង

ពេលនោះ, ទេវតាបានឮសូរជើងព្រាយរត់តាម, លោកក៏យកគ្រាប់របស់លោក កាច់បំបាក់ហើយចោលទៅក្រោយ, ចំពួកព្រាយ, គ្រាប់នោះក៏ប្រែកាត់ទៅក្រោយចំពួកព្រាយ, គ្រាប់នោះក៏ប្រែក្លាយទៅជាទំពាំង ។ ពួកព្រាយក៏បន្ថយល្បឿន, ចាំរើសទំពាំងនោះបរិភោគ ។

ឥឡូវនេះ ទៅជាទេវតារន្ធត់តាំងប្រាំបីរូប និងពួកភាហាះនៅស្ថាននរក មានចំនួនជាង មួយពាន់ប្រាំរយនាក់ រត់ដេញតាមទេវតា អំដសាណាគីៗ ក៏ហូតព្រះខ័ន, ហើយរត់បណ្ដើរ, គ្រវីពីក្រោយបណ្ដើរ ដើម្បីឲ្យសត្រូវនោះជៀសចេញឆ្ងាយ ។

ទេវតានោះបះតែរត់, រត់ទៅស្រាប់តែបាត់ដំនឹត ។ នៅឆ្ងាយ, សែនឆ្ងាយ, មានស្មើក្លឹងតាំងបែង, គឺទីនោះឯងជាស្ថានមនុស្សលោក ។

ទេវតាអំដសាណាគី នឹកក្នុងចិត្តថា អញជិតផុតពីកយក្ខកាយ , តែក្នុងពេលនោះ, សត្រូវរត់ដេញប្រកិតជិតទាន់លោក ។ លោកជិតដួល, ក៏ស្រាប់តែក្រឡេកទៅ ឃើញផ្លែប៉ែសបី, លោកក៏យកផ្លែនោះចោលទៅលើសត្រូវ ហើយសត្រូវក៏ឈប់បង្អង់រើសផ្លែនោះភាស្រ័យ ។

ទេវតាអំដសាណាគី ក៏ពោលទៅកាន់ផ្លែប៉ែសថា "ដោយសារឯងជួយអញ, អញសុំឲ្យជួយមនុស្សណា ដែលមានអាសន្ន អញឲ្យនាមឯងថា "ផលទេព" ។

តែក្នុងពេលនោះ, ស្រាប់តែសពព្រះនាងអ៊ិជសាណាមីស្ទុះភាយមកទៀត៖ ព្រះហស្ដនៃសពនោះគ្មានសាច់ទេ, ក៏លើកឡើងបម្រុងនឹងស្រវាចាប់ទេវតា អ៊ិជសាណាគីៗ ក៏ស្ទុះហោះទៅដល់ស្ថានមនុស្សលោក ។ អ៊ិជសាណាគី ក៏យកថ្មធំមួយធំសម្បើមអស្ចារ្យ ដែលមនុស្សមួយពាន់នាក់មិនអាចលើករួច យកមកសន្ទប់ផ្លូវ ដែលទៅស្ថាននរក ។

ចាំងពីនោះមក, ស្ថាននរកនឹងស្ថានមនុស្សលោកក៏ស្ថិតនៅដាច់ដោយឡែកពីគ្នា ... ។

ទេវតាអ៊ិជសាណាគី ក៏ស្រែកទៅកាន់ព្រះនាងអ៊ិជសាណាមីវិញថា "ខ្ញុំសូមលាហើយ, ខ្ញុំសូមលា, យើងទាំងពីរនាក់ លែងឃើញមុខគ្នាពីត្រឹមនេះតទៅ" ។

ព្រះនាងអ៊ិជសាណាមីទ្រង់តបទៅស្វាមីវិញថា "បើលោកបោះបង់ចោលខ្ញុំៗ នឹងសម្លាប់មនុស្សលោក ក្នុងមួយថ្ងៃដាច់មួយពាន់នាក់ ។

ទេវតា អ៊ិជសាណាគីក៏តបទៅវិញថា "ខ្ញុំបង្កើតមនុស្ស ក្នុងមួយថ្ងៃមួយពាន់ប្រាំរយនាក់, ខ្ញុំសូមលាហើយ! ខ្ញុំសូមលា ហើយ! ។ នាងឯងជាទេវតាខាងស្ថាននរក ។

ទេវតាអ៊ិជសាណាគី ក៏បានទៅស្វែងរកប្រភពទឹកថ្លាមួយហើយក៏ចុះទៅងូតទឹកលប់ព្រះកេត្រ ដែលប៉ុកញើសហូរសស្រាក់ ហើយលាងខ្លួនឲ្យ

បរិសុទ្ធស្អាតផុតមន្ទិលសៅហ្មង ដែលលោកបានទៅកប់ប្រុសព្វនឹង មនុស្សជាប់ក្អិន អាសោចមកជាមួយផង ។

ទេវតាអ៊ិដសាណាគីក៏បានរកឃើញស្ទឹងមួយនៅកោះគីយូស៊ូ ហៅថា "ស្ទឹងក្រូចពោធិ៍សាត់", នៅទីនោះ, លោកបានលប់មុខលាងខ្លួន ឲ្យបរិសុទ្ធស្អាត ។

ស្រាប់តែមានអព្ភូតហេតុមួយជាថ្មី កើតមានឡើង ។ មានទឹកមួយដំណក់ស្រក់ពីព្រះនាសិកៈ កើតជាទេវតានាមសុសានូគឺទេវតាព្យុះសង្ឃរា ។ មានទឹកមួយដំណក់ស្រក់ពីព្រះនេត្រស្តាំ កើតជាទេវតាត្សុគីណូគាមី , គឺទេវតាព្រះចន្ទ ឬ ចន្ទទេព ។ ទឹកមួយដំណក់ស្រក់ពីព្រះនេត្រឆ្វេង, កើតជាទេវតាអាម៉ាតេរ៉ាសុ, ទេវធីតានៃព្រះអាទិត្យ ឬ សុរិយាទេវី ។

លោកអ៊ិដសាណាគីក៏បានបំពាក់មួយ ដល់ឱរៈទៅជានាងទេវធីតាមួយរូបទៀត ។ គឺនាងទេវធីតានេះ នឹងបានស្គាល់នូវសេចក្តីសប្បាយនិងសេចក្តីទុក្ខ ដែលព្រះនាងអ៊ិដសាណាមី បានទទួលពីកាលមុនមក ។

ទេវតាអ៊ិដសាណាគីក៏ពោលថា:"ឥឡូវនេះ ត្រូវនាងទេវធីតាឯងហើយ ! " ។

(មានត)

## កំណត់ដំណើរប្រវត្តិការណ៍

# ពិធីអនុសំវច្ឆរៈមហាសន្និបាតលើកទី១៤

# នៃមន្ត្រីសង្ឃសម្រាប់ឆ្នាំ ១៩៥៨ តាមផ្លូវព្រះសទ្ធម្ម

ក្នុងវត្តព្រះកែវមរកត

លោក ឯន - បិង់ រៀបរៀង

---

*ពិធីអនុសំវច្ឆរៈមហាសន្និបាតលើកទី ១៤ នៃមន្ត្រីសង្ឃសំរាប់ឆ្នាំ ១៩៥៨ ដូចមានសេចក្ដីរៀបរាប់តទៅនេះ ៖*

*កាលពីថ្ងៃទី ៧ មករា ១៩៥៨ វេលាម៉ោង ២ និង ១៤ នាទីរសៀល ក្នុងវិហារវត្តបទុមវតី មានការសន្និបាតនៃមន្ត្រីសង្ឃគណៈធម្មយុត្តមាន សម្ដេចព្រះសុធម្មាធិបតីសង្ឃនាយក, ព្រះមហាព្រហ្មមុនី ទេព អ៊ូ ព្រះអរិយកស្សប កែវ-អូច ជាដើម; ចំណែកឯសប្បុរសជនខាងគ្រហស្ថ មាន លោក មាស យឹង អនុរដ្ឋលេខាធិការក្រសួងធម្មការ, លោក យ៉ែម-យុត នាយកការិយាល័យ ក្រសួងធម្មការ, លោកគិម-ហុង នាយខុទ្ទកាល័យ, លោកយៀន ចឹម អគ្គលេខាធិការ នៃពុទ្ធសាសនបណ្ឌិត្យជាដើម ។*

លោកមាស-យ៉ន់ អនុរដ្ឋលេខាធិការ បានធ្វើគារវកិច្ចចំពោះព្រះសង្ឃ ហើយទូលសួរហេតុផ្សេងៗ តាមផ្លូវពុទ្ធសាសនា ដោយសេចក្តីរីករាយ ។ សម្តេចព្រះសុគន្ធាធិបតី សង្ឃនាយកគណៈធម្មយុត្ត ក៏មានថេរវាចាសំណេះសំណាលតបវិញ ដោយស្រោះស្រាយ ។

ដល់ម៉ោង ២ និង ៥៥ នាទី រសៀល លោក មាស យ៉ន់ អនុរដ្ឋលេខាធិការក្រសួងធម្មការ ព្រមទាំងសហការីទាំងឡាយ បានចេញពីវត្តបទុមវត្តីទៅកាន់ទីមហាសន្និបាតមួយដ៏ទូលាយក្នុងវត្តឧណ្ណាលោម ដែលមានសម្តេចព្រះមហាសុមេធាធិបតី ជ.ណាត សង្ឃនាយកគណៈមហានិកាយ, ព្រះពោធិវង្ស ហួត តាត ចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត, ព្រមទាំងមន្ត្រីសង្ឃ មេគណ អនុគណ គ្រប់ខេត្តក្នុងព្រះរាជាណាចក្រ មានព្រះវណ្ណរ័ត្ន អ៊ំ ងួត មេគណខែត្តបាត់ដំបងជាដើម ។ លោក មាស-យ៉ន់ អនុរដ្ឋលេខាធិការ ក្រសួងធម្មការ បានបន្ទំកាយធ្វើគារវកិច្ចហើយថ្លែងសេចក្តីប្រស្រ័យ ទាក់ទងខាងពុទ្ធសាសនា ចំពោះព្រះសង្ឃទាំងឡាយ ដោយសេចក្តីរីករាយ ។ បន្ទាប់មក សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ បានថ្លែងសន្ទនាមួយយ៉ាងវែងដាស់តឿនព្រះសង្ឃទាំងឡាយ ឲ្យខំយកព្រះទ័យទុកដាក់ សិក្សាធម្មវិន័យ ឲ្យបានម៉ត់ចត់ អស់រយៈវេលាចំនួន ២ ម៉ោង ។

ព្រឹកឡើង ថ្ងៃទី ៨ មករា ឆ្នាំ១៩៥៨ វេលាម៉ោង ៧ មានការជួបជុំព្រះសង្ឃជាឧឡារិក នៅមន្ទីរព្រះសទ្ធម្ម ក្នុងវត្តព្រះកែវមរកត, ព្រះសង្ឃទាំងឡាយបានសាធ្យាយន៍ ចំរើនសត្តប្បករណ៍ ទទួលថ្វាយព្រះរាជកុសល ចំពោះព្រះបិតរនៅៈចេតិយព្រះកែវមរកត ។

ម៉ោង ៨ និង ១៥ នាទី ឯកឧត្តមប្រធានរដ្ឋសភា, ឯកឧត្តមប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ, គណៈរដ្ឋមន្ត្រី អនុរដ្ឋលេខាធិការក្រសួងធម្មការ, សមាជិកសភាទាំងពីរ, លោកអ្នកឧកញ៉ាចៅហ្វាយក្រុង ព្រមទាំងឥស្សរជន ជាពុទ្ធបរិស័ទជាច្រើនទៀត បានទៅរង់ចាំក្រាបថ្វាយបង្គំគាល់ព្រះមហាក្សត្រទាំងពីរព្រះអង្គ នៅមុខព្រះវិហារ ព្រះកែវមរកត ។

នៅម៉ោង៨និង៣០នាទី ព្រះមហាក្សត្រទាំងពីរព្រះអង្គ ស្តេចយាងចេញពីព្រះបរមរាជវាំង ដោយមានព្រះរាជបរិពារ ហែហមអមព្រះរាជដំណើរផង ។

នៅពេលដែលព្រះមហាក្សត្រទាំងពីរព្រះអង្គ ស្តេចយាងចុះពីព្រះទីនាំងរថយន្ត លោក មាស យ៉ង់ អនុរដ្ឋលេខាធិការ ក្រសួងធម្មការ, ប្រធានសភាទាំងពីរ និងឯកឧត្តមនាយករដ្ឋមន្ត្រី បានក្រាបថ្វាយបង្គំនៅទីនោះ បន្ទាប់មក ក្រុមតូរ្យតន្ត្រីព្រះរាជទ្រព្យ បន្លឺបទនគររាជ ជាទីគោរព ហើយបន្លឺបទលីលា ជូនព្រះរាជដំណើរ ស្តេចយាងចូលទៅកាន់មន្ទីរព្រះសទ្ធម្មដែលមានមន្ត្រីសង្ឃទាំងឡាយ គង់នៅទីនោះ ។

ក្រោយដែលព្រះមហាក្សត្រទាំងពីរព្រះអង្គ ទ្រង់ថ្វាយបង្គំព្រះសង្ឃរួចហើយ ព្រះនរបតីទ្រង់មានព្រះរាជឧង្ការទទួលព្រះអំណរ ប្រស្រ័យយ៉ាងជិតស្និទ្ធទៅរកមន្ត្រីសង្ឃ ដោយព្រះភក្ត្រញញឹម ព្រមទាំងមានព្រះរាជហឫទ័យ ទ្រង់រីករាយយ៉ាងក្រៃលែង ហើយទ្រង់មានព្រះបន្ទូលស្សូរ-សីហនាទទៅកាន់មន្ត្រីសង្ឃ ដូចតទៅនេះ ៖

## ព្រះបន្ទូលស្សូរសីហនាទ

សូមពិតពុទ្ធដីកាព្រះតេជព្រះគុណគ្រប់ព្រះអង្គ !

ខ្ញុំព្រះករុណាមានសេចក្ដីសោមនស្សយ៉ាងពន្លឹក ដោយបានឃើញព្រះតេជព្រះគុណទាំងអស់ និមន្តមកកាន់មហាសន្និបាតនេះ ដើម្បីជ្រាបនូវកិច្ចការខ្លះ ខាងពុទ្ធចក្រនិងខាងអាណាចក្រ ដែលបានប្រព្រឹត្តទៅក្នុងបច្ចុប្បន្នកាលនេះ ។

ខ្ញុំព្រះករុណាមានសេចក្ដីសង្ឃឹមថា ព្រះតេជព្រះគុណគ្រប់ព្រះអង្គ នឹងអាចជួយគ្រោមគ្រែងព្រះពុទ្ធសាសនា នៅក្នុងប្រទេសកម្ពុជាយើង ឲ្យបានរីងរឹតតែចំរើនតទៅទៀត ហើយនឹងជួយឧបត្ថម្ភ ដល់រាជរដ្ឋាភិបាលក្នុងការបំរើមាតុប្រទេស ឲ្យបានទៅកាន់វឌ្ឍនភាព យ៉ាងឆាប់រហ័ស ។

ខ្ញុំព្រះករុណា សង្ឃឹមលើព្រះតេជព្រះគុណគ្រប់ព្រះអង្គ ក្នុងការរម្ងាប់

☛ (មានត)

# ដំណើរឧស្សាហការសហរដ្ឋអាមេរិក

នៃព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត ចាន់ហ្វាន

ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ក្រុងភ្នំពេញ

## រៀបរៀងដោយជា ទន់

សាស្ត្រាចារ្យទទួលភារៈខាងការបង្រៀនអង់គ្លេស នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ។

( តមក )

---

គ្រប់ជ្រៀន, ធ្វើការផ្សេងៗ ក្នុងហាងដំនួញធំៗ ក្នុងកន្លែងឯទៀតៗ ធ្វើប៉ូលិស ធ្វើការនេះធ្វើការនោះប្លែកៗគ្នា គ្មានទំនេរនៅផ្ទះចាំតែពេលជាំបាយទេ ។ អ្នកមានប្រពន្ធប្ដី ច្រើនតែធ្វើការដូចគ្នា ។ នៅក្នុងផ្ទះ. ធ្វើការផ្ទះទាំងអស់គ្នា, អាមេរិកាំងថ្នាក់ណា ក៏ត្រូវជួយធ្វើការប្រពន្ធក្នុងផ្ទះ លាងចាន, ជូតចាន រៀបចំទុកដាក់ របស់ទ្រព្យផ្សេងៗ ។ បានឮថា នៅសហរដ្ឋ មិនសូវមានគ្រួសារដែលមានឈ្នួល ឬ ខ្ញុំកំដរបាវព្រាវៈ បីទេ ព្រោះបុះបច្ច័យ គឺប្រាក់ ឬ លុយណាស់ ឈ្នួលម្នាក់ៗ ស៊ីថ្លៃយ៉ាងតិច ១ ដុល្លា ១ ម៉ោង ហើយតាមច្បាប់ ធ្វើការតែ ៨ ម៉ោងក្នុង ១ ថ្ងៃ តែប្រើហួសពីនេះ ត្រូវទូតថ្លៃ មួយជាពីរ ម៉ោះហើយកិច្ចការគ្រប់យ៉ាង ក្នុងផ្ទះ ប្រពន្ធនឹងប្ដីត្រូវធ្វើទាំងអស់គ្នា ទើបសុខជាននឹងគ្នា ។ ឡានក៏គ្មានសូហ្វ័រ

(អ្នកបរ) ដែរ ត្រូវបើកខ្លួនឯង ៗ ប្ដីក៏មានការធ្វើ មានប្រាក់បៀវត្ស គ្រាន់នឹងចាយ, ប្រពន្ធក៏មានការធ្វើ មានប្រាក់ថ្ងៃ ប្រាក់ខែដែរ ផ្លូវការ មានឡានមួយម្នាក់ផងទៀត មានអធិបតេយ្យភាពទាំងពីរ តែពេលមិនសូវ គ្នា មិនបានជានាទីនឹងគ្នាយូរទេ មុខជាមានការប្រេះឆារពុំខាន ៗ ដោយ ហេតុនេះ បានដឹងថា ប្ដីប្រពន្ធអាមេរិកាំង ច្រើនតែលះលែងគ្នា ដោយ ការមិនមានគុណភាព ក្នុងកិច្ចការ គឺការមិនស្របស្រួលនឹងគ្នា ដោយ កាយពាននឹងដោយចិត្ត ៗ

ផ្នែកខាងផ្លូវសាសនា អាមេរិកាំងមានសេរីភាព, សេរីភាពក្នុង សាសនាអ្នកក្ដាន តាមសេចក្ដីពេញចិត្ត, តែសង្កេតឃើញថា ប្រជាជាតិនេះ កាន់គ្រិស្តសាសនាទាំងអស់ ប៉ុន្តែនិកាយផ្សេងគ្នាប៉ុណ្ណោះ ៗ ក៏ប៉ុន្តែ សាសនាគ្រិស្ត មិនមែនជាសាសនារបស់រដ្ឋទេ គេបើកផ្លូវសាសនាឲ្យ ទូលាយសំរាប់ប្រជាជន ៗ ប្រជាជនមានជំនឿយ៉ាងណា ឬមានទំនោរ យ៉ាងណា ដើម្បីញុំាងសាសនាឲ្យចំរើន ក៏តាមតែសេចក្ដីត្រូវការ របស់ ប្រជាជន ៗ នៅក្នុងភូមិ ឃុំ ស្រុក ខេត្តនិងទីក្រុងធំៗ យើងសង្កេតឃើញ មានវិហារគ្រិស្តសាសនាជាច្រើន ដែលគេហៅថា Church (ឆឺច-ឆ៍) ហើយ មានតិចខ្លះមានសាលាឈ្នួលថែមទៀត ដូចជា សាលាបឋមសិក្សាមធ្យ- មសិក្សាវិទ្យាល័យ និងមហាវិទ្យាល័យ ៗ Church នីមួយៗ ជាមជ្ឈដ្ឋាន

សំរាប់អប់រំខាងផ្លូវចិត្ត ក្នុងមួយអាទិត្យ ឬ មួយសប្តាហ៍ គេទៅ Church ម្តង ដើម្បីស្តាប់លោកសង្ឃ របស់គេទេសនាប្រៀនប្រដៅធម៌អាថ៌ ។ មាន Church ខ្លះទៀត មានសាលាសំរាប់អប់រំក្មេងប្រុសស្រី ហៅថា Sunday School (ស័នដេស្គូល) ។ នៅក្នុងសាលារៀនទានា តាំងពីថ្នាក់ដាច់ក្រោម ដល់ថ្នាក់ដាច់លើ គេមានថ្នាក់រៀនពិសេសខាងសាសនា ។ ចុះដឹង ឯងថា គេបង្រៀនសាសនាសាកល គឺសាសនាទាំងអស់ ប្រៀបធៀបទៅ គ្រិស្តសាសនា (ដូចជានៅសាលាយើង បង្រៀនសាសនាទាំងអស់ ប្រៀបធៀបនឹងព្រះពុទ្ធសាសនា ដូច្នោះដែរ) ។ ក្រៅពីនេះ គេមានសមាគមយុវជនគ្រិស្តសាសនា ហៅថា Young Mem Christion Association Y.M.C.A. និងសមាគមយុវគ្រិស្តសាសនា Y.W.C.A. ដែលជាអង្គការសំរាប់អប់រំយុវនរៈនិងនារី ផ្នែកខាងផ្លូវសាសនា ។ អង្គការនេះបាន-ចំរើនឡើងជាលំដាប់ គេមានសង់កន្លែងធំៗ សំរាប់ជួលសំណាក់ផង សំរាប់អប់រំ ខាងផ្លូវសាសនាផង ហៅថា Y.M.C.A. ឬ Y.W.C.A. ។

សហរដ្ឋអាមេរិក មិនមានសាសនាសម្រាប់សហរដ្ឋទេ, ប៉ុន្តែសាសនាគ្រិស្ត ជាសាសនាដែលអាមេរិកជនទូទៅ ទទួលគោរពប្រតិបត្តិតាម ជាប់ជាទំនៀមពីបរមបុរាណមក ។ សព្វថ្ងៃនេះ សាសនាគ្រិស្តបែកបញ្ចេញទៅជាច្រើននិកាយ ប៉ុន្តែឯនិកាយដែលធំៗ មានមនុស្សទទួលកាន់ច្រើន

ជាងគេ មានតែបី គឺ និកាយប្រូតិស-ស្តង់ the Protestant មានប្រជាជនជាសមាជិក ចំនួនប្រមាណពី ៥០ ទៅ៦០ លាននាក់ ជានិកាយធំជាងគេបំផុត; និកាយរ៉ូម៉ាំងកាតូលិក the Romam Catholic មានប្រជាជនជាសមាជិកប្រមាណជា ៧០ ឬ ៨០ លាននាក់; និកាយជ្វីស្ហ the Jewish មានប្រជាជនជាសមាជិក ប្រមាណជា ៥ លាននាក់; រីឯនិកាយតូចតាចរាយរងដែលបែកចេញពីប្រូតិស-ស្តង់ទៅទៀត មានច្រើនណាស់ ពុំអាចស្គាល់អស់ឡើយ ។

ទីកន្លែងដែលគេគោរពប្រតិបត្តិសាសនា ហៅថាឆឺច-ឆ៍ Church ។ ឆឺច-ឆ៍ និងអគ្គការទំនុកបំរុងខាងសាសនាទាំងឡាយកើតឡើង ដោយសេចក្ដីស្ម័គ្រចិត្ត ឬ ពេញចិត្តនៃប្រជាជន, រដ្ឋការរដ្ឋ ឬ រដ្ឋការសហរដ្ឋ មិនមានជួយទំនុកបំរុងអ្វី សូម្បីបន្តិចបន្តួច ចំពោះកិច្ចការខាងសាសនាឡើយ.ច្បាប់ធានាអះអាង ចំពោះជនទាំងអស់ ចំពោះសេរីភាពខាងប្រតិបត្តិសាសនា តាមចិត្តជ្រើសរើស ។ រីឯថ្ងៃបុណ្យសម្រាប់សាសនា ដែលប្រជាជនគ្រប់គ្នាទទួលស្គាល់ មានតែមួយប៉ុណ្ណោះ ហៅថា Chrismas ជាថ្ងៃបុណ្យធំដែលគេធ្វើគ្រប់ទីកន្លែង នៅថ្ងៃទី ២៥ ធ្នូ រៀងរាល់ឆ្នាំ ត្រូវដល់ថ្ងៃមរណៈ នៃព្រះគ្រិស្ត ។

ពួកជនអ្នកកាន់គ្រិស្តសាសនាជាតិអាមេរិកាំង តែងមានសេចក្ដី

ស្រេកឃ្លានចង់ដឹងអំពីសាសនានានា និងអំពីរបៀបកាន់សាសនានៅប្រទេសផ្សេងៗណាស់, កាលណាមានអ្នកដំណើរទៅពីបរទេស គេតែងអញ្ជើញឲ្យទៅនិយាយអំពីសាសនា អំពីរបៀបកាន់សាសនា អំពីការសិក្សាផងដើមនៃបរទេសនោះៗ ព្រោះហេតុនោះ ព្រះតេជព្រះគុណព្រះពោធិវង្សប្រធានពុទ្ធិកវិទ្យាល័យ, កាលដែលនិមន្តទៅទស្សនាសហរដ្ឋ បានត្រូវអាមេរិកជននិមន្តទៅថ្លែងការអំពីប្រទេសកម្ពុជា ការសិក្សា និងព្រះពុទ្ធសាសនា ព្រមទាំងរបៀបកាន់ព្រះពុទ្ធសាសនា នៃកម្ពុជជន ជាច្រើនលើក ៗ ក្នុងលើកនីមួយៗមានការចោទសួរប្រស្នាផ្សេងៗ តាមការចង់ដឹងរបស់គេៗ របៀបនេះជាវិធីសិក្សាមួយយ៉ាងដែរ ព្រោះគេអាចដឹងរបៀបស្រុកទេស និងរបៀបសាសនានៃនានាប្រទេស តាមអ្នកដំណើរបរទេស ។

ក្រៅពីគ្រិស្តសាសនា, សហរដ្ឋអាមេរិក មានប្រជាជនមួយចំណែកតូច ជាអ្នកកាន់ពុទ្ធសាសនា លទ្ធិមហាយាន ។ ពុទ្ធសាសនាលទ្ធិមហាយាន បាននាំចូលទៅដោយជនជាតិជប៉ុននិងចិន មានវិហារពុទ្ធសាសនាជាច្រើនកន្លែងដែរ គេហៅថា Buddhist Church ឬ Buddhist Temple តែឯពុទ្ធសាសនិកជនមហាយានិកទាំងនោះ ឃើញច្រើនតែជាតិជប៉ុន មិនសូវមានជាតិអាមេរិកាំងទេ មានប្រទះអាមេរិកាំងពុទ្ធិកៈមួយៗ ។ នៅហូណូលូលូ នៃកោះហាវ៉ៃ និងសានហ្វ្រាំងស៊ីស្កូ មានវិហារពុទ្ធសាសនាមហាយានិក ច្រើនជាងកន្លែងឯទៀតក្នុងសហរដ្ឋ ។

នៅនារដ្ឋធានីវ៉ាស៊ីនតុន ឌីស៊ី មានក្រុមជន ១ ក្រុម ជាអ្នកកាន់ពុទ្ធសាសនាលទ្ធិហីនយាន មានសមាជិក ជាតិអាមេរិកាំងខ្លះ ជាតិសៀមខ្លះ ជាតិភូមាខ្លះ ជាតិយួនខ្លះ គេហៅថា សមាគមមិត្តពុទ្ធសាសនិកហីនយានិក នៅវ៉ាស៊ីនតុន The Association of Friends of Buddhism in Washinqton D.C. ។ សមាគមនេះ មិនទាន់មានទីសំណាក់ការប្រាកដប្រជានៅឡើយសព្វថ្ងៃ វេលាប្រជុំគ្នាម្ដងៗ ជួនកាលប្រជុំគ្នានៅស្ថានទូតថៃ ឬនៅស្ថានទូតភូមា ។ លោកប្រធានសមាគមជាជាតិអាមេរិកាំង, ក្នុងដំណើរទស្សនាសហរដ្ឋ ព្រះតេជព្រះគុណព្រះពោធិវង្ស បានទទួលនិមន្តទៅឆាន់ និងទេសនា នៅស្ថានទូតថៃម្ដង នៅស្ថានទូតភូមាម្ដង, ព្រះតេជព្រះគុណបានបួងសួងចំពោះគុណព្រះរតនត្រ័យ សូមឲ្យសមាគមមិត្តពុទ្ធសាសនិកហីនយានិក នៅវ៉ាស៊ីនតុន បានចំរើនរុងរឿងតទៅអនាគត ។

ដំណើរទស្សនាការសហរដ្ឋអាមេរិក នៃព្រះតេជព្រះគុណចាន់ញាន ពុទ្ធិកវិទ្យាល័យ បានចាប់ផ្ដើម តាំងពីថ្ងៃសៅរ៍ ១ កើត ខែកត្តិក ឆ្នាំវក អដ្ឋស័ក ពុទ្ធសករាជ ២៤៩៩ ត្រូវនឹងថ្ងៃទី ៣ វិច្ឆិកា ស ១៩៥៥ វេលាម៉ោង ២·៣០ រសៀល រហូតដល់ថ្ងៃចន្ទ ១៣ រោចខែបុស្ស ឆ្នាំដ ដែល គឺថ្ងៃទី ២៣ មករា ១៩៥៦ វេលាម៉ោង ១០ ព្រឹក ទើបព្រះតេជព្រះគុណបាននិមន្តត្រឡប់មកដល់ក្រុងភ្នំពេញវិញដោយសុវត្ថិភាព ។

ចប់ ។

# ពិធីបុណ្យទទួលព្រះត្រៃបិដកជាភាសាទីបេត៍
# នៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ

---

កាលពីថ្ងៃអង្គារ ទី ១៥ តុលា ១៩៥៧ ម៉ោង ៩ ព្រឹក នោះបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ មានពិធីបុណ្យទទួលព្រះត្រៃបិដក ជាភាសាទីបេត៍ ចំនួន ២០ ក្បាលដែលលោកកេនយ៉ូ ម៉ាត់ស៊ុមុរ៉ា សមាជិកសភាតំណាងរាស្ត្រនិងអតីតរដ្ឋមន្ត្រី ប្រទេសជប៉ុនបានជូនជាអំណោយ ចំពោះពុទ្ធសាសនបណ្ឌិត្យ ។

ក្នុងឱកាសនោះ, មានឥស្សរជនទាំងបព្វជិតទាំងគ្រហស្ថ ព្រមទាំងបរទេស បាននិមន្ត និងអញ្ជើញមកកាន់ពិធីនេះ ។

ខាងបព្វជិត, មានសម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត ជោតញ្ញាណោ សង្ឃនាយកគណៈមហានិកាយ វត្តឧណ្ណាលោម, សម្តេចព្រះសុធម្មាធិបតី កុល-ទេស, សង្ឃនាយក គណៈធម្មយុត្តិកវត្តបទុមវតី, ព្រះពោធិវង្ស ហួត-តាត វជិរប្បញ្ញោ ចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត, ពជាគណៈ បានាទុក្រម, ។

ខាងគ្រហស្ថ, មានសហជីវិន ម៉ាស-យ៉េង អនុរដ្ឋលេខាធិការក្រសួងធម្មការ, លោកៈយៀន-ចឹម អគ្គលេខាធិការ ក្រុមពុទ្ធសាសនបណ្ឌិត្យ,

លោកសម-ញាណ, ប្រធានពុទ្ធិកសមាគមកម្ពុជរដ្ឋ, លោកទ្រិញ-ពាំញ តំណាងរាស្ត្រ, លោកពាយ-ប៊ុក ប្រធានសមាគមមិត្តពុទ្ធិកវិទ្យាល័យ, បុគ្គលិកក្រសួងធម្មការ, ពុទ្ធសាសនបណ្ឌិត្យ និងភ្ញៀវជនឯទៀតជាច្រើន ។

ខាងបរទេស មានឯកឧត្តម យុស៊ីយូកា ឯកអគ្គរាជទូតប្រទេសជប៉ុនប្រចាំប្រទេសកម្ពុជា និងភ្ញៀវជនជប៉ុន ៦ នាក់ ។

ម៉ោង ៩ និង ៥ នាទី, ឯកឧត្តម យុស៊ីយូកា ឯកអគ្គរាជទូតបានថ្លែងនូវសន្ទកថាមួយដូចតទៅនេះ ៖

សម្តេចសង្ឃនាយកទាំងពីរគណៈ !

ឯកឧត្តម !

លោក-អ្នកទាំងឡាយ !

ខ្ញុំព្រះករុណា ខ្ញុំបាទមានចិត្តសោមនស្សជាយ៉ាងក្រៃពេកដោយបានមកប្រជុំក្នុងពិធីបុណ្យ ប្រគល់ព្រះត្រៃបិដក ជាភាសាទីបេត៍ ចំនួន ៦០ក្បាល ជាអំណោយដល់លោករដ្ឋមន្ត្រីក្រសួងធម្មការ, ចំពោះព្រះភក្ត្រសម្តេចសង្ឃនាយក ទាំងពីរគណៈ និងមន្ត្រីសង្ឃទាំងឡាយ ។

ឯកឧត្តមៈកនហ្ស ម៉ាត់ស៊ុម៉ូ អតីតរដ្ឋមន្ត្រី និងសមាជិក តំណាងរាស្ត្រប្រទេសជប៉ុនដែលបានកំណត់ថា និងអញ្ជើញមកទស្សនានៅប្រទេសកម្ពុជា ពីខែមីនាមុននេះ, ក្នុងឋានៈជា ប្រេសិតពិសេសនៃនាយករដ្ឋមន្ត្រី

ប្រទេសជប៉ុន លោកតាន់ហ្សង់ អ៊ីស្ហ៊ីបាស្ហ៊ី ហើយអាក់ខាន មិនបានអញ្ជើញមកវិញ ដោយមានវិតក្កបំណង ចង់ធ្វើឲ្យការគមនាគមន៍ ដោយមេត្រីភាព រវាងប្រទេសជប៉ុន និងប្រទេសកម្ពុជាឲ្យកាន់តែមានសភាពមាំមួនឡើង, បានចាត់ឲ្យខ្ញុំទទួលភារកិច្ច ជូនជាអំណោយចំពោះរដ្ឋាភិបាលខ្មែរនូវព្រះត្រៃបិដក ២០ សៀវភៅជាភាសាទីបេ (ក្បួនច្បាប់ពុទ្ធសា-សនាទីបេ) ដែលបង្ហាញស្នាដៃនៃការសិក្សាព្រះត្រៃបិដកទីបេ មានលោកកេនហ្យូ-ម៉ាត់សុមុរា ជាអគ្គនាយកបានបោះពុម្ពផ្សាយនៅទីក្រុងប៉េកាំង ។

ព្រះត្រៃបិដកដែលបោះពុម្ពទាំងអស់មានចំនួន ១៥០ សៀវភៅ នៅសល់ ១៣០ សៀវភៅទៀត ដែលនឹងត្រូវបោះពុម្ពនៅពេលក្រោយ ។ ខ្ញុំព្រះករុណា ខ្ញុំបាទបានទទួលសៀវភៅទាំងនេះ នឹងជូនមករដ្ឋាភិបាលខ្មែរតាមលំដាប់មិនហ៊ានខាន ។ ខ្ញុំព្រះករុណាខ្ញុំបាទមានអំណរពន់ពេក, បើសៀវភៅនេះអាចនឹងជួយចំពោះវិទ្យាសាស្ត្រ សាសនា និងគណៈព្រះសង្ឃពុទ្ធសាសនាខ្មែរឲ្យមានវឌ្ឍនភាពតទៅអនាគត ។

បន្ទាប់មក លោកមាស-យ៉ង់ អនុរដ្ឋលេខាធិការ ក្រសួងធម្មការ បានថ្លែងនូវសុន្ទរកថាមួយដូចតទៅនេះ

ឯកឧត្តម អគ្គរាជទូត !

គឺជាកិត្តិយសដ៏ឧត្តម និងសេចក្តីរីករាយចិត្តជាយ៉ាងជ្រាលជ្រៅដោយ

ខ្ញុំបាទបានទទួលនូវព្រះត្រៃបិដក ជាភាសាទីបេតដែលឯកឧត្តម កេនហ្សុ មាត់ស៊ុម៉ុក សមាជិកនៃសភាដំណាងរាស្ត្រ និងអតីតរដ្ឋមន្ត្រីប្រទេសជប៉ុនបានជូនជាអំណោយចំពោះរាជរដ្ឋាភិបាល ប្រទេសកម្ពុជាក្នុងថ្ងៃនេះដោយមហាសប្បុរស។ គឺគម្ពីរនេះឯង ដែលឯកឧត្តមបានអញ្ជើញមកផ្ទាល់ប្រគល់ ក្នុងនេះយើងសូមថ្លែងនូវអំណរគុណ ដោយចិត្តស្មោះស្ម័គ្រចំពោះឯកឧត្តម ។

គ្មានពុទ្ធសាសនិកជនណាមួយមិនជ្រាបថា គម្ពីរធំសម្បើមអស្ចារ្យដែលមានអត្ថបទពិសិដ្ឋ គឺព្រះត្រៃបិដកនេះឯង ជាគម្ពីរសំខាន់នៃព្រះពុទ្ធសាសនា គឺជាអត្ថបទដែលពណ៌នាអំពីធម៌ និងវិន័យព្រះពុទ្ធសាសនា ។ ព្រះត្រៃបិដកនេះមានសារៈសំខាន់ណាស់, បានជាប្រទេសដែលនិយមកាន់ព្រះពុទ្ធសាសនានីមួយ ៗ មានបំណងចង់បានជាកម្មសិទ្ធិរបស់ខ្លួនហើយយល់ថា គម្ពីរព្រះត្រៃបិដកសម្រាប់ជាតិខ្លួននោះ ជាយ៉ាងនៃវិជ្ជាសាស្ត្រ ខាងសាសនាដែលប្រទេសនោះទុកជាការចាំបាច់ជាបឋម ។

គម្ពីរព្រះត្រៃបិដកជាភាសាទីបេត ក៏គង់តែមានតម្លៃពេញលេញទៅតាមក្បួនច្បាប់ព្រះពុទ្ធសាសនា ។ គម្ពីរនេះជាផលនៃកិច្ចការពួកវិញ្ញូជន ក្នុងវិជ្ជាស្ថានការសិក្សា ព្រះត្រៃបិដកទីបេតដែលមានឯកឧត្តមកេនហ្សុ-មាត់ស៊ុម៉ុក ជាអគ្គនាយក ជាស្ថាប័នមួយធំសម្បើម ព្រមទាំង

សភាពថ្លៃថ្នូរ របស់ប្រជាជាតិដ៏ឧត្តមមួយនៃទ្វីបអាស៊ី ។

ព្រះត្រៃបិដកនេះ ដែលបោះពុម្ពដោយអក្សរមានលំអឆើតយ៉ាងក្រៃលែង បញ្ជាក់ឲ្យឃើញថា មានសភាពស្ញប់ស្ញែងដ៏អស្ចារ្យ បើតាមសំនួនសៀវភៅប្រហែលគ្នានឹងព្រះត្រៃបិដកខ្មែរ ដែលកំពុងបោះពុម្ពសព្វថ្ងៃ ជាការផ្សាយមួយកើតឡើងដោយឆន្ទៈ នៃសង្ឃបណ្ឌិតរបស់យើងដែលមានអង្គខ្លះគង់នៅទីនេះ ។ ព្រះត្រៃបិដកដែលឯកឧត្តមបានធ្វើអំណោយមកយើង ព្រមទាំងភាគឯទៀតជាខាងក្រោយ ដរាបដល់ចប់គ្រប់ជា ១៥០ សៀវភៅ យើងថែរក្សាទុកជាវត្ថុយ៉ាងថ្លៃថ្លា ។ គម្ពីរនេះ នឹងអាចជួយឲ្យវិជ្ជាខាងសាសនា មានវឌ្ឍនភាពតទៅអនាគត ហើយជាប្រភពតែមួយដ៏ប្រសើរនៃក្បួនច្បាប់ព្រះពុទ្ធសាសនា ដែលប្រជារាស្ត្រនិយមកាន់ព្រះពុទ្ធសាសនាទាំងឡាយតែងស្រាវជ្រាវ ដើម្បីប្រយោជន៍ចំពោះព្រះសង្ឃ សុភមង្គល ចំពោះមនុស្សជាតិទាំងឡាយ ព្រមទាំងសន្តិភាពលោក ។

ការដែលឯកឧត្តម បានប្រគល់ជាអំណោយនូវព្រះត្រៃបិដកនេះ ចំពោះរាជរដ្ឋាភិបាលប្រទេសកម្ពុជា ឈ្មោះថា ឯកឧត្តមបានប្រគល់នូវសារវត្ថុដ៏វិសេសវិសាល ក្នុងដែនវប្បធម៌ និងសាសនា ។ អំណោយនេះដែលបញ្ជាក់ឲ្យឃើញសុទ្ធចិត្ត នឹងបំណងដ៏បរិសុទ្ធនៃប្រជារាស្ត្រជប៉ុន

មកកាន់ប្រជារាស្ត្រខ្មែរ ទុកជាកាយវិការមួយ មិនមែនគ្រាន់តែប្រកបដោយមហាសប្បុរស ដែលមានន័យដ៏ខ្ពង់ខ្ពស់បំផុតនោះទេ ថែមទាំងជានិមិត្តរូបជាក់ច្បាស់ នៃការប្រកបដោយសម្បណ៌ិការពមហាប្រទេស ជាកល្យាណមិត្តមួយចំពោះសហការវប្បធម៌ រវាងប្រជារាស្ត្រយើងទាំងពីរ ។

ក្នុងនាមនៃរាជរដ្ឋាភិបាលប្រទេសកម្ពុជា នាមគណៈសង្ឃខ្មែរនិងនាមខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងនូវអំណរគុណដ៏ជ្រាលជ្រៅ ចំពោះឯកឧត្តម អំពីសារប្រយោជន៍វិទ្យាសាស្ត្រ និងសាសនាដែលឯកឧត្តមនិងប្រជារាស្ត្រជប៉ុន មានឯកឧត្តម កេនហ្សូម៉ាត់ស៊ុក ជាអ្នកតំណាងបានធ្វើ ចំពោះប្រជារាស្ត្រខ្មែរ ដោយជាក់ស្តែងគឺអំណោយដ៏ថ្លៃថ្លានៃគម្ពីរនេះ ។ កាយវិការនេះ ខ្ញុំជឿជាក់ចំពោះខ្លួនខ្ញុំហើយ ខ្ញុំសូមបញ្ជាក់ចំពោះឯកឧត្តមថា មុខជាជនជាតិខ្មែរ ក្នុងព្រះរាជអាណាចក្រទាំងមូល នឹងពេញចិត្តជាទីបំផុត ក្នុងនាមនៃជនជាតិខ្មែរទាំងនោះ ខ្ញុំសូមថ្លែងនូវអំណរគុណជាចុងក្រោយម្តងទៀតចំពោះឯកឧត្តម ។

លុះចប់សន្ទកថាហើយ ព្រះសង្ឃក៏សូត្រជ័យន្តោ ជូនពរជ័យមង្គលសិរីសួស្តីចំពោះឯកឧត្តមអគ្គរាជទូតប្រទេសជប៉ុនប្រចាំប្រទេសកម្ពុជា ។

រួចទើបមានពិធីជប់លៀងនំទឹកតែ ទឹកក្រូចជាកិត្តិយស ។

ពិធីបុណ្យនេះបានបញ្ចប់នៅម៉ោង ៩ និង៣០នាទី ។

# ពិធីទទួលព្រះត្រៃបិដកអក្សរចិន

ស្រី-អ៊ី រៀបរៀង

បណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ មានព្រះត្រៃបិដក ៨ ចប់ គឺ ព្រះត្រៃបិដកអក្សរខ្មែរ - សៀម - មន - ភូមា - លង្កា - អំរុប - ទីបេត៍ ចិនប្រជាមានិត និងចិនជាតិនិយម ១ ទៀត ជាគម្រប់ ៩ ដែលយើងទើបនឹងបានទទួលនៅពេលថ្មីៗនេះ ៖

នៅថ្ងៃ ១៨ កុម្ភៈ ១៩·៨ ពេលព្រឹក ម៉ោង ៩ នៅមន្ទីរពុទ្ធ-សាសនបណ្ឌិត្យ ក្រសួងធម្មការ មានធ្វើពិធីមួយយ៉ាងអធិកអធឹក ដោយឯកឧត្តមកុងស៊ុលចិនជាតិនិយម ប្រចាំប្រទេសកម្ពុជា បានធ្វើអំណោយសៀវភៅព្រះត្រៃបិដកអក្សរចិន ៤០ ក្បាល ដែលជាអំណោយរបស់សម្តេច ទៀវិងពុទ្ធ កាន់ដូវ៉ា " ហូទីកេទូ " តាមរយៈរដ្ឋាភិបាលនៃសាធារណរដ្ឋចិន មកជាសម្បត្តិរបស់មន្ទីរពុទ្ធសាសនបណ្ឌិត្យ ក្រសួងធម្មការ ។

នៅឱកាសនោះ លោកជ័យ-ល្អ រដ្ឋមន្ត្រីក្រសួងធម្មការ សម្តេចព្រះសង្ឃនាយកទាំងពីរគណៈ ព្រះពោធិវង្ស ហួត-តាត ចាងហ្វាង ព្រះមហាព្រហ្មមុនី ចាងហ្វាងរង ព្រមទាំងសាស្ត្រាចារ្យនៃពុទ្ធិកវិទ្យាល័យព្រះ

សុពម្រឹត ព្រះសង្ឃក្រុមជំនុំព្រះត្រៃបិដកនិងឯកឧត្តម សម-ញាណ អនុ-ប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ ព្រមទាំងមន្ត្រីក្រសួងធម្មការ ក្រុមពុទ្ធសាសនបណ្ឌិត្យ ជាច្រើនរូប បាននិមន្ត អញ្ជើញមកជួបជុំនៅមន្ទីរពុទ្ធសាសនបណ្ឌិត្យ យ៉ាងកុះករ ។

វេលាព្រឹក ម៉ោង ៩ គត់ ឯកឧត្តមកុងស៊ុលចិន និងសហការីរបស់លោកព្រមទាំងលោកសង្ឃចិន ៥ អង្គ បានអញ្ជើញ បាននិមន្តមកដល់ ៗ ក្រោយដែលបានធ្វើគារវកិច្ច ដោយពក់ពាក់ទៅវិញទៅមក ឯកឧត្តមកុងស៊ុលចិន បានចាប់ផ្ដើមថ្លែងសន្ទរកថា ជាភាសាចិន រួចប្រែជាភាសាបារាំង រៀបរាប់អំពីហេតុ ដែលនាំឲ្យមានការធ្វើអំណោយសៀវភៅព្រះត្រៃបិដក ៤០ ក្បាលនេះ ។ ឯសន្ទរកថានោះ បានប្រែមកជាភាសាខ្មែរ មានសេចក្ដីដូចតទៅ ៖

## សន្ទរកថា

## របស់លោកកុងស៊ុលប្រទេសចិនថ្លែងក្នុងឱកាសប្រគល់

## សៀវភៅព្រះត្រៃបិដកមកព្រះរាជរដ្ឋាភិបាល

## ប្រទេសកម្ពុជា

ឯកឧត្តមរដ្ឋមន្ត្រី !

ក្នុងថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយពន់ប្រមាណដោយបានទទួលឯកសិទ្ធិ មកជាតំណាងពុទ្ធិកសមាគមនៃប្រទេសខ្ញុំ ដើម្បីប្រគល់សៀវភៅព្រះត្រៃបិដកចំនួន ៤០ ក្បាល មកព្រះរាជរដ្ឋាភិបាលប្រទេសកម្ពុជា ដែលមានឯកឧត្តមជាតំណាង នៅចំពោះព្រះភក្ត្រសម្តេចព្រះសង្ឃ-នាយកទាំងពីរគណៈ និងមន្ត្រីសង្ឃទាំងឡាយ ។

សៀវភៅទាំងនេះមានកត់ត្រានូវពាក្យប្រៀនប្រដៅទាំងឡាយនៃព្រះសម្មាសម្ពុទ្ធបរមគ្រូ ដែលជាស្នាដៃមួយ ដ៏មានសារៈសំខាន់ក្រៃលែង ដោយអ្នកប្រាជ្ញខាងសាសនានៃប្រទេសខ្ញុំបានបកប្រែមកនេះ ។ គម្ពីរទាំងនេះជារបស់ក្រណាស់ ដែលប្រទេសកាន់ព្រះពុទ្ធសាសនាទាំងឡាយក្នុងសាកលលោកជឿជាក់នូវតំលៃខាងសតិអារម្មណ៍ ។

អាស្រ័យហេតុនេះហើយ បានជាសម្តេច ឡេវីងពុទ្ធ-កាន់ជួរពាំ "ហ្វូខុកេខូ" បានស្នើសុំទៅរដ្ឋាភិបាលសាធារណរដ្ឋខ្ញុំថា សូមតម្រូវឲ្យខ្ញុំទទួលភារៈជាតំណាងប្រទេសចិន ដើម្បីប្រគល់សៀវភៅដ៏ឧត្តុង្គឧត្តមនេះ មកព្រះរាជរដ្ឋាភិបាលប្រទេសកម្ពុជា ។ កិច្ចនេះធ្វើឡើងស្របទៅតាមពាក្យសន្យារបស់សម្តេចឡេវីងពុទ្ធ កាលសម្តេចនិមន្តមកទស្សនាប្រទេស

កម្ពុជា ក្នុងខែទសកាមុននោះ ហើយទាំងមានបំណងចង់ពង្រីងបំណង មេត្រីភាព ដែលធ្លាប់មានមកអស់កំឡុងជាច្រើន សតវត្សរ៍មកហើយ រវាងជនជាតិចិននឹងជនជាតិខ្មែរ ។

ឯកឧត្តម ខ្ញុំប្រាកដជានឹងកើតសេចក្តីរីករាយខ្លាំងក្លាជាងនេះទៅទៀត បើសិនជាសៀវភៅព្រះត្រៃបិតកទាំងនេះ ដែលជាប្រភពពាក្យប្រៀនប្រដៅនៃព្រះពុទ្ធជាម្ចាស់ អាចជាជំនួយជួយបង្កើនសាសនគតិបណ្ឌិត ដែលពលរដ្ឋក្នុងប្រទេសឯកឧត្តមភាគច្រើន បានប្រព្រឹត្តតាមស្រាប់ហើយ ព្រោះពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ សុទ្ធតែច្បាប់សម្រាប់ញ៉ាំងសេចក្តីល្អ ដល់សាសនសង្គមពិភពលោក និងសុភមង្គលដល់មនុស្សជាតិទូទៅទាំងអស់ ។

សម្តេច ! អស់លោកទាំងឡាយ !

នៅទីបញ្ចប់នេះ ខ្ញុំព្រះករុណា, ខ្ញុំ សូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅនិងជិតស្និទ្ធ ចំពោះសម្តេច ព្រះភេជព្រះគុណ និងអស់លោកទាំងឡាយ ដែលបាននិមន្តនិងអញ្ជើញមកក្នុងទីនេះ ដើម្បីញ៉ាំងពិធីនេះ ឲ្យទៅជាមានសភាពដ៏រុងរឿង ។

តពីនោះមក លោកកៃយ-លុត រដ្ឋមន្ត្រីក្រសួងធម្មការ បានថ្លែងសន្ថិថាជាភាសាខ្មែរ រួចប្រែជាភាសាបារាំង ឆ្លើយតបទៅវិញ មាន

សេចក្តីដូចតទៅនេះ ៖

## សន្ទរកថា

### របស់លោក ភាយ-ល្មុត រដ្ឋមន្ត្រីក្រសួងធម្មការ

សូមក្រាបថ្វាយបង្គំសម្តេច

សូមជំរាបឯកឧត្តម

សូមគោរពព្រះតេជព្រះគុណទាំងឡាយ

សូមជំរាបអស់លោកទាំងឡាយ

ជាដំបូង ខ្ញុំព្រះករុណា-ខ្ញុំ សូមសំដែងនូវសេចក្តីគោរពនមស្ការថ្វាយបង្គំចំពោះសម្តេចនៃគណៈមហានិកាយ និងធម្មយុត្ត ទាំងពីរព្រះអង្គ និងសូមសំដែងនូវអំណរគុណ ដ៏បរិសុទ្ធចំពោះឥស្សរជនជាបញ្ជិតនិងជាគ្រហស្ថ ដែលបាននិមន្ត - អញ្ជើញមកកុះករ នាំឲ្យពិធីនេះមានរស្មីរឹតតែរុងរឿងឡើងក្នុងពេលនេះ ។

ឯកឧត្តម លោកកុងស៊ុល !

ជាកិត្តិយសមួយធំដល់ខ្លួនខ្ញុំ ហើយដោយសេចក្តីរីករាយជាទីបំផុតនៅនាថ្ងៃនេះ ខ្ញុំបានធ្វើជាប្រធាននៃពិធីទទួលសៀវភៅព្រះត្រៃបិដកចំនួន ៤០ ក្បាល ជាភាសាចិន ដែលឯកឧត្តមបានខ្វល់ខ្វាយនាំមកប្រគល់ជូនក្រសួងធម្មការ ព្រះត្រៃបិដកនេះជាអំណោយរបស់សម្តេច ឡេ-

វិធពុទ្ធ កាន់ផ្លូវ "ហូទូកេទូ តាមអាយៈរដ្ឋាភិបាលនៃសាធារណរដ្ឋចិន ។

សៀវភៅមួយឈុតនេះ សំខាន់ជាពន់ពេកណាស់ និងមានពីពាក្យប្រៀនប្រដៅ ដែលរួបរួមគ្នាទៅហៅថា អនុត្តរធម៌របស់ព្រះសម្មាសម្ពុទ្ធបរមគ្រូ ។ ជាការពិតណាស់ សៀវភៅនេះ គឺកើតឡើងមកពីអ្នកប្រាជ្ញដ៏ឧត្តម របស់មហាប្រទេសលោក បានខំប្រឹងប្រែងសន្សំតព្យាយាមដ៏យូរ ដើម្បីប្រមូលផ្តុំឯកសារយ៉ាងទូលំទូលាយ ថ្វីបើមានពើបពះប្រទះនឹងការលំបាកយ៉ាងណាក៏ដោយ ខ្ញុំសូមសំដែងនូវសេចក្តីស្ងើចយ៉ាងក្រៀវក្លារបស់ខ្ញុំ ចំពោះអស់លោកអ្នកប្រាជ្ញជាទីនមស្ការៈទាំងនោះ ទោះបីលោកគង់រស់នៅសព្វថ្ងៃនេះក្តី លោកលាងខន្ធទៅកាន់បរលោកនាយហើយក្តី ៗ សូមអស់លោកទាំងនោះទុកចិត្តចុះ ព្រហ្មវិហារធម៌ មានករុណាធម៌របស់លោកជាដើម ចំពោះសត្វលោកឥតសាបសូន្យសោះឡើយ ។

ឯកឧត្តម !

ពុទ្ធមាមកជនណាក៏ដឹងដែរថា ក្នុងសៀវភៅទាំងនេះ មានធម៌ជាទីគោរពនមស្ការ ព្រោះធម៌ទាំងនោះស្តីសុទ្ធសឹងតែពីឯកភាព សាម-គ្គីភាព ភាតរភាព រវាងមនុស្សលោក ព្រមទាំងសកម្មភាពខាងប្រជាសង្គ្រោះ, ការសិក្សា, វប្បធម៌ និងកិច្ចការដទៃទៀតជាមនុស្សធម៌ ដើម្បី

បង្កើតឲ្យមានសន្តិភាព នឹងសុខដុមរមនាមនុស្សជាតិ នឹងសុកមង្គលដល់សត្វលោកទាំងឡាយ ។

ខ្ញុំសូមបន្ថែមសេចក្តីបន្តិចទៀតថា ក្នុងសៀវភៅទាំងនេះ មានពាក្យប្រៀនប្រដៅរបស់ព្រះបរមសាស្តាព្រះអរហន្តសម្មាសម្ពុទ្ធរបស់យើងទាំងអស់គ្នា សុទ្ធសឹងជាពាក្យប្រៀនប្រដៅប្រកបដោយវិចារណញ្ញាណ ហើយប្រសើរអស្ចារ្យ ព្រោះជាពាក្យប្រៀនប្រដៅចង្អុលប្រាប់អ្នកប្រតិបត្តិតាមផ្លូវផ្ទាល់ ផ្លូវត្រង់ទៅកាន់អភិវឌ្ឍនធម៌ ពោលគឺព្រះនិព្វាន ។

ឯកឧត្តម !

អំណោយដ៏ឧត្តមនេះ ជាទីពេញចិត្តយើងខ្ញុំជាពន់ពេកណាស់ អំណោយនេះកើតមានឡើង នៅពេលដែលមហាប្រទេសរបស់ឯកឧត្តម ដូចជាប្រទេសរបស់ខ្ញុំដែរ កំពុងត្រូវការជាក់ឧត្តមគតិ ដែលព្រះសម្មា-សម្ពុទ្ធបរមគ្រូទ្រង់បានកំណត់ហើយ ឲ្យពុទ្ធមាមកៈកាន់យកថែទាំរក្សាគោ-រពជាអចិន្ត្រៃយ៍ ដើម្បីប្រមូលគ្នាជាកំឡាំងមួយ ខាងសន្តិភាពនឹងខាងការស្រុះស្រួលគ្នា ទៅតស៊ូនឹងស្ថានភាពតឹងតែងពិភពលោកសព្វថ្ងៃនេះ នេះ. ១ ១ - ១ ១ ទៀតអំណោយដ៏ឧត្តមនេះ ពង្រឹងសាជាថ្មីម្តងទៀតនូវចំណងមិត្តភាព ដែលមានរាប់ច្រើនរយសតវត្សរ៍មកហើយ រវាងប្រទេសចិននឹងព្រះរាជអាណាចក្រកម្ពុជាផងដែរ ។ ជំនួនទេះមានន័យខាងផ្លូវលោកផ្លូវ

ធម៌ទូលំទូលាយណាស់ ដំនូននេះត្រូវចូលទៅពង្រីកបណ្ណាល័យនៃក្រសួងធម្មការ ក្រសួងធម្មការសប្បាយរីករាយណាស់ នឹងដាក់ជំនូនដ៏ឧត្តមនេះជូនមហាជនប្រើប្រាស់តាមត្រូវការ គឺជាហេតុនាំឲ្យអំណោយនេះជ្រួតជ្រាបជាទីបំផុតដល់ជនានុជនទូទៅ ។

ជាអវសាន ក្នុងនាមនៃរាជរដ្ឋាភិបាល ក្នុងនាមផ្ទាល់នៃខ្ញុំព្រះ-ករុណា - ខ្ញុំ ។ សូមឯកឧត្តម មេត្តាបញ្ជូនចំពោះទៅសម្តេច ទៀវឹនតុង-កានផ្សាយ "ហូទូកេទូ" ព្រមនឹងចំពោះទៅរដ្ឋាភិបាលនៃសាធារណៈរដ្ឋចិន នូវមនោសញ្ចេតនាប្រកបដោយកតញ្ញូតាធម៌ដ៏ក្រៀវក្រា ព្រមទាំងអំណរគុណដ៏បរិសុទ្ធ នៃរាជរដ្ឋាភិបាលខ្មែរឲ្យបានកុំខានផង ។

កាលចប់សេចក្តីថ្លែងសន្ថថាហើយ លោកសង្ឃប៉ះតាំង ៤ អង្គ ចាប់ផ្តើមស្វាធ្យាយធម៌ជាភាសាចិនប្រសិទ្ធពរ ដោយបទសរភញ្ញដ៏ពិរោះ ក្នុងឱកាសនោះ ឯកឧត្តមកុងស៊ុលចិន ក៏ចាប់លើកស្លាយសៀវភៅព្រះត្រៃបិដកមកជូនផ្ទាល់ដៃលោកពយ–ល្វត រដ្ឋមន្ត្រីក្រសួងធម្មការ ចំពោះព្រះភក្ត្រសម្តេចព្រះសង្ឃនាយកទាំងពីរគណៈនិងមន្ត្រីសង្ឃទាំងឡាយ ។ តមក ព្រះសង្ឃខ្មែរ ក៏ស្វាធ្យាយធម៌ជយន្តោប្រសិទ្ធពរជ័យជូនឯកឧត្តមកុង-ស៊ុលចិន និងមន្ត្រីទាំងឡាយ ។

នៅទីបញ្ចប់ ក្នុងបរិយាកាសដ៏ក៏ស្មាន មានការប្រគេន ការលៀងភេសជ្ជៈនិងនំ ចំពោះព្រះសង្ឃនិងភ្ញៀវកិត្តិយសទាំងឡាយ ដោយរីករាយ ។

ពិធីនេះបានចប់សព្វគ្រប់ នៅវេលាម៉ោង១០ព្រឹក ។

# វចនានុក្រមសំស្ក្រឹត ខ្មែរ

( តមក )

## ព្រះមហាប៉ាង–ខាត់ រៀបរៀង

*អង្កុរ* បុំ. ពន្លក, លំពង់ឈើ; សក់, លោហិត, ទឹក; ពហុ. នៅទ្វី ។ -វន្ត, គុ. ដែលមានលំពង់ ។

*អង្កុរក* បុំ. សំបុក ។

*អង្កុឝ* បុំ. កង្វេ ។ គ្រហ, បុំ. អ្នកកាន់កង្វេ, ហ្មដំរី ។ ធរ. បុំ. អ្នកកាន់កង្វេ, ហ្មដំរី ។ អង្កុឝិត ដែលមានកង្វេ ។

*អង្កូរ* បុំ. មើលអង្កុរ ។

*អង្កោឋ, អង្កោដ, អង្កោល, អង្កោល្ល, អង្កោលក,* បុំ. *ដើមអង្កោដ ឬ អង្កោល ។ អង្កោល-សារ,* បុំ. *ខ្ទឹមអង្កោល, ថ្នាំពុល ដែលផ្សំពីខ្ទឹមអង្កោល ។*

*អង្ក្ត* មើលពាក្យ អញ្ជ ។

*អង្ក្យ* គុ. ដែលសំគាល់ដោយសំឡាករបួស ។

*អង្ខ* ធាតុ, កំរើក ។

( មានត )

ផ្នែកខាងព្រះសង្ឃ មានសម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយកគណៈមហានិកាយ, ព្រះពោធិវង្ស ហួត-តាត ថាន់ហាង, ព្រះមហាព្រហ្មមុនី ទេព-អ៊ូ ថាន់ហាងរងជាដើម ។

ផ្នែកខាងគ្រហស្ថ មានលោកយ៉ែម-យុត នាយកមន្ទីរ លោកយ៉ា-គឹមហុង នាយកកាប៊ីណេ តំណាងរដ្ឋមន្ត្រីក្រសួងធម្មការ ជាដើម លោកសម-ញាណ អនុប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ ព្រមទាំងមន្ត្រីបារាំងខ្មែរឯទៀតជាច្រើន ដែលយើងសូមអភ័យទោស ដោយកាយនាមពុំសព្វគ្រប់ ។

ដំបូង ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត បានថ្លែងសុន្ទរ-កថាជាភាសាខ្មែរ ហើយប្រែជាភាសាបារាំង រៀបរាប់អំពីព្រឹត្តិការណ៍នោះ យ៉ាងពីរោះក្បោះក្បាយ ។ បន្ទាប់មក ព្រះសង្ឃមានសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកជាប្រមុខ ចាប់ផ្តើមស្វាធ្យាយធម៌ជយន្តោ ស្រិទ្ធិពរជ័យប្រគេនព្រះគ្រូសង្ឃសត្ថា ឲ្យមានជោគជ័យល្អ ក្នុងដំណើរចេញទៅបន្តវិជ្ជានោះ ។

ចប់ការស្វាធ្យាយធម៌ហើយ មានការជប់លៀងភេសជ្ជៈ នំនំ បំពោះភ្ញៀវកិត្តិយសអស់រយៈវេលាដ៏សមគួរ ។

សន្និបាតនេះ បានចប់នៅវេលាម៉ោង ៦ និង ៣០ នាទីល្ងាច ដោយបរិយាកាស ដ៏ប្រកបដោយសេចក្តីរីករាយយ៉ាងក្រៃលែង ។